ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 18-Sep-2015, 12:58
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្ដីនៅដំណាក់កាលពីរ
# សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥**

**ម៉ោង ០៩:០២នាទី**

**សវនាការលើកទី៣២៧**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក រ៉ូជឺ ហ្វីលីព *(Mr.Roger PHILLIP)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង លាង

លោក ឌេល លីសាក់ *(Mr.Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វិចទ័រ កូប៉េ*(Mr.Victor KOPPE)*

លោក លីវ សុវណ្ណា

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក វ៉ែន ពៅ

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណា

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក សេង ស៊្រុន (2-TCW-880) | ខ្មែរ |

## ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក សេខ ស្រ៊ុន** (2-TCW-880)


សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ..................................................ទំព័រ ២

សួរដោយលោក ឌេល លីសាក់ ផ្ដើមពី ..................................................ទំព័រ ៥

សួរដោយលោក ពេជ អង្គ ផ្ដើមពី ..................................................ទំព័រ ៤២

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី..................................................ទំព័រ ៤៧

សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្ដើមពី..................................................ទំព័រ ៨១

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:៤០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការ ស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-880 ហើយនិងមានសាក្សីបម្រុង 2-TCW-883។ ក្រឡាបញ្ជីសវនាការ លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមានអវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ហើយសាក្សីដែលត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃនេះគឺសាក្សីដែលមានរហស្សនាម 2-TCW-880។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ សាក្សីបានធ្វើសម្បថរួចហើយនៅចំពោះមុខលោកតាដំបងដែកកាលពីព្រឹកមិញនេះ មុននឹងផ្តល់សក្ខីកម្ម។ ហើយនៅថ្ងៃនេះមានសាក្សីបម្រុងមួយរូបគឺ 2-TCW-883។ សាក្សីនឹងធ្វើសម្បថនៅមុនពេលផ្តល់សក្ខីកម្ម។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រី សែ កុលវុឌ្ឍី។ ជាដំបូងនេះអង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ ដែល

បានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ដង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃខាងមុខឱ្យមានប្រសិទ្ធភាព ខ្លួនសូមលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥។ មេធាវីការពារក្ដីរបស់ខ្លួនបានប្រាប់ពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះមិនអាចបកស្រាយថា ជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្ដីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះ គ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ បានកត់សម្គាល់ថា ស្ថានភាពសុខភាពរបស់លោក នួន ជា មានអាការៈវិលមុខ និងឈឺចង្កេះ ពេលអង្គុយ និងបានផ្ដល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឱ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

[០៩:០៥:៤៦]

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឱ្យលោក នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឱ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និង តាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ហើយជាបន្តទៅនេះ បង្គាប់ឱ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សីដែលមានរហស្សនាម 2-TCW-880 ចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្ដីលោកសាក្សី។ តើលោកឈ្មោះអី?

**លោក សេង ស្រ៊ុន៖**

**ឆ៖** ខ្ញុំបាទឈ្មោះ សេង ស្រ៊ុន។

[០៩:០៨:១១]

**ស៖** អរគុណលោក សេង ស្រ៊ុន។ តើលោកកើតនៅថ្ងៃខែឆ្នាំណា? កុំទាល់ឆ្លើយតប ចាំក្បាលមីក្រូហ្វូនប្រតិបត្តិការ ដោយឲ្យភ្លើងសញ្ញាក្រហមសិន។

**ឆ៖** ខ្ញុំកើតនៅខែមករា ឆ្នាំ១៩៤៩។

**ស៖** អរគុណ។ ហើយទីកន្លែងកំណើតរបស់លោក នៅទីកន្លែងណា?

**ឆ៖** ខ្ញុំបាទរស់នៅភូមិសំប្ួរមាស “ក” ឃុំពាមជីកង ស្រុកកងមាស ខេត្តកំពង់ចាម។

**ស៖** អរគុណ។ ចុះទីលំនៅបច្ចុប្បន្នរបស់លោក តើលោករស់នៅទីកន្លែងណា?

**ឆ៖** បច្ចុប្បន្ន ខ្ញុំរស់នៅភូមិសំប្ួរមាស “ក” ឃុំពាមជីកង ស្រុកកងមាស ខេត្តកំពង់ចាម។

**ស៖** លោកប្រកបមុខរបស់រកស៊ីធ្វើអ្វីដែរ សព្វថ្ងៃនេះ?

**ឆ៖** ខ្ញុំបាទជាកសិករ។

**ស៖** ចុះឪពុកបង្កើតរបស់លោកឈ្មោះអី? ហើយម្ដាយបង្កើតរបស់លោក គាត់ឈ្មោះអី?

**ឆ៖** ឪពុកខ្ញុំបាទឈ្មោះ ម៉ោ ហួរ។ ម្ដាយឈ្មោះ ហួយ ស៊ីម។

**ស៖** អរគុណលោក សេង ស្រ៊ុន។ ចុះភរិយារបស់លោកឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** ប្រពន្ធខ្ញុំបាទឈ្មោះ សែម ធឿន។ ខ្ញុំមានកូនប្រាំពីរនាក់។

[០៩:១០:០៤]

**ស៖** បាទ អរគុណ។ ហើយលោក សេង ស្រ៊ុន តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះ ថាតាមសមត្ថភាពដែលលោកអាចដឹង និងគឺថាលោកមិនមានចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន ទេ ហើយក៏មិនមានជាប់ញាតិលោហិត ឬញាតិពន្ធជាមួយនឹងបុគ្គលដែលត្រូវទទួលយកជាភាគីដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២នេះទេ តើពិតមែនដែរទេ?

**ឆ៖** បាទ ពិតមែន។

**ស៖** ហើយលោកបានស្បថនៅចំពោះមុខអ្នកតាដំបងដែកហើយឬនៅ?

**ឆ៖** ខ្ញុំបានស្បថរួចហើយ។

**ស៖** តទៅនេះ យើងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចក្នុងឋានៈលោកចូលរួមក្នុងសវនាការ ក្នុងនាមជាសាក្សី ក្នុងឋានៈជាសាក្សី។ អំពីសិទ្ធិ លោក សេង ស៊្រុន ក្នុងឋានៈលោកជាសាក្សីនៅក្នុងកិច្ចដំណើរការសវនាការចំពោះមុខអង្គជំនុំជម្រះនេះ លោកមានសិទ្ធិអាចបដិសេធក្នុងការឆ្លើយទៅនឹងសំណួរ ឬការសុំឱ្យលោកធ្វើអត្ថាធិប្បាយ ដែលនាំឱ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ អំពីករណីយកិច្ច ក្នុងនាមលោកជាសាក្សីត្រូវតែឆ្លើយតបទៅនឹងរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែសំណួរទាំងឡាយដែលនាំឱ្យចម្លើយតប ឬក៏ការធ្វើអត្ថាធិប្បាយតបរបស់លោក ដែលនាំឱ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងបានប្រាប់អំពីសិទ្ធិរបស់លោករួចហើយអម្បាញ់មិញនេះ។ ក្នុងឋានៈជាសាក្សី ត្រូវតែឆ្លើយឱ្យការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយ ដែលពាក់ព័ន្ធទៅនឹងសំណួរដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។

លោក សេង ស៊្រុន តើលោកធ្លាប់បានផ្តល់សក្ខីកម្ម ឬក៏ផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ ក្នុងរយៈពេលកន្លងមក? ប្រសិនបើមាន តើធ្វើប៉ុន្មានដង ធ្វើនៅទីកន្លែងណា នៅពេលណា?

[០៩:១២:២០]

**ឆ៖** ខ្ញុំបាទ ធ្លាប់ផ្តល់ចម្លើយដល់សាលាក្តីខ្មែរក្រហមហ្នឹង ប្រហែលជាប្រាំដង គឺនៅក្នុងភូមិខ្ញុំផ្ទាល់តែម្តង ខ្ញុំបាទផ្ទាល់តែម្តង ហើយនិងនៅផ្ទះខ្ញុំ។

**ស៖** ពីពេលណាលោកចាំទេ?

**ឆ៖** ពីដំបូងប្រហែលជានៅឆ្នាំ២០០៨។

**ស៖** ចុះចុងក្រោយបង្អស់នៅពេលណា?

**ឆ៖** ចុងក្រោយបង្អស់ប្រហែលជានៅក្នុងឆ្នាំ២០១២, ២០១៣ហ្នឹង។

**ស៖** បាទ អរគុណ។ ហើយមុនពេលចូលមកចំពោះមុខអង្គជំនុំជម្រះនាពេលនេះ តើលោកបានពិនិត្យមើល ឬបានអាននូវកំណត់ហេតុដែលលោកបានផ្តល់ចម្លើយកាលពីពេលមុនជាមួយនឹងអ្នកស៊ើបអង្កេតដែលលោកអះអាងថាបានធ្វើចំនួនប្រាំដង តាំងពីឆ្នាំ២០០៨ រហូតដល់ឆ្នាំ២០១២ ឬ២០១៣នោះ

ដែរឬទេ ដើម្បីរំឭកការចងចាំរបស់លោក?

**ឆ៖** ខ្ញុំបានអាននូវឯកសារខ្លះៗ បានខ្លះដែរ។

[០៩:១៤:00]

**ស៖** ហើយតាមសមត្ថភាពដែលលោកអាចដឹង និង ចងចាំ ថាតើលោកអាចបញ្ជាក់បានដែរទេ ថាកំណត់ហេតុស្តាប់ចម្លើយដែលលោកបានអានដើម្បីរំឭកការចងចាំនោះ ពិតជាត្រឹមត្រូវ ឬក៏វាស៊ីសង្វាក់គ្នា ស្របគ្នាទៅនឹងចម្លើយដែលលោកបានផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេត កាលពីពេលមុននៅនឹងភូមិរបស់លោកនោះដែរឬទេ?

**ឆ៖** ការអានឡើងវិញរបស់ខ្ញុំបាទនេះ គឺខ្ញុំអាចទទួលបានថា ជាពាក្យសម្តីដែលខ្ញុំបានរៀបរាប់ផ្តល់ដល់តុលាការមែន។

**ប្រធានអង្គជំនុំ៖**

អរគុណលោក សេង ស្រ៊ុន។ ក្នុងការសួរដេញដោលសាក្សីរូបនេះ អនុវត្តតាមវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាសួរដេញដោលសាក្សីរូបនេះ មុនភាគីដទៃទៀតនៃរឿងក្តី។ សហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេលពីរវគ្គនៃថ្ងៃសវនាការក្នុងការសួរសាក្សីរូបនេះ។

បាទ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[០៩:១៥:១០]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម មេធាវីការពារក្តី។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ជម្រាបសួរលោក សេង ស្រ៊ុន។ ខ្ញុំមិនដឹងថា លោកចាំខ្ញុំឬក៏អត់ទេ។ ខ្ញុំគឺជាសមាជិកនៃការិយាល័យសហព្រះរាជអាជ្ញា ដែលធ្លាប់បានសម្ភាសលោកកាលពីឆ្នាំ២០០៨។ អរគុណណាស់ដែលលោកបានអញ្ជើញមកថ្ងៃនេះ។ ខ្ញុំសូមសួរអំពីប្រវត្តិសាវតាររបស់លោក នៅក្នុងកិច្ចសម្ភាសន៍លើកទី១ ជាមួយសហចៅក្រមស៊ើបអង្កេត លោកបាននិយាយអំពី និយាយពីការរត់ចូលទៅព្រៃម៉ាគី ដើម្បីចូលរួមចលនាបដិវត្តន៍នៅក្នុងឆ្នាំ១៩៧១ ហើយក្រោយមកលោកក៏បានក្លាយទៅជាមេបញ្ជាការកង

អនុសេនាតូច គ្រប់គ្រងកងទ័ពចំនួន៣០នាក់។ ហើយលោកក៏បានរៀបរាប់អំពីការចូលរួមវាយប្រយុទ្ធគ្នានៅក្នុងការប្រយុទ្ធផ្សេងៗ ដូចជា នៅកំពង់ធំ ពោធិ៍សាត់ និងភ្នំពេញ។ ខ្ញុំចង់សួរលោកថា តើភូមិភាគ តំបន់ ឬក៏ស្រុកមួយដែលកងអនុសេនាតូច -- កងវរសេនាតូច៣០៥ របស់លោកហ្នឹង នៅក្នុងតំបន់មួយណា?

**លោក សេង ស្រ៊ុន៖**

**ឆ៖** ខ្ញុំសូមជម្រាបថា កងវរសេនាតូចរបស់ខ្ញុំ វរ:៣០៥ហ្នឹង គឺស្ថិតនៅក្នុងភូមិភាគ៣០៤ គឺភូមិឧត្តរ ហើយស្ថិតនៅក្នុងតំបន់៣០។

[០៩:១៧:០៦]

**ស៖** នៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ៧០ហ្នឹង ដើមឆ្នាំ៧០ លោកនិយាយអំពីតំបន់៣០ តើលេខតំបន់នេះ មានផ្លាស់ប្តូរទេ ក្រោយឆ្នាំ១៩៧៥?

**ឆ៖** ដល់ឆ្នាំ១៩៧៥ គឺថាតំបន់ហ្នឹងអត់មានផ្លាស់ប្តូរទេ នៅដដែល។

**ស៖** ហើយនៅក្នុងកិច្ចសម្ភាសន៍លោកបានរៀបរាប់ ដែលនៅវរសេនាតូច៣០៥ ដែលជាផ្នែកមួយដែលភូមិភាគឧត្តររហូតដល់ខែមេសា ១៩៧៥។ នៅពេលដែលលោកត្រូវបានចាត់តាំងឱ្យធ្វើការនៅស្វាយទាប ស្រុកចំការលើ។ ហើយបន្ទាប់មកលោកបានឆ្លើយថា នៅដើមឆ្នាំ១៩៧៦ លោកបានទទួលលិខិតមួយច្បាប់ បង្គាប់ឱ្យលោកត្រឡប់ទៅស្រុកកំណើតវិញ នៅភូមិសំបួរមាសៗ ឃុំពាមជីកង ស្រុកកងមាស។ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ មានអ្វីកើតឡើងចំពោះលោក នៅពេលដែលលោកទៅដល់ភូមិសំបួរមាស នៅដើមឆ្នាំ១៩៧៦?

**ឆ៖** នៅក្នុងឆ្នាំ១៩៧៦ ដែលគេបានរំសាយអង្គភាពទ័ព ខ្ញុំត្រឡប់មកភូមិវិញនេះ គឺគេបានបញ្ចូលខ្ញុំទៅក្នុងកងចល័ត។ កងចល័តហ្នឹង គឺសម្រាប់ដើរធ្វើការនៅតាមកន្លែងផ្សេងៗ ដូចជាការដ្ឋានអីផ្សេងៗហ្នឹង។

**ស៖** តើលោកត្រូវបានគេចាប់ខ្លួនមួយរយ:ណាទេ នៅពេលដែលលោកត្រឡប់ទៅភូមិកំណើតវិញ?

**ឆ៖** បាទ នៅក្នុងអំឡុងពេលដែលខ្ញុំមកវិញហ្នឹង មុននឹងគេឱ្យខ្ញុំចូលកងចល័តហ្នឹង គេបានចាប់ខ្លួនខ្ញុំ យកទៅឃុំឃាំង១០ថ្ងៃ។

**ស៖** លោកដឹងទេថា ហេតុអ្វីបានជាគេឃុំខ្លួនលោក១០ថ្ងៃនៅពេលលោកត្រឡប់ទៅស្រុកភូមិ

វិញនោះ?

[០៩:១៩:៥៣]

**ឆ៖** ពេលដែលគេចាប់ខ្ញុំបាទទៅនោះ គឺគេអត់មានបញ្ជាក់ពីទោសកំហុស ឬហេតុផលអី។ ដល់ពេលគេមកចាប់ហ្នឹង គេឲ្យឈ្លបមកចាប់ទៅតែម្ដង ដោយយើងអត់ដឹងរឿងហេតុអីផង។

**ស៖** តើលោកអាចបញ្ជាក់ទេ អ្នកណាទទួលគ្រប់គ្រងកងឈ្លបនៅឃុំពាមជីកង? គឺអ្នកដែលតើអ្នកណាគ្រប់គ្រងសេនាជនដែលមកចាប់ខ្លួនលោកនេះនៅពាមជីកង?

**ឆ៖** បាទ អ្នកដែលមកចាប់ខ្លួនខ្ញុំហ្នឹង គឺមានមេសន្តិសុខមួយឈ្មោះហៅថា មិត្តណាំ តែឈ្មោះគាត់ពិតប្រាកដខ្ញុំអត់ស្គាល់ទេ ប៉ុន្តែអង្កាល់នុំងឈ្មោះបដិវត្តន៍គេហ្នឹងគេហៅ មិត្តណាំៗ។ ហើយអ្នកដែលចាប់ខ្ញុំបាទគឺឈ្មោះ សំរិត មុយ ជាមេឈ្លបនៅឃុំពាមជីកង។

**ស៖** ក្រោយពីលោកត្រូវបានគេដោះលែងក្រោយការឃុំខ្លួន១០ថ្ងៃ ក្នុងឆ្នាំ៧៦។ តើលោករស់នៅទីណា? ហើយគេឲ្យលោកធ្វើអ្វីក្រោយពេលដោះលែងខ្លួន?

**ឆ៖** ក្រោយពីការដោះលែងខ្ញុំបាទមក គឺនៅក្នុងឆ្នាំ១៩៧៦ នេះគេបានឲ្យខ្ញុំបាទរៀបការជាមួយនារីម្នាក់ដែលនៅភូមិខ្ញុំបាទដែរ ហើយបានបញ្ចូលខ្ញុំនៅក្នុងកងចល័តហ្នឹង ដើរធ្វើការតាមការដ្ឋាន។

**ស៖** ហើយកងចល័តដែលលោកទៅធ្វើការជាមួយនេះជាកងចល័តចំណុះឲ្យឃុំ ឬក៏កងចល័តស្រុក ឬក៏កងចល័តតំបន់ លោកអាចបញ្ជាក់បានទេ?

**ឆ៖** កងចល័តដែលខ្ញុំទៅធ្វើការហ្នឹង គឺកងចល័តតំបន់។

[០៩:២២:៣១]

**ស៖** ហើយតើអ្នកណាជាមេកងរបស់លោក?

**ឆ៖** មេកងខ្ញុំបាទហ្នឹងឈ្មោះ ធួក ណូយ។

**ស៖** នៅក្នុងកិច្ចសម្ភាសន៍របស់លោក លោកក៏បានបញ្ជាក់បុគ្គលម្នាក់ឈ្មោះ ហ៊ុន ដែលលោករៀបរាប់ថា ហ៊ុន នេះជាមេកង។ តើលោកអាចបញ្ជាក់ភាពខុសគ្នារវាងតួនាទីរបស់ ណូយ ហើយនិង ហ៊ុន បានទេ?

**ឆ៖** បាទ ហ៊ុន -- ហ៊ន អ៎!ឈ្មោះ ហន និង ណូយ ហ្នឹងគឺវាខុសគ្នាត្រង់ថា ណូយ ហ្នឹងគាត់ជាប្រធានកងទទួលមុខព្រួញតាមមុខសញ្ញាការដ្ឋាន។ ហើយ ហន ហ្នឹងគាត់ជាប្រធានសន្តិសុខស្រុកកងមាស នៅវត្តអូរត្រកួន នៅក្នុងភូមិពាមជីកង ហៅ វត្តមុនីសារវន្តហ្នឹង។

**ស៖** បាទ អធ្យាស្រ័យដល់អំណានរបស់ខ្ញុំផង ខ្ញុំក្រែងអានវាមិនច្បាស់ អានឈ្មោះមនុស្សទៅមិនច្បាស់។ បុគ្គលមួយនេះ ដែលលោកបានបញ្ជាក់ថាជាមេកងនៅក្នុងភូមិរបស់លោកហ្នឹង គឺភូមិសំបួរមាស "ក" ហាក់បីដូចជាឈ្មោះនេះគឺឈ្មោះ ហ៊ុន មិនមែន ហន ទេ។ លោកចាំមេកងទទួលខុសត្រូវភូមិសំបួរមាសទេ?

**ឆ៖** មេកងតាមភូមិនៅភូមិសំបួរមាសហ្នឹង គឺឈ្មោះ ហឿន មិនមែនឈ្មោះ ហន, ឈ្មោះ ហឿន។ ឥឡូវគាត់បានស្លាប់បាត់ហើយ ស្លាប់ គាត់បានធ្វើប្រាំពីរថ្ងៃថ្ងៃហ្នឹងហើយ ហឿន ហ្នឹងមេកងនៅសំបួរមាសហ្នឹង គាត់ស្លាប់ហើយ។

[០៩:២៥:១០]

**ស៖** បាទ អរគុណដែលបានបញ្ជាក់ចំណុចនេះ។ ឥឡូវនេះ ខ្ញុំទៅសួរសំណួរពាក់ព័ន្ធទៅនឹងជនជាតិចាមនៅក្នុងឃុំរបស់លោក គឺឃុំពាមជីកង។ នៅពេលដែលលោកចាកចេញទៅធ្វើជាកងទ័ពនៅដើមឆ្នាំ១៩៧០ តើនៅក្នុងឃុំរបស់លោកមានចាមរស់នៅទេ? ហើយបើមាន ចាមរស់នៅក្នុងភូមិឈ្មោះអីដែរ?

**ឆ៖** បាទ ខ្ញុំកាលពីឆ្នាំ១៩៧០ហ្នឹង គឺបងប្អូនចាមហ្នឹង គឺនៅក្នុងឃុំពាមជីកងយើងខ្ញុំ គឺមានរស់នៅច្រើន តែខ្ញុំមិនអាចស្គាល់អស់ទេ ខ្ញុំស្គាល់ខ្លះៗ ដោយសារមានទំនាក់ទំនងធ្វើការជាមួយគ្នាហ្នឹងទៅធ្វើស្រែចម្ការជាមួយគ្នា ខ្ញុំអាចស្គាល់។ តែបើសិនជាអ្នកផ្សេងៗទៀត ខ្ញុំមិនអាចស្គាល់បានទេ អ្នកដែលខ្ញុំស្គាល់ហ្នឹងគឺដូច ឈ្មោះ ម៉ាន, ឈ្មោះ ហ៊ីម អីហ្នឹងខ្ញុំអាចស្គាល់ ព្រោះគាត់ជាកសិករ ធ្វើស្រែចម្ការនៅជិតខាងខ្ញុំហ្នឹង។

**ស៖** តើភូមិឈ្មោះអ្វីដែលមានចាមរស់នៅច្រើនជាងគេបំផុត កាលពេលនោះ នៅក្នុងឃុំរបស់លោក?

**ឆ៖** ភូមិដែលមានបងប្អូនជនជាតិចាមរស់នៅច្រើនជាងគេបំផុត គឺភូមិសាច់ស្វ ហើយនិងភូមិអន្ទង់ស។

**ស៖** នៅពេលនោះលោកចាំបានទេថា ប្រជាជនចាមប៉ុន្មានគ្រួសាររស់នៅទីនោះ ឬក៏ថាប្រជាជនចាមប៉ុន្មាននាក់រស់នៅភូមិដែលលោកឆ្លើយអំម្បាញ់មិញ គឺភូមិសាច់ស្វនេះ?

[០៩:២៧:២២]

**ឆ៖** ខ្ញុំមិនអាចដឹងតួលេខច្បាស់លាស់ទេ ចំពោះប្រជាពលរដ្ឋចាមដែលគាត់នៅសាច់ស្វហ្នឹង។

ប៉ុន្តែតាមការប៉ាន់ស្មានខ្ញុំដែលមើលចំនួនមនុស្សនៅនេះហ្នឹង ប្រហែលជាបងប្អូនចាមហ្នឹងប្រហែលជាមានល្បាក់ប្រហែលជា ១០០០នាក់ដែរ ក្នុងមួយភូមិសាច់សូ។

**សៈ** តើស្រុកកងមាសស្ថិតនៅតាមដងទន្លេមេគង្គឬ? តើប្រជាជនចាមដែលលោកលើកឡើងនេះ រស់នៅជាប់នឹងទន្លេមេគង្គដែរទេ?

**ឆៈ** បងប្អូនជនជាតិអ៊ីស្លាមហ្នឹង ភាគច្រើនគឺគាត់រស់នៅតាមបណ្ដោយទន្លេមេគង្គហ្នឹងបាទ ព្រោះគាត់ជា របរគាត់គឺភាគច្រើន គឺនេសាទ ធ្វើស្រែចម្ការហ្នឹងគឺមានប្រហែលជា២០ភាគរយទេ ៨០ភាគរយគឺជាអ្នកនេសាទ។

**សៈ** តើមានវិហារទេ នៅភូមិសាច់សូហ្នឹង?

**ឆៈ** បាទ នៅក្នុងភូមិសាច់សូហ្នឹងមានព្រះវិហារ នៅខាងអន្ទង់សហ្នឹង ក៏មានព្រះវិហារដែរ។

**សៈ** ឥឡូវនេះ ខ្ញុំសូមទៅសួរលោកអំពីពេលវេលាដែលលោកត្រឡប់មកឃុំរបស់លោកវិញ នៅដើមឆ្នាំ១៩៧៦។ នៅពេលត្រឡប់មកវិញនៅឆ្នាំ១៩៧៦ តើចាមនៅតែបន្តរស់នៅភូមិសាច់សូដដែលឬ?

**ឆៈ** បាទ ក្នុងឆ្នាំ១៩៧៦នេះ បងប្អូនខាងខ្មែរអ៊ីស្លាមនេះ ត្រូវគេបំបែកឲ្យមកនៅលាយឡំជាមួយបងប្អូនខ្មែរ តាមភូមិនីមួយៗហ្នឹង។ គេអត់ឲ្យបងប្អូនចាមនៅជុំគ្នាទេ គេបំបែកៗមកនៅម្ដុំៗតាមជាមួយបងប្អូនខ្មែរ។

[០៩:៣០:០៩]

**សៈ** ក្រៅពីប្រជាជនដែលត្រូវបានគេបញ្ជូនទៅឲ្យរស់ក្នុងចំណោម ជាមួយនឹងប្រជាជនខ្មែរ តើមានគ្រួសារចាមណានៅតែបន្តរស់នៅភូមិសាច់សូនេះតទៅទៀតដែរទេ?

**ឆៈ** បាទ ក្នុងចំណោមដែលគេឲ្យមកហ្នឹង គឺនៅក្នុងភូមិសាច់សូហ្នឹងមានចាម បងប្អូនចាមនៅខ្លះដែរ គេមិនឲ្យមកទាំងអស់ទេ។ ដោយគ្រាន់តែគេបំបែកគ្នាឲ្យនៅរាយៗអ៊ីចឹងទៅ ដើម្បីអត់ឲ្យមានការប្រមូលផ្តុំ។

**សៈ** ហើយនៅពេលប្រជាជនចាមដែលគេបំបែកពង្រាយទៅទូទាំងឃុំស្រុកហ្នឹងទៅ តើមានចាមណាដែលត្រូវបានគេបញ្ជូនមកភូមិសំបួរមាស “ក” នេះទេ?

**ឆៈ** បាទ ក្នុងភូមិសំបួរមាស “ក” នេះគឺបងប្អូនចាមដែលគេឲ្យមកពីសាច់សូមក គឺភាគច្រើនដែរប្រហែលជា២០-៣០គ្រួសារដែរ។

**សៈ** តើគេដែលធ្លាប់ប្រាប់លោកថា ហេតុអ្វីបានជាប្រជាជនចាមត្រូវបានបញ្ជូនចេញពីភូមិ

សាច់សូ ហើយពង្រាយនៅតាមភូមិផ្សេងៗនៅក្នុងភូមិឃុំរបស់លោកនេះដែរទេ?

**ឆ៖** ខ្ញុំអត់ដែលបានដឹងថាមូលហេតុអីបានគេបំបែកបងប្អូនចាមហ្នឹងទេ គឺខ្ញុំអត់ដែលបានដឹង។

[០៩:៣២:១២]

**ស៖** នៅពេលដែលលោកត្រឡប់មកពាមជីកងវិញ នៅដើមឆ្នាំ៧៦ តើប្រជាជនចាមនៅក្នុងឃុំនោះ ត្រូវបានគេអនុញ្ញាតឲ្យគោរពសាសនា និយាយភាសារបស់ខ្លួន ស្លៀកសម្លៀកបំពាក់ប្រពៃណីចាមដែរទេ?

**ឆ៖** នៅក្នុងឆ្នាំ១៩៧៦ហ្នឹង បងប្អូនជនជាតិចាមហ្នឹងបានត្រូវគេបំបិទសេរីភាពខាងសាសនាហ្នឹង គេអត់ឲ្យគាត់ធ្វើទេ ហើយការស្លៀកពាក់ក៏អត់មានឲ្យស្លៀកពាក់ជារបៀបរបបបងប្អូនអ៊ីស្លាមដែរ គេឲ្យស្លៀកពាក់ធម្មតា ដូចខ្មែរយើងអ៊ីចឹង។

**ស៖** លោកសាក្សី តើលោកដឹងថាមានការបះបោរ ឬក៏ការតវ៉ារបស់ជនជាតិចាមនៅក្នុងស្រុកកងមាសដែរឬទេ? គឺខ្ញុំនិយាយអំពីការបះបោរតវ៉ានៅក្នុងរបបខ្មែរក្រហម។

**ឆ៖** នៅក្នុងស្រុកកងមាសហ្នឹង ជាទូទៅដូចអត់មានសកម្មភាពអីដែលគាត់ចង់ប្រឆាំងនឹងពួកខ្មែរក្រហមទេ ហើយគាត់ក៏អត់ដែលបានធ្វើសកម្មភាពអីក្នុងការតវ៉ាដែរ ព្រោះគាត់ខ្លាចៗ ដូចគាត់អត់ដែលបានបញ្ចេញសកម្មភាពអីទេបាទ។

**ស៖** តើមានអ្វីកើតឡើងចំពោះវិហារចាមនៅភូមិសាច់សូ និងភូមិអន្ទង់ស នៅពេលដែលគេមិនអនុញ្ញាតឲ្យជនជាតិចាមហ្នឹងគោរពទៅតាមជំនឿសាសនាអ៊ីស្លាមរបស់ខ្លួននោះ?

**ឆ៖** នៅកន្លែងវិហារចាមហ្នឹង ពីឆ្នាំ១៩៧៦ហ្នឹងវាបានក្លាយទៅជាកន្លែងខ្មែរនៅ គេយកខ្មែរមកដាក់នៅកន្លែងបងប្អូនចាមហ្នឹង គេយកបងប្អូនចាមឲ្យរស់នៅជាមួយខ្មែរ។ ដូច្នេះកន្លែងវិហារហ្នឹង វាក៏ក្លាយទៅជាកន្លែងគេសម្រាប់ទុកដាក់សម្ភារៈអី ដូចជាភស្តុភារ ដូចជាប្រដាប់ហូបចុកអីហ្នឹង ស្រូវអង្ករហ្នឹង គឺអត់មានបងប្អូនចាមណាអាចចូលទៅបានទេ។

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំសូមសាកសួរលោកពីបញ្ហាទូទៅអំពីវត្តអូរត្រកួន គឺវត្តព្រះពុទ្ធសាសនារបស់លោក គឺវត្តព្រះពុទ្ធសាសនានៅស្រុករបស់លោក។ នៅពេលដែលលោកមកដល់ពាមជីកងនៅឆ្នាំ៧៦ តើលោកស្នាក់នៅក្បែរវត្តអូរត្រកួននោះដែរឬទេ?

**ឆ៖** បាទ នៅឆ្នាំ១៩៧៦ ខ្ញុំមានលំនៅឋាន គឺស្ថិតនៅជិតវត្តអូរត្រកួនហ្នឹង ប្រហែលជាពីផ្ទះខ្ញុំបាទទៅវត្តហ្នឹងប្រហែលជា ២០០ម៉ែត្រទេបាទ ប្រហែលជា២០០ម៉ែត្រពីវត្តអូរត្រកួនហ្នឹង។

**ស៖** តើផ្ទះរបស់លោកនៅតាមផ្លូវទៅវត្តអូរត្រកួនហ្នឹងមែនទេ?

**ឆ៖** បាទ ផ្លូវចូលទៅវត្តអូរត្រកួនហ្នឹងបណ្តោយពីត្បូងតែម្តង គឺផ្ទះខ្ញុំនៅផ្លូវហ្នឹងគឺនៅនឹងមុខផ្ទះខ្ញុំ ចម្ងាយប្រហែលជាល្បាក់ជិត៧០ម៉ែត្រពីផ្លូវហ្នឹង។

**ស៖** នៅពេលដែលលោកត្រឡប់ទៅពាមជីកងនៅដើមឆ្នាំ៧៦ តើនៅពេលនោះលោកឃើញមានព្រះសង្ឃពុទ្ធសាសនានៅវត្តអូរត្រកួនដែរឬទេ?

**ឆ៖** ខ្ញុំត្រឡប់មកវិញឆ្នាំ១៩៧៦ គឺព្រះសង្ឃអត់មានទេ គឺគេផ្សឹកអស់ហើយ។ គេអត់ឲ្យមានព្រះសង្ឃទេ។

**ស៖** តើគេប្រើវត្តអូរត្រកួនហ្នឹងធ្វើជាកន្លែងអីដែរ ក្រោយពេលដែលគេផ្សឹកព្រះសង្ឃអស់នោះ?

**ឆ៖** វត្តអូរត្រកួនក្រោយពីការផ្សឹកព្រះសង្ឃអស់ទៅ កន្លែងនេះក៏ក្លាយទៅជាកន្លែងសន្តិសុខសម្រាប់ឃុំឃាំងមនុស្ស។

**ស៖** លោកបានបញ្ជាក់ថា ផ្ទះដែលលោកស្នាក់នៅហ្នឹងគឺនៅតាមផ្លូវទៅវត្តអូរត្រកួន ហើយមានចម្ងាយប្រហែល២០០ម៉ែត្រពីវត្ត។ តើលោកធ្លាប់ឃើញគេនាំយកមនុស្សទៅវត្តអូរត្រកួន ឬក៏យកចេញពីវត្តអូរត្រកួនដែរឬទេ នៅពេលដែលលោកនៅទីនោះ?

[០៩:៣៨:១៣]

**ឆ៖** នៅតាមផ្លូវនោះគឺខ្ញុំបានឃើញរាល់ថ្ងៃ ពេលដែលគេដឹកប្រជាពលរដ្ឋចូលទៅក្នុងវត្តហ្នឹងគឺចូលរាល់ថ្ងៃ។ ហើយការដឹកចេញហ្នឹងគឺ ដូចមិនសូវមានដឹកចេញទេ ច្រើនតែដឹកចូល។

**ស៖** នៅក្នុងរបបខ្មែរក្រហម ថាតើវត្តអូរត្រកួនហ្នឹង មានរបងព័ទ្ធជុំវិញដែរឬទេ?

**ឆ៖** នៅក្នុងរបបខ្មែរក្រហមហ្នឹង តាំងពីពួកខ្មែរក្រហមវាទៅបង្កើតមន្ទីរសន្តិសុខនៅវត្តអូរត្រកួនហ្នឹង វាបានធ្វើរបងព័ទ្ធជុំវិញ តែធ្វើរបងលួសទេបាទ គឺលួសបន្លាយើងហ្នឹង។ តែកាលពីដើមមក យើងអត់មានរបងទេ ដល់សន្តិសុខគេមកយកកន្លែងហ្នឹងធ្វើជាមន្ទីរសន្តិសុខ គេក៏បានព័ទ្ធរបងលួសហ្នឹងជុំវិញវត្តអូរត្រកួនតែម្តង។

**ស៖** លោកនិយាយថា គេប្រើលួសបន្លា ថាតើលួសបន្លាហ្នឹង អាចឲ្យលោកមើលឃើញទៅក្នុងបរិវេណវត្ត ឬមួយក៏ជារបង ឬក៏ជារបាំងអីដែលធ្វើឲ្យលោកមើលអត់ឃើញបរិវេណខាងក្នុងវត្តទេ? តើយ៉ាងម៉េចដែរ?

**ឆ៖** បាទ កាលពីដំបូងដែលគេទើបនឹងបង្កើតកន្លែងសន្តិសុខហ្នឹង ប្រជាពលរដ្ឋអាចដើរទៅមក

បានតាមរបងនោះដែរ។ ដល់ក្រោយមក រវាងឆ្នាំ១៩៧៧ គឺគេហាមឃាត់យើងឈប់ឱ្យដើរកាត់តាមផ្លូវមុខវត្តនោះហើយ គេបិទ។ ពីមុនមកគេឱ្យយើងដើរធម្មតាអ៊ីចឹង ដូច្នេះ ការមើលអីឃើញ អ្នកទោស អ្នកអី គឺមើលឃើញធម្មតា។

**ស៖** បើមើលពីផ្ទះរបស់លោក ដែលមានចម្ងាយប្រហែល២០០ម៉ែត្រពីវត្ត តើលោកធ្លាប់ឮសំឡេងចេញពីក្នុងវត្តនៅពេលយប់ដែរឬទេ?

[០៩:៤០:៥៧]

**ឆ៖** បាទ វាជាទូទៅពេលណាដែលវាយកមនុស្សទៅសម្លាប់ វាអត់នេះទេ វាចាក់មីក្រូហ្នឹងគឺពីពេលវាចាប់ទៅ ចាក់មីក្រូពីម៉ោងប្រាំពីរ ឬក៏ម៉ោងប្រាំបីទៅ ទាល់តែម៉ោងដប់ ដែលវាបិទហ្នឹងគឺពេលនុំងហើយដែលគេសម្លាប់មនុស្ស វាអត់មានសំឡេងមនុស្សណាស្រែកឮទេ ព្រោះមីក្រូហ្នឹង គេចាក់បន្លប់ដើម្បីឱ្យបំបាត់សំឡេងអ្នកប្រជាជនដែលគេសម្លាប់ ហើយស្រែកអីហ្នឹង គឺអត់ឮទេបាទ។

**ស៖** តើលោកអាចស្តាប់ឮចម្រៀងដែលគេចាក់ហ្នឹងពីផ្ទះលោកដែរឬទេ?

**ឆ៖** បាទ ឮតើ! ឮដល់រហូតដល់ផ្លូវ មិនមែនត្រឹមតែឮផ្ទះខ្ញុំ ឮរហូតផ្លូវ។ ដូច្នេះប្រជាជនទាំងអស់ហ្នឹង មិនអាចឮសំឡេងគេស្រែកបានទេ អ្នកស្រុកស្រែកបានទេ គឺឮតែសំឡេងមីក្រូគេចាក់បន្លប់យើងហ្នឹង។

**ស៖** នៅពេលដែលលោកនិយាយថា គេចាក់ភ្លេងតាមមីក្រូហ្នឹង តើលោកអាចប្រាប់បានទេ ថាលោកចាំទេ ថាគេចាក់ភ្លេងអីដែរ តាមមីក្រូនោះ?

**ឆ៖** គេចាក់ភ្លេងចម្រៀងហ្នឹង ប៉ុន្តែចម្រៀងសម័យប៉ុល ពត ដែលគេបង្កើតឡើងហ្នឹង គឺអត់មានចម្រៀងស្អីទេ គឺអាចម្រៀងពីសម័យប៉ុល ពតហ្នឹង ខ្ញុំមិនជាចាំច្បាស់ទេ។ ប៉ុន្តែសុទ្ធតែចម្រៀងសម័យ ប៉ុល ពត ដែលគេទើបនឹងតែងថ្មីហ្នឹង។

**ស៖** មុននេះបន្តិចលោកនិយាយថា គេចាក់ភ្លេងតាមមីក្រូនៅពេលដែលគេសម្លាប់មនុស្ស។ ខ្ញុំចង់ដឹងថា តើលោកធ្វើយ៉ាងណាបានដឹងថា នៅពេលដែលគេចាក់ភ្លេងហ្នឹង គឺគេសម្លាប់មនុស្សនោះ?

[០៩:៤៣:០៧]

**ឆ៖** បាទ នៅពេលដែលគេចាក់ភ្លេង បានន័យថា គេសម្លាប់មនុស្សហ្នឹង ព្រោះខ្ញុំនៅពេលនោះគេឱ្យខ្ញុំឡើងត្នោត។ ហើយការឡើងត្នោតហ្នឹង គឺពួកសន្តិសុខហ្នឹងគេៗឡើងត្នោតដែរ ហើយត្នោតខ្ញុំនិងត្នោតគេហ្នឹងវានៅជាប់គ្នា។ ហើយដល់យើងមកស្គាល់គ្នារាល់ថ្ងៃទៅ ក៏មានទំនាក់ទំនងអ៊ីចឹងទៅ។

ហើយកិច្ចការអីដែលនៅក្នុងវត្តហ្នឹង ពេលដែលគេចាក់មីក្រូអីម៉េចៗហ្នឹង គឺឈ្មោះ មឿន ជាអ្នកឡើងត្នោតហ្នឹងដែរនៅក្នុងមន្ទីរសន្តិសុខហ្នឹង បានប្រាប់ខ្ញុំថា "បងឯងនេះទៅ ឲ្យតែគេចាក់មីក្រូហ្នឹង គឺគេយកមនុស្សទៅសម្លាប់ហើយ"។ ពេលដែលគេចាក់មីក្រូហ្នឹង បានន័យថាគេបន្លប់ កុំឲ្យសំឡេងដែលជនរងគ្រោះដែលស្រែក ដែលក្នុងការឈឺចាប់អីហ្នឹង កូនក្មេងដែលគេសម្លាប់អីហ្នឹង គឺវាអត់មានឮសំឡេងអីទេ ឲ្យតែពេលគេចាក់មីក្រូ គឺថ្ងៃហ្នឹងហើយគេសម្លាប់មនុស្ស។ តែវាមិនមែនចាក់រាល់ថ្ងៃទេ គឺជួនណារំលងមួយយប់ទៅ ជួនណាក៏ជាប់គ្នាទៅ។ ឲ្យតាមដំណឹងពីឈ្មោះ មឿន ហ្នឹងព្រោះ មឿន និងខ្ញុំហ្នឹងឡើងត្នោត ដើមត្នោតជាប់គ្នាហ្នឹង ប្រហែលបីបួនម៉ែត្រពីគ្នា គឺអាចនិយាយគ្នាបាន។

**ស៖** ខ្ញុំសូមសួរលោកបន្តិចអំពីការងាររបស់លោកជាអ្នកឡើងត្នោត។ គឺថាលោកនៅជិតវត្តអូរត្រកួន ហើយនៅពេលដែលលោកធ្វើការងារជាអ្នកឡើងត្នោតពីឆ្នាំ៧៦ ដល់៧៨ ខ្ញុំចង់សួរថា តើនៅពេលដែលលោកឡើងត្នោតហ្នឹង គឺលោកឡើងត្នោតនៅជិតវត្តអូរត្រកួនដែរ មែនទេ?

**ឆ៖** បាទ ខ្ញុំឡើងត្នោតហ្នឹងគឺនៅជុំវិញបរិវេណវត្តអូរត្រកួនហ្នឹង។

[០៩:៤៥:១៦]

**ស៖** តើដើមត្នោតដែលលោកឡើងហ្នឹងវានៅចម្ងាយប្រហែលប៉ុន្មានម៉ែត្រដែរ ពីវត្តអូរត្រកួន?

**ឆ៖** ដើមត្នោតដែលខ្ញុំឡើងហ្នឹង គឺវាចម្ងាយពីរបងវត្តហ្នឹងប្រហែលជា២០ម៉ែត្រ។

**ស៖** ឥឡូវនេះ ខ្ញុំចង់សួរលោកអំពីការមកដល់របស់កម្មាភិបាលនិរតីនៅក្នុងភូមិភាគរបស់លោកវិញ។ តើលោកអាចជម្រាបតុលាការបានទេថា លោកចាំបានអ្វីខ្លះអំពីការមកដល់របស់កម្មាភិបាលភូមិភាគនិរតី? ហើយខ្ញុំចង់ដឹងថា តើមានអ្វីកើតឡើងផងដែរចំពោះកម្មាភិបាលភូមិភាគឧត្តរ នៅពេលដែលពួកនិរតីចូលមកដល់នោះ?

**ឆ៖** បាទ កាលពីមុនប្រធានសន្តិសុខហ្នឹង គឺសុទ្ធតែនៅខាងភូមិភាគឧត្តរ ហ្នឹងគឺភូមិភាគ៣០៤ហ្នឹង។ ក៏ប៉ុន្តែដល់ពេលដែលពួកនិរតីចូលមកហ្នឹង ពួកដែលជាប្រធានសន្តិសុខចាស់ ដូចជា ឈ្មោះ ឃុនគាត់ឈ្មោះ ឃុន ជាប្រធានសន្តិសុខចាស់នៅក្នុងវត្តអូរត្រកួនហ្នឹង ហើយដល់ប្រហែលជាបីបួនខែក្រោយមក ពួកនិរតីបានចូលមក។ ដំបូងគឺពួកហ្នឹងទេ អត់ពួកនិរតីចូលមកទេ គឺពួកសន្តិសុខនៅខាងតំបន់ ភូមិភាគឧត្តរហ្នឹងទេ តំបន់៣០ហ្នឹងទេ គាត់គ្រប់គ្រងនៅវត្តអូរត្រកួនហ្នឹង។ ដល់ប្រហែលជាពីរបីខែ ទើបមានបញ្ជូនខាងសន្តិសុខ ខាងភូមិភាគនិរតីហ្នឹងមក។ ដល់ពួកសន្តិសុខហ្នឹងមក គេក៏ធ្វើការជាមួយគ្នា ជាមួយពួកសន្តិសុខចាស់ហ្នឹងទៅ ឃុន ហ្នឹងក៏គាត់នៅជាប្រធានសន្តិសុខដដែល។ ក៏ប៉ុន្តែ

ពីរបីខែកន្លងមកហ្នឹង ស្រាប់តែគេថា យុន ហ្នឹងគេឲ្យឡើងទៅលើ ហើយគេឲ្យ ហាន ហ្នឹងធ្វើប្រធានសន្តិសុខវិញ។ ក៏ប៉ុន្តែដល់នេះទៅ ខ្ញុំអាចទទួលព័ត៌មានពីអ្នកធ្វើការខ្លះមកហ្នឹង គេថា យុន ហ្នឹងគេបានយកទៅសម្លាប់ចោលហើយនៅវត្តគរ ព្រោះវត្តគរហ្នឹងមានកន្លែងសន្តិសុខតំបន់ កន្លែងតំបន់។ គេបញ្ជូនយុន ហ្នឹងទៅកន្លែងសន្តិសុខតំបន់ហ្នឹងសម្លាប់ចោលហើយ ប៉ុន្តែគេអត់ប្រាប់ថា យកទៅសម្លាប់ចោលទេ គេថាផ្លាស់ទៅលើ។ ដូច្នេះអ្នកដែលគ្រប់គ្រង មេដឹកនាំធំៗនៅក្នុងសន្តិសុខស្រុកហ្នឹង គឺគេសម្លាប់ចោលអស់ហើយ នៅតែកូនចៅវាយរងដែលជាអ្នកដើរចាប់មនុស្សចាប់អីហ្នឹង គឺគេអត់ទាន់នេះទេ គេទុកនៅប្រើនៅឡើយ ដែលគេចាប់តែអ្នកគ្រប់គ្រងមន្ទីរសន្តិសុខចាស់ហ្នឹងទេ។ ហើយ ហាន ហ្នឹងក៏គាត់មកកាន់កាប់នៅវត្តអូរត្រកួនហ្នឹងជាប់ពីពេលដែលគេចាប់មេសន្តិសុខចាស់ហ្នឹងទៅបាត់ទៅ។

[០៩:៤៨:៥៣]

**ស៖** ចុះកម្មាភិបាលឧត្តរដែលស្ថិតនៅថ្នាក់ឃុំ ហើយនិងថ្នាក់ស្រុក ខ្ញុំចង់ដឹងថា តើមានអ្វីកើតឡើងចំពោះពួកគាត់នៅពេលដែលកម្មាភិបាលមកពីនិរតីចូលមកដល់នោះ?

**ឆ៖** បាទ ពេលដែលពួកនិរតីចូលមកដល់នៅក្នុងភូមិភាគ៣០៤ហ្នឹង គឺតាំងពីប្រធានសង្កាត់ប្រធានឈ្លប អីនៅតាមនេះហ្នឹង គឺគេបានចាប់ខ្លួនទាំងអស់បាទ គឺគេយកទៅសម្លាប់ចោលអស់ អត់មានទុកទេ។ អ្នកដែលជាប់ធ្វើការពីមុនៗមកនៅក្នុងឃុំ នៅស្រុក គឺគេចាប់ទាំងអស់ អត់មានទុក។

**ស៖** ខ្ញុំសូមអាននូវសម្រង់មួយចេញពីកំណត់ហេតុស្តាប់ចម្លើយរបស់លោក គឺ E3/8736។ ហើយគឺចាប់ពីសំណួរទី២ ដល់សំណួរទី៤។ លោកបានផ្តល់សក្ខីកម្មដូចតទៅនេះ៖ "នៅពេលដែលកម្មាភិបាលឧត្តរ គឺថាពួក -- នៅពេលដែលពួកនិរតីមកដល់គឺគេចាប់ពួកឧត្តរ ហើយគេចោទប្រកាន់ថាជាប់ខ្សែជាមួយ កុយ ធួន។ សំណួរ៖ តើមានស្ថានភាពបែបណាចំពោះអ្នកដែលត្រូវបានគេចាប់ខ្លួននោះ? ចម្លើយ៖ ពួកគេស្លាប់ទាំងអស់។ ពួកគេត្រូវបានគេសម្លាប់ ជាពិសេសពួកខាងខ្សែ ធុច ហើយនិងស្រេង។ សំណួរ៖ តើលោកឃើញការសម្លាប់ដោយផ្ទាល់ ឬក៏គ្រាន់តែឮទេ? ឆ្លើយ៖ ចំពោះថ្នាក់លើៗ ខ្ញុំមិនបានដឹងទេ ប៉ុន្តែសម្រាប់ថ្នាក់មូលដ្ឋានដូចជាថ្នាក់ឃុំ ដែលត្រូវបានចោទជាខ្សែ កុយ ធួន ពួកគេត្រូវបានសម្លាប់នៅក្នុងវត្តអូរត្រកួននេះតែម្តង។ គឺ តាកាន ពួកសន្តិសុខថ្មីជាអ្នកបញ្ជាឲ្យសម្លាប់។" ដូច្នេះខ្ញុំចង់សួរលោកជាដំបូងថា គឺចង់ឲ្យលោកបញ្ជាក់បន្តិច តើអ្នកណាជាអ្នកប្រាប់លោកថា កម្មាភិបាលឧត្តរដែលត្រូវបានគេចោទប្រកាន់ថាជាខ្សែរបស់កុយ ធួន នោះ តើអ្នកណាជាអ្នកប្រាប់លោកអំពីបញ្ហានេះ?

[០៩:៥១:៣៦]

**ឆ៖** បញ្ហាហ្នឹងគឺខ្ញុំមិនមែនជាអ្នកតាមដានសភាពការណ៍ទេ ក៏ប៉ុន្តែការលេចឮ ការនេះគឺជាក់ស្តែង គឺខ្ញុំឃើញ មិត្តខែង ហ្នឹងជាគាត់ជាប្រធានសង្កាត់ចាស់ជាមួយ មិត្តអ៊ី ហ្នឹង។ ក៏ប៉ុន្តែ មិត្តអ៊ី ហ្នឹងគាត់ជាខាងចៅសង្កាត់ដែរ គេចាប់គាត់ទៅគរ ជាមួយ មិត្តណាំ មិត្តអ៊ីហ្នឹងដែលជាគាត់សន្តិសុខចាស់ហ្នឹង។ ហើយចំពោះមួយទៀត សង្កាត់ចាស់ដែរ មិត្តខែង អាហ្នឹងក្រោយពីគេចាប់ មិត្តអ៊ី ទៅគេដំឡើង មិត្តខែង ហ្នឹង។ ហើយ មិត្តខែង ហ្នឹងគឺអង្គាល់នុំង ដូចខ្ញុំបានជម្រាបអ៊ីចឹងថា នៅក្នុងវត្តអូរត្រកួនហ្នឹង ដំបូងគេអត់សូវរឹតត្បិតក្នុងការដើរអី ប្រជាជនដើរទៅធ្វើការហ្នឹងគេអត់សូវរឹតត្បិតទេ យើងអាចដើរតាមនោះបាន។ ហើយខ្ញុំដើរទៅហ្នឹង ខ្ញុំបានប្រទះឃើញ មិត្តខែង គាត់មិនមែនស្លាប់នៅ គេដឹកយកទៅក្រៅទេ គឺគាត់ស្លាប់នៅនឹងវត្តអូរត្រកួនហ្នឹង ដោយការគេចងជើងគាត់ព្យួរឡើងលើ បាទ នៅក្នុងសាលាបង្រៀនហ្នឹង។

**ស៖** តើលោកអាចប្រាប់តុលាការបានទេថា កម្មាភិបាលថ្មីមកពីភូមិភាគនិរតីដែលមកកាន់តួនាទីធ្វើជាមេឃុំពាមជីកង និងជាលេខាស្រុកកងមាស និងជាលេខាតំបន់ហ្នឹង តើអ្នកណាខ្លះជាអ្នកទទួលយកតួនាទីទាំងអស់នេះនៅពេលដែលពួកកម្មាភិបាលមកពីនិរតីចូលមកដល់នោះ? តើលោកអាចប្រាប់បានទេ?

[០៩:៥៣:៣២]

**ឆ៖** បាទ ខ្ញុំសូមជម្រាបថា នៅក្នុងពេលដែលគេចាប់កម្មាភិបាលចាស់អស់ទៅ គឺគេយកកម្មាភិបាលថ្មីខាងផ្នែកនិរតីហ្នឹង។ ទី១ គឺនៅខាងតំបន់ហ្នឹងគឺឈ្មោះ អាន ប៉ុន្តែខ្ញុំអត់ស្គាល់នាមត្រកូលគាត់ទេ ប៉ុន្តែគេហៅ មិត្តអាន១ ហ្នឹង។ គាត់ជាប្រធានតំបន់៣០ហ្នឹង។ ហើយនៅក្នុងស្រុកកងមាសហ្នឹងគឺឈ្មោះ កាន។ កាន ហ្នឹងគាត់ទទួលខុសត្រូវស្រុកកងមាសហ្នឹង ជាចៅហ្វាយស្រុកកងមាស ហើយមានប្រពន្ធគាត់មួយទៀតឈ្មោះ ភាព – ភាព ហ្នឹងគាត់ដូចជាអនុប្តីគាត់អ៊ីចឹង។ ហើយប្រធានសង្កាត់ថ្មីហ្នឹងគាត់ឈ្មោះ ខេន ដែលទីលំនៅគាត់នៅឃុំរាយប៉ាយ។ ហ្នឹងជាអ្នកស្នងពីកម្មាភិបាលដែលគេចាប់ខ្លួនបាត់ទៅ។

**ស៖** តើនៅពេលដែលកម្មាភិបាលនិរតីមកដល់ហ្នឹង តើពួកគេមកដល់នៅពេលណា? ហើយតើកម្មាភិបាលឧត្តរហ្នឹងត្រូវបានគេចាប់ខ្លួននៅពេលណា?

**ឆ៖** កម្មាភិបាលខាងភូមិភាគឧត្តរហ្នឹង គឺមានការចាប់ខ្លួននៅរវាងក្នុងឆ្នាំ១៩៧៦ ឬក៏៧៧ហ្នឹង។ ប៉ុន្តែបើតាមខ្ញុំចាំ ចាប់ខ្លួននៅក្នុងឆ្នាំ១៩៧៦ ពេលនោះគឺមានចាប់ខ្លះ នៅខ្លះ ក៏ប៉ុន្តែដល់ពេល ឆ្នាំ៧៧

ហ្នឹងគឺគេចាប់អស់ហើយ អស់តែម្តង។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតផ្តល់ឯកសារពីរ គឺកំណត់ហេតុរបស់មន្ទីរ ស-២១ ជូនទៅដល់សាក្សី ដើម្បីជួយសាក្សីឱ្យអាចកំណត់បាន ក៏ដូចជារំឭកការចងចាំរបស់គាត់អំពីពេលវេលា នៃការចាប់ខ្លួនកម្មាភិបាលមួយចំនួន គឺឯកសារទាំងពីរនេះគឺ E3/2956 និង E3/3861 គឺE3/3861។ ខ្ញុំសូមរង់ចាំការជំទាស់របស់មេធាវីសិន។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីទាំងអស់។ ខ្ញុំជំទាស់ទៅលើឯកសារទាំងអស់នេះ។ ដើម្បីជាកំណត់ត្រាប្រតិចារឹក ខ្ញុំសូមជំទាស់ដោយសារតែ សាក្សីនេះ គាត់អត់មានអ្វីអាចទាក់ទងទៅនឹងកំណត់ហេតុរបស់មន្ទីរស-២១ ឡើយ។ ប្រសិនបើព្រះរាជអាជ្ញាអាចបង្ហាញអំពីឈ្មោះបាន នោះបញ្ហា ប៉ុន្តែសាក្សីនេះ គាត់មិនមែនធ្វើការនៅមន្ទីរស-២១ នោះទេ។ ដូច្នេះ ខ្ញុំជំទាស់ទៅនឹងការសួរសំណួរបែបនេះ។ សូមអរគុណ។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតឆ្លើយតប។ គោលដៅដែលខ្ញុំធ្វើនេះ គឺដូចដែលយើងធ្វើកន្លងមករួចមកហើយ។ ទី១ គឺដើម្បីជួយដល់ការកំណត់ពេលវេលានៃការចាប់ខ្លួន និងទី២ ដើម្បីជួយពីព្រោះថាពេលខ្លះនៅពេលដែលយើងអាចផ្តល់ឯកសារជូនដល់សាក្សី សាក្សីគាត់អាចចាំ ឬក៏នឹកឃើញអំពីឈ្មោះទាំងអស់នោះ គឺវាប្រសើរជាងការដែលខ្ញុំប្រាប់គាត់ដោយផ្ទាល់មាត់។ សូមលោកប្រធានអនុញ្ញាត។

[០៩:៥៧:៥០]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៥៨:៣០]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសម្រេចបដិសេធនូវសេចក្តីជំទាស់របស់មេធាវី វ៉ិចទ័រ កូប៉េ មេធាវីការពារក្តីលោក នួន ជា ចំពោះការតាំងសំណួរ ការដាក់បង្ហាញ ស្នើសុំដាក់បង្ហាញឯកសារចំនួនពីររបស់សហព្រះរាជអាជ្ញារងអន្តរជាតិ។ ហើយការលើកឡើង និងការសម្អាងហេតុរបស់សហព្រះរាជអាជ្ញារងអន្តរជាតិ លើបញ្ហានេះ មានលក្ខណៈសមស្រប ហើយទំនងជាការដាក់បង្ហាញនេះ មិនមែនគោលដៅនៃ

ការបង្ហាញរួមទៅលើខ្លឹមសារនៃឯកសារនោះទេ។

បាទ អង្គជំនុំជម្រះអនុញ្ញាត។

**លោក ខេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោកសាក្សី គឺថាគេបានប្រគល់ឯកសារពីរជូនលោករួចទៅហើយ។ ដូច្នេះខ្ញុំសូមឲ្យលោកមើលទៅលើឯកសារទី១គឺ E3/2956 គឺជាបញ្ជីអ្នកទោស ស-២១ ដែលមានចំណងជើងថា "អ្នកទោសមកពីភូមិភាគឧត្តរ" នៅថ្ងៃ០១ កុម្ភៈ រហូតដល់ថ្ងៃ២០ ខែមីនា ឆ្នាំ៧៦ ដែលបង្ហាញពីបញ្ជីឈ្មោះអ្នកទោស៨៤ ដែលត្រូវបានចាប់ខ្លួន ហើយបញ្ជូនទៅស-២១ ចន្លោះពាក់កណ្ដាលខែកុម្ភៈ និង ខែមីនា។ ដូច្នេះ ខ្ញុំចង់ឲ្យលោកមើលទៅលើឈ្មោះទី១ នៅក្នុងបញ្ជីនេះ។ ឈ្មោះទី១គឺ ជ ឆាន ហៅ ស្រេង ដែលត្រូវបានកត់ត្រាថា ចូលស-២១នៅថ្ងៃ១៨ កុម្ភៈ ឆ្នាំ៧៧។ តើលោកចាំឈ្មោះ ស្រេង ហ្នឹងដែរឬទេ?

[១០:០០:៣៥]

**លោក សេង ស៊្រុន៖**

**ឆ៖** វា ស្រេង ហ្នឹងបើសិនជា ព្រោះឈ្មោះដើមគេ ខ្ញុំអត់ដឹងថាឈ្មោះស្អីទេ ប៉ុន្តែឈ្មោះ ស្រេង ហ្នឹង បើតាមខ្ញុំស្គាល់គាត់ គាត់ជាប្រធានភូមិភាគ បន្ទាប់ពីគេចាប់ឈ្មោះ កែ ពក -- អឺ កុយ ធួន ហៅ ធុច ហ្នឹង។ ហើយក្រោយមក គាត់បានឡើងជាប្រធានភូមិភាគ គេហៅ តាស្រេងៗ ហ្នឹង ប៉ុន្តែឈ្មោះដើមគាត់ ខ្ញុំអត់ស្គាល់ទេ។

**ស៖** ឥឡូវនេះបើសិនជា សូមលោកពិនិត្យមើលឯកសារទី២ គឺឯកសារ E3/3861 មើលលេខរៀងទី១០៣ នៅលើបញ្ជីនេះ។ នេះគឺជាបញ្ជី គេហៅថាបញ្ជីអ្នកទោសស-២១ បញ្ជីអ្នកទោសដែលបានកម្ទេចនៅថ្ងៃទី០៨ កក្កដា ១៩៧៨ មកពីភូមិភាគឧត្តរ ដែលមានអ្នកទោសទាំងអស់១៧៣នាក់ មកពីភូមិភាគឧត្តរ ដែលត្រូវបានសម្លាប់នៅថ្ងៃនោះ។ លេខរៀងទី១០៣ នៃបញ្ជីអ្នកទោសនេះ ដែលខ្ញុំបានដាក់*ហាយឡាយ*ថា គួសពណ៌ឈ្មោះ ជុំ ឈុន ហៅ ថាង ជាលេខារបស់តំបន់៤១ មកចូលស-២១ នៅថ្ងៃទី១៨ កុម្ភៈ ១៩៧៧ នៅថ្ងៃខែឆ្នាំតែមួយ ដូចគ្នានឹង ស្រេង ដែរ។ ថេង ក៏មានឈ្មោះនៅលើបញ្ជីលេខ៥៦ លើ E3/2956 ត្រង់លេខរៀង៥៦។ តើលោកធ្លាប់បានឮឈ្មោះ ថាង នេះទេ?

**ឆ៖** បាទ ឈ្មោះមិនមែនឈ្មោះ ថាង ទេគេហៅគាត់ហ្នឹងឈ្មោះ តាតាំង១។ ខ្ញុំស្គាល់គាត់

ច្បាស់ណាស់ ព្រោះគាត់ពីមុនមក គាត់ជាចៅហ្វាយស្រុកនៅស្រុកកងមាស។ តាតាំងៗ ហ្នឹងគាត់មិនមិនឈ្មោះ ស្រេង ទេ គាត់ឈ្មោះ តាំង មិនមែន ថាង ទេ។ ប៉ុន្តែឈ្មោះដើមខ្ញុំនេះ ខ្ញុំអត់ស្គាល់ទេ គេហៅថា តាតាំងៗ គឺខ្ញុំស្គាល់គាត់ច្បាស់ តាតាំង ហ្នឹងគឺគាត់នៅធ្វើជាចៅហ្វាយស្រុកនៅស្រុកកងមាស ក្រោយមកគាត់បានផ្លាស់ទៅនៅតំបន់៤១ ។

[១០:០៣:៣០]

**ស៖** លោកសាក្សី តើកំណត់ត្រានេះ រំឭកដល់ការចងចាំរបស់លោកទេ ថានៅដើមឆ្នាំ១៩៧៧ ប្រហែលជាក្នុងខែកុម្ភៈ ១៩៧៧ មិនមែនឆ្នាំ១៩៧៦ទេ គឺនៅពេលដែលកម្មាភិបាលនិរតីមកដល់ ហើយកម្មាភិបាលថ្នាក់តំបន់នោះ គឺថាកម្មាភិបាលនៅក្នុងភូមិភាគនោះត្រូវបានចាប់ខ្លួន?

**ឆ៖** បាទ រឿងកម្មាភិបាល ឆ្នាំ៧៦, ៧៧ហ្នឹង ដូចខ្ញុំបានបញ្ជាក់ហើយ មួយជំនាន់នោះ យើងអត់មានស្អីកំណត់សម្គាល់ថាខែប៉ុន្មានៗទេ គឺវាបាត់បង់អស់ហើយ គេអត់ឲ្យមានយើងនេះទេ។ ខ្ញុំគ្រាន់ចាំថា រវាងចុងឆ្នាំ៧៦ ហើយនិងអាចដើមឆ្នាំ៧៧។ តែឲ្យកំណត់ថា ខែអី ព្រោះសម័យនុ៎ងវាអត់មានអីណា ខែកុម្ភៈ មីនា មករាណា គឺអត់មានទេ សូម្បីតែថ្ងៃក៏មិនដឹងថ្ងៃអីៗដែរ។

**ស៖** មិនជាអ្វីទេ។ សូមឲ្យលោកមើលឯកសារនេះម្តងទៀត គឺមើលឯកសារ E3/3861 ដដែល ត្រង់លេខរៀង៣៥ នៃបញ្ជីអ្នកទោសនេះ។ លេខរៀង៣៥ ឈ្មោះ ជួន អុល ហៅ មាស ជាលេខាស្រុកកងមាស ដែលគេបញ្ជូនមកស-២១ នៅថ្ងៃទី២៦ ខែកុម្ភៈ ១៩៧៧។ ត្រង់លេខរៀង៣៥ ជួន អុល ហៅ មាស។ លោកនៅចាំមនុស្សឈ្មោះ មាស ជាលេខាស្រុកកងមាស ដែរឬទេ?

[១០:០៥:៣៤]

**ឆ៖** បាទ ឈ្មោះ មាស ហ្នឹងគឺខ្ញុំស្គាល់។ តែឈ្មោះដើមឈ្មោះ ជួន អុល នេះ ខ្ញុំអត់ស្គាល់ទេ ព្រោះមួយសម័យ ប៉ុល ពត អត់ដែលនរណាឈ្មោះពីរទេ បើអ្នកណាឈ្មោះស្អីគឺឈ្មោះហ្នឹង។ ក៏ប៉ុន្តែ ឈ្មោះ មាស នេះខ្ញុំស្គាល់ គាត់ជាអនុប្រធានស្រុកមែន ប៉ុន្តែក្រោយមកគាត់បានត្រូវគេតែងតាំងគាត់ជាប្រធានយោធាស្រុកកងមាស ទៅជាប្រធានយោធាស្រុកកងមាស។

**ស៖** សូមអរគុណ ដែលបានពិនិត្យមើលបញ្ជីនេះ ហើយឆ្លើយនឹងសំណួរ។ ឥឡូវនេះខ្ញុំសុំទៅសួរសំណួរក្រោយពេលកម្មាភិបាលភូមិភាគនិរតីទៅដល់ តើលោកនៅចាំថា លោកត្រូវបានគេហៅទៅប្រជុំនៅពេលដែលលេខាស្រុកថ្មី ឡើងធ្វើសុន្ទរកថា ឡើងនិយាយហ្នឹង លោកធ្លាប់ត្រូវបានគេហៅទៅប្រជុំដែរទេ?

**ឆ៖** លេខាស្រុកថ្មីហ្នឹង ដូចគាត់អត់ដែលបានហៅប្រជាពលរដ្ឋអីទៅចូលរួមទេ មានតែលេខាខាងតំបន់ ប្រធានតំបន់គឺ មិត្តអាន ហ្នឹងគឺគាត់បានទៅប្រជុំនៅវត្តអូរត្រកួនហ្នឹង នៅក្នុងវត្តអូរត្រកួន ឃុំយើងខ្ញុំហ្នឹង មានតែ តាអាន ហ្នឹងទេ ដោយមានចូលរួមទាំង កាន ហ្នឹងដែរ ប៉ុន្តែការដែលគាត់ថ្លែងការណ៍អី គាត់និយាយហ្នឹងគឺ អាន ហ្នឹងទេគាត់អ្នកនិយាយ។

**ស៖** តើ អាន មាននិយាយអំពីអ្វីដែរទេ នៅក្នុងពេលប្រជុំអំពីកម្មាភិបាលភូមិភាគឧត្តរហ្នឹង? ហើយមាននិយាយថា ហេតុអ្វីបានជាកម្មាភិបាលទាំងនោះត្រូវបានចាប់ខ្លួនដែរទេ?

[១០:០៧:៤០]

**ឆ៖** តាមវារៈប្រជុំហ្នឹង គឺគាត់បាននិយាយច្រើន។ គាត់និយាយពីកម្មាភិបាលនៅក្នុងភូមិភាគឧត្តរហ្នឹង គាត់ថាសុទ្ធតែជាមនុស្សក្បត់។ ហើយមួយទៀត គាត់បាននិយាយពីជីវភាពរស់នៅប្រជាពលរដ្ឋហ្នឹងក្នុងការស៊ីៗហ្នឹង ដូចថាការហូបចុកអីហ្នឹង។ គាត់ចង់មានន័យថា នៅក្នុងសហករណ៍ នៅក្នុងរោងបាយហ្នឹង តើប្រធានកងមួយណាដែលឲ្យប្រជាពលរដ្ឋស៊ីបបរវាវ ស៊ីអីអ៊ីចឹងទៅណា គាត់អ៊ីចឹង។ ក៏ប៉ុន្តែការដែលយើងដាំដំណាំតាមគ្រួសារហ្នឹង គាត់បាននិយាយថា ពីណាមិនឲ្យយើងគាស់ហូប ព្រោះរបស់យើងខំដាំ យើងត្រូវតែហូប។ ហ្នឹងជាយុទ្ធសាស្ត្រគាត់ មកប្រជុំគឺអ៊ីចឹង។ ទី១ គាត់ផ្សព្វផ្សាយពីរឿងកម្មាភិបាលចាស់ដែលគេត្រូវចាប់ខ្លួនហ្នឹង គឺគាត់ថាសុទ្ធតែជាអ្នកក្បត់អង្គការ ក្បត់បដិវត្តន៍ ឲ្យប្រជាពលរដ្ឋហ្នឹង តាមមូលដ្ឋានហ្នឹង គឺគាត់ឲ្យថាចង់ឲ្យប្រជាពលរដ្ឋហ្នឹងហូបអីចុកហ្នឹងតាមចិត្តចង់អីទៅ ដាំទៅហូបទៅ។ ក៏ប៉ុន្តែការពិត គាត់មកហ្នឹង គាត់គ្រាន់តែមកបោកប្រាស់ប្រជាជននៅកន្លែងហ្នឹង ថាពីណា មេកងណាដែលមិនឲ្យប្រជាពលរដ្ឋគាស់របស់ហ្នឹងស្ងោរហូប ដូចជាចេកដូចជាដំឡូងអីហ្នឹង ឲ្យរាយការណ៍ប្រាប់គាត់។ ដល់ហើយ ដល់ពេលប្រជាពលរដ្ឋគាត់មិននឹកស្មានថាគាត់មកនិយាយហ្នឹង ប្រជាពលរដ្ឋគាត់អរ គាត់អរថា អ្វីរបស់ដែលយើងខំដាំហើយ គេមិនឲ្យគាស់ហូប ឥឡូវគាត់មកប្រកាសថាឲ្យយើងគាស់ហូប ឲ្យក្នុងរោងបាយអីឲ្យបានបបរអីខាប់អ៊ីចឹងទៅ កុំឲ្យរាវអ៊ីចឹងទៅ។ ប្រជាជនហ្នឹងក៏គាត់មានការត្រេកអរ រហូតដល់មានប្រជាជនខ្លះគាត់ – អ៊ំគាត់ប្រកាសថាអ៊ីចេះ គាត់ថា “បើមេកងណា ប្រធានរោងបាយណា បបរវាវ ឲ្យស៊ីមិនគ្រប់គ្រាន់ ឲ្យទៅប្តឹងគាត់”។ ហើយក្រោយពីចប់មីទ្ទិងហ្នឹងទៅ មានប្រជាជនបីនាក់គាត់ឡើងទៅតវ៉ាដល់កន្លែងស្រុកហ្នឹង កន្លែងកាន នៅហ្នឹង នៅពាមជីកងហ្នឹង។ ក្រោយពីគាត់ទៅរាយការណ៍ថា អ៊ូ! ប្រធានកងភូមិនេះ មិនឲ្យគាស់ទេអារឿងដំឡូង រឿងអីចេកហ្នឹង មិនឲ្យកាប់ទេ ទុកដាក់កន្លែងរួម។ អ៊ីចឹងទៅគាត់ទៅរាយការណ៍ថា

ភូមិនេះៗអ៊ីចឹងទៅ។ បន្ទាប់ពីគាត់វាយការណ៍ ពេលគាត់ទៅហ្នឹងប្រហែលជាម៉ោងៗប្រាំបួនៗ ហើយគាត់ត្រឡប់មកផ្ទះវិញប្រហែលជាម៉ោងដប់កន្លះ ទៅម៉ោងដប់មួយហ្នឹង។ គ្រាន់តែគាត់មកដល់ផ្ទះវិញហ្នឹង រទេះសេះហ្នឹងទៅតាមចាប់គាត់យកមកក្នុងវត្តអូរត្រកួនហ្នឹង។ អាហ្នឹងយុទ្ធសាស្ត្រ អាន ហ្នឹងដែលគេទៅប្រជុំហ្នឹង គឺមានប៉ុណ្ណឹងបាទ។

[១០:១០:៥០]

**សៈ** សូមអរគុណ។ ខ្ញុំចង់សាកសួរអំពីទីកន្លែងនៃកិច្ចប្រជុំទាំងនេះ។ លោកបានឆ្លើយថាកិច្ចប្រជុំនោះ គឺធ្វើឡើងនៅវត្តអូរត្រកួន។ ខ្ញុំសូមអានកិច្ចសម្ភាសន៍ស្តាប់ចម្លើយ សម្រង់មួយ ពីបុគ្គលម្នាក់ដែលបាន ថាជាប្រធានកងឈ្លបពាមជីកងគឺ TCW-883 កិច្ចសម្ភាសន៍គឺ E3/9346 ERN ជាភាសាខ្មែរ 00235016, អង់គ្លេស 00235508, បារាំង 00283948។ គាត់បានរៀបរាប់អំពីកិច្ចប្រជុំមួយដែលក្រោមអធិបតីភាពរបស់លេខាតំបន់ថ្មីនោះ៖ "ដើមឆ្នាំ១៩៧៧ ពួកគេរៀបចំកិច្ចប្រជុំនៅស្ពានពាម គណៈកម្មាធិការ លេខាស្រុកនិង -- លេខាៗតំបន់ លេខាស្រុកគឺបានកោះប្រជុំ និងឲ្យអ្នកទាំងអស់ធ្វើការឲ្យខ្លាំងសម្រាប់អង្គការ ហើយនិងស្វែងរកខ្មាំងនៅក្នុងចំណោមប្រជាជន។ ក្រោយកិច្ចប្រជុំនេះការចាប់ខ្លួនគឺថាកាន់តែកើនឡើងៗទាំងយប់ទាំងថ្ងៃ។" សាក្សីរូបនេះបានរៀបរាប់ថា កិច្ចប្រជុំនេះធ្វើឡើងនៅស្ពានពាម។ សូមលោកជម្រាបតុលាការមើល ថាតើស្ពានពាមនេះ នៅទីកន្លែងណាដែរ ហើយជាអ្វីដែរ?

**ឆៈ** បាទ ខ្ញុំសូមជម្រាបដល់អង្គតុលាការថា នៅស្ពានពាមជីកងនេះ វាមានទីតាំងនៅទល់នឹងសាលាបឋមសិក្សាពាមជីកង។ ដូច្នេះអាក្នុងការគេប្រជុំអីរឿងនៅស្ពានអី ខ្ញុំអត់បានដឹង អត់បានអីទេ ខ្ញុំបានដឹងនេះ ខ្ញុំបានដឹងនៅក្នុងវត្តអូរត្រកួន ព្រោះសម័យហ្នឹង យើងអត់អាចឆ្លងកាត់ ពីកន្លែងមួយទៅកន្លែងមួយបានទេ។ គឺយើងនៅត្រង់ណា នៅត្រង់ហ្នឹងហើយ អត់មានទៅឆ្លងទៅពាមជីកងទៅណា ខ្ញុំនៅសំបួរមាសហ្នឹង គឺនៅតែសំបួរមាសហ្នឹង។ អត់ដែលទាំងបាន សូម្បីតែបងប្អូននៅក្នុងឃុំពាមជីកងដូចគ្នា ត្រឹមដំណាក់ជ្រៃហ្នឹង ក៏អត់មានការទំនាក់ទំនងអី នេះគ្នា ដូចសព្វថ្ងៃនេះ គឺខាងមនោសញ្ចេតនាបងប្អូនហ្នឹង ដូចថាវាដាច់អស់ទៅ មួយឆ្នាំ មិនទាន់ជួបគ្នាម្តងផងបាទ។ ហើយនៅក្នុងនៅកន្លែងស្ពានហ្នឹង ខ្ញុំអត់បានដឹងទេ ហើយការដែលគេប្រជុំរឿងចាប់ខ្លួនហ្នឹង គេមិនមែនឲ្យប្រជាជនយើងទៅស្តាប់ទេ អាហ្នឹងគេនិយាយតែក្រុមគេកម្មាភិបាលគេអីហ្នឹង ថ្នាក់ដឹកនាំអីគេហ្នឹងទេ គេមិនដែលមកផ្សព្វផ្សាយប្រាប់ប្រជាជនយើងហ្នឹងទេ។ អាហ្នឹង ខ្ញុំសូមជម្រាបតុលាការអ៊ីចឹង។

[១០:១៤:១៣]

**ស៖** ដូច្នេះ កិច្ចប្រជុំនៅវត្តអូរត្រកួនគឺ អាន ដែលជាអ្នកលេខាតំបន់ ជាអ្នកឡើងនិយាយ។ តើលោកអាចជម្រាបជូនតុលាការបានទេថានេះ តើៗអូរត្រកួននេះជាកន្លែងមន្ទីរសន្តិសុខឬក៏អត់ទេ? ហើយតើមន្ទីរសន្តិសុខនេះ -- តើកិច្ចប្រជុំនៅក្នុងវត្តអូរត្រកួននេះ ប្រជុំឲ្យចំតែម្តង គឺៗនៅកន្លែងណានៃវត្តអូរត្រកួនហ្នឹង?

**ឆ៖** បាទ ប្រជុំនៅវត្តអូរត្រកួននេះ គឺវាស្ថិតនៅក្នុងវត្តហ្នឹងតែម្តងបាទ គឺធ្វើនៅក្នុងវត្តហ្នឹងតែម្តង ខាងលិចវិហារសព្វថ្ងៃហ្នឹង គឺកន្លែងអីនុំងពីដើមវាមានដើមឈើច្រើនអ៊ីចឹងទៅណា ដើមទឹកដោះអីអ៊ីចឹងវាមានម្លប់ ហើយគេធ្វើបើកមីទ្ទិងហ្នឹងនៅខាងលិចវិហារហ្នឹងតែម្តង នៅក្នុងវត្តអូរត្រកួនហ្នឹង។

**ស៖** ឥឡូវនេះ ខ្ញុំសូមចូលទៅប្រធានបទថ្មីមួយទៀត លោកប្រធាន -- លោកចាំប្រធានកងឈ្លបនៅក្នុងស្រុករបស់លោកទេ?

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ដោយសារចូលទៅប្រធានបទថ្មី ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និង ឲ្យអញ្ជើញគាត់ត្រឡប់មកកន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងដប់កន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៦ នាទី ដល់ម៉ោង ១០:៣០ នាទី)*

[១០:៣០:៤៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយបន្តទៅនេះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

ផ្អាកសិនសហព្រះរាជអាជ្ញារងអន្តរជាតិ! សូមអញ្ជើញសហមេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ សម្រាប់សាក្សីរូបនេះ ខាងដើមបណ្តឹងរដ្ឋប្បវេណីសូមប្រគល់ជូនពេលវេលាជូនទៅខាងសហព្រះរាជអាជ្ញា យើងខ្ញុំត្រូវការរយៈពេលតិចតួចតែប៉ុណ្ណោះសម្រាប់សួរសាក្សីរូបនេះ។ ដូច្នេះ ពេលវេលាច្រើនជូនទៅខាងសហព្រះរាជអាជ្ញា។ យើងត្រូវការប្រហែលជា៥នាទី ទៅ១០នាទីតែប៉ុណ្ណោះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ សូមអរគុណដែលបានផ្តល់ព័ត៌មាននេះ។ សហព្រះរាជអាជ្ញាជ្រាបហើយ។

សូមអញ្ជើញបាទ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន សូមអរគុណលោកមេធាវី។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ខ្ញុំនឹងសាកសួរលោកអំពីក្រុមមួយដែលគេហៅថា "ក្រុមដាវវែង"។ តើលោកចាំទេថាមានឈ្លបមួយដែលឈ្មោះបែបនេះទេ? ហើយលោកអាចប្រាប់បានទេ ថាតើគេបង្កើតក្រុមឈ្លបដាវវែងហ្នឹងនៅពេលណាដែរ?

[១០:៣២:២៨]

**លោក សេង ស៊្រុន៖**

**ឆ៖** បាទ ក្រុមដាវវែងហ្នឹងគេចាប់ផ្តើមបង្កើតនៅឆ្នាំ១៩៧៧ ប្រហែលជាដើមឆ្នាំហ្នឹងក៏មិនដឹងទៅមុខទៀតក៏មិនដឹង ប៉ុន្តែក្នុងឆ្នាំ៧៧ហ្នឹង ប្រហែលជាអាចចុងឆ្នាំ៧៦ ហើយនិងដើមឆ្នាំ៧៧ហ្នឹង។

**ស៖** តើលោកអាចពន្យល់បានទេថា កងដាវវែងហ្នឹងធ្វើអី? ហើយកងដាវវែងហ្នឹងមានមុខងារអ្វីដែរ? ហើយតើកងហ្នឹងវាខុសពីឈ្លបឃុំហ្នឹង ខុសគ្នារបៀបណាដែរ?

**ឆ៖** ខ្ញុំសូមជម្រាបថាក្រុមដាវវែងនេះ គេរៀបចំឡើងវាខុសពីឈ្លប។ ក្រុមដាវវែងនេះគេ កាល

ណាដល់មានអន្តរាគមន៍ចុះចាប់ប្រជាជន ដូចជាប្រជាពលរដ្ឋដែលជាប្រជាជនថ្មី ឬក៏ប្រជាជននៅក្នុងចល័តហ្នឹង គឺគេប្រើពួកដារវែងហ្នឹងឱ្យចុះទៅចាប់។ ពួកដារវែងទៅចាប់ហើយ គឺមិនមែនចាប់មួយពីរទេ គឺតែពួកហ្នឹងចុះទៅ គឺគេចាប់ច្រើនៗតែម្ដង ១០នាក់, ២០នាក់អីទៅ។ ប្រាំនាក់ឡើងទៅគឺគេឱ្យពួកក្រុមដារវែងហ្នឹងចុះទៅចាប់ហើយ។ តាមឃុំក៏អ៊ីចឹងដែរ បើមានពួកដារវែងហ្នឹងចុះទៅ ប្រជាជនគាត់សូម្បីតែធ្វើការនឿយហត់យ៉ាងម៉េច ក៏គាត់ពេលហូបហ្នឹងក៏គាត់អត់ឃ្លានទេ ឱ្យតែឃើញពួកដារវែងហ្នឹងចូលទៅ គឺគាត់លែងឃ្លានបាយតែម្ដង។ ពួកដារវែងគឺអ៊ីចឹង ឱ្យតែចុះទៅត្រង់ណា គឺហេតុការណ៍កើតឡើងនៅកន្លែងនុ៎ង។ អាហ្នឹងសូមជម្រាបពីក្រុមដារវែងដែលគេបង្កើតឡើង គឺតួនាទីគេ គឺអ៊ីចឹង។

[១០:៣៤:៣២]

**ស៖** តើពួកក្រុមដារវែងចាប់ខ្លួន ហើយនាំមនុស្សយកមកវត្តអូរត្រកួនមែនទេ?

**ឆ៖** បាទ ពួកក្រុមដារវែងហ្នឹង កាលណាគេចាប់គឺគេនាំខ្លួនមកចូលវត្តអូរត្រកួនហ្នឹងហើយ។

**ស៖** តើលោកមានបងប្អូនថ្លៃម្នាក់ដែលជាប្រធានពួកក្រុមដារវែងហ្នឹងដែរឬទេ?

**ឆ៖** បាទ ខ្ញុំមានបងថ្លៃម្នាក់គាត់ជាប្រធានក្រុមដារវែង ក៏ប៉ុន្តែកាលនុ៎ងគាត់មិនទាន់ក្លាយជាបងថ្លៃខ្ញុំទេ គឺតែចប់ហើយទេបានក្លាយជាបងថ្លៃខ្ញុំ។ កាលពីសម័យនោះ ខ្ញុំអត់មានការទំនាក់ទំនង អីទេ។

**ស៖** មុននេះបន្តិច ក៏លោកបាននិយាយអំពីមិត្តភក្តិរបស់លោកឈ្មោះ មឿន ដែល មឿន ហ្នឹងគាត់ធ្វើការដូចលោកដែរ គឺអ្នកឡើងត្នោត ហើយពេលខ្លះគាត់ធ្វើការជាសន្តិសុខផងដែរ។ ខ្ញុំចង់សួរថាតើនៅពេលនោះ នៅក្នុងរបបនោះ មឿន ក៏គាត់ជាសមាជិករបស់ក្រុមដារវែងដែរមែនទេ?

**ឆ៖** មឿន ហ្នឹងគាត់មិនមែនជាក្រុមសន្តិសុខដារវែងទេ។ ការពិតទៅ គាត់ជាក្រុមសន្តិសុខរស់នៅក្នុងវត្តអូរត្រកួនហ្នឹង ក៏ប៉ុន្តែគេចាត់គាត់ហ្នឹង ឱ្យឡើងត្នោត។

**ស៖** ដើម្បីបញ្ជាក់ឱ្យច្បាស់ ដូច្នេះអ៊ីចឹង មឿន ហ្នឹងគាត់ធ្វើការជាសន្តិសុខហ្នឹង គឺគាត់ធ្វើការជាសន្តិសុខនៅវត្តអូរត្រកួន។ តើខ្ញុំយល់អ៊ីចឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ខ្ញុំថាត្រឹមត្រូវហើយ ព្រោះគាត់នៅក្នុងវត្តអូរត្រកួននេះ គាត់មិនមែនជាសន្តិសុខដើរចាប់មនុស្សទេបាទ។

[១០:៣៧:១៨]

**ស៖** ឥឡូវនេះ ខ្ញុំចង់និយាយអំពីប្រធានបទទាក់ទងទៅនឹងហេតុការណ៍កើតឡើងចំពោះជនជាតិ

ចាមនៅក្នុងតំបន់របស់លោក ក្រោយពេលដែលពួកកម្មាភិបាលនិរតីចូលមកដល់។ ដូច្នេះ ខ្ញុំចង់សួរលោកថា នៅពេលដែលកម្មាភិបាលនិរតីមកដល់នោះ តើកងរបស់លោកហ្នឹង មានទទួលការបញ្ជា ឲ្យរៀបចំបញ្ជីឈ្មោះជនជាតិចាមនៅក្នុងកងរបស់លោកហ្នឹងដែរឬទេ?

**ឆ៖** នៅក្នុងពេលដែលគេចាប់បងប្អូនជនជាតិចាមហ្នឹង ខ្ញុំអត់ដែលបានឃើញបញ្ជីអីទេ ព្រោះខ្ញុំអត់មានទាក់ទងអីអារឿងបញ្ជីឈ្មោះ ការចាប់ចាមហ្នឹង ក៏ខ្ញុំអត់បានដឹងដែរ ក៏ប៉ុន្តែនៅពេលគេចាប់ហ្នឹង គឺខាងក្រុមខ្ញុំឡើងត្នោតហ្នឹង វាមានគ្នាប្អូននាក់ហ្នឹង ហូបបាយរួចល្ងាចម៉ោងប្រាំមួយហើយ បានគេប្រាប់ថា ឲ្យទៅតាមពួកដាវវែងហ្នឹង។ ប៉ុន្តែទៅហ្នឹង ក៏អត់ដឹងទៅណាច្បាស់លាស់ដែរ គេហៅទៅ ទៅតាមគេទៅ គេអត់ប្រាប់ថា ទៅចាប់បងប្អូនចាមអីក៏គេអត់បាននិយាយផងហ្នឹង។

**ស៖** សូមអរគុណ។ ខ្ញុំនឹងនិយាយអំពីហេតុការណ៍នេះ នៅពេលបន្តិចទៀតនេះ ប៉ុន្តែឥឡូវនេះខ្ញុំចង់សួរលោក គឺថាមុនពេលដែលគេចាប់ខ្លួនជនជាតិចាមនៅថ្ងៃនោះ លោកបាននិយាយអំពីមនុស្សម្នាក់ឈ្មោះ ណូយ ដែលជាមេកងចល័តរបស់លោក។ តើលោកចាំទេ ថាតើ ណូយ មានបានទទួលបញ្ជា ឲ្យរៀបចំបញ្ជីឈ្មោះជនជាតិចាមនៅក្នុងកងរបស់លោកដែរឬទេ?

[១០:៣៩:២២]

**ឆ៖** បាទ នៅក្នុងកងចល័តហ្នឹង គឺគេរៀបចំស្រេចហើយ គេដឹងថា អ្នកណាចាម អ្នកណាខ្មែរ ប៉ុន្តែគេមិនដែលបង្ហាញឲ្យយើងឃើញទេ។ គឺគេធ្វើអីសុទ្ធតែគេលាក់ការណ៍ទាំងអស់ ការណ៍ស្ងីសំខាន់ៗ គឺខ្ញុំអត់ដែលបានដឹងទេ ប្រជាពលរដ្ឋទាំងអស់ក៏គាត់មិនបានដឹងដែរ ស្រេចតែនៅលើគេ ប៉ុន្តែ គ្រាន់ថានៅក្នុងកងចល័តអ៊ីចឹងទៅ គេមានចុះចំនួនបងប្អូនចាមប៉ុន្មាននាក់អីអ៊ីចឹងទៅ ខ្មែរប៉ុន្មាននាក់ទៅ ព្រោះចល័តហ្នឹង បងប្អូនចាម និងបងប្អូនខ្មែរហ្នឹង គឺនៅជាមួយគ្នាទាំងអស់។

**ស៖** តើលោកអាចប្រាប់បានទេថា តើគេធ្វើយ៉ាងណាដើម្បីឲ្យដឹងថាអ្នកណាខ្លះជាខ្មែរ អ្នកណាជាចាម? ថាតើគេដឹងដោយសារតែការស្លៀកពាក់ជាសម្លៀកបំពាក់ចាម ឬក៏ដោយសារតែភាសានិយាយ ឬក៏របៀបនិយាយ? ដូច្នេះតើលោកអាចប្រាប់បានទេ ថាតើគេធ្វើយ៉ាងណាទើបអាចដឹងថាអ្នកណាម្នាក់ជាជនជាតិចាមនោះ?

**ឆ៖** នៅក្នុងការសម្គាល់ហ្នឹង វាមិនជាមានការពិបាកអីទេ ព្រោះថាបងប្អូនចាមដែលរស់នៅក្នុងភូមិសាច់ស្ងហ្នឹង គេដូចកម្មាភិបាលជំនាន់ខ្មែរយើងហ្នឹង ជំនាន់ខ្មែរក្រហមហ្នឹង គេដឹងថាអ្នកនេះចាម អ្នកនេះខ្មែរ គេស្គាល់ច្បាស់ ព្រោះនៅជិតខាងគ្នា។ ហើយមួយទៀតការនិយាយភាសាហ្នឹង ក៏ខុស

គ្នា ហើយបងប្អូនចាម កាលណាគាត់និយាយឡើងក៏មិនច្បាស់ដូចខ្មែរយើងដែរ គាត់និយាយរៀងប៉ៃឡាំអីចឹងទៅ។ ហើយអានេះវាមិនមែនជាកំណត់សម្គាល់ទេ កំណត់សម្គាល់គឺថា គេស្គាល់គាត់ថាជនជាតិចាមហ្នឹងតែម្តង ព្រោះនៅត្រង់នុំង ខ្មែរ និងចាមវាបែងចែកច្បាស់លាស់ណាស់។ អត់ចាំបាច់ទៅចំណាំអីទេ អត់ចាំបាច់ទៅមានការថា អ្នកណាចាម គេចំណាំម៉េច ខ្មែរចំណាំម៉េច គឺអត់ចាំបាច់នេះ ព្រោះគេស្គាល់ច្បាស់អស់ហើយចាមនៅក្នុងឃុំមួយៗគេស្គាល់។

[១០:៤១:៥៧]

**ស៖** ចំពោះ ណូយ ដែលជាមេកងរបស់លោកហ្នឹង តើគាត់ធ្លាប់បង្ហាញលិខិតរបស់លោកមួយដែលលិខិតហ្នឹង បង្គាប់ឱ្យគាត់ប្រមូលផ្តុំចងក្រងឈ្មោះជនជាតិចាមដែរឬទេ? តើលោកធ្លាប់ឃើញលិខិតនេះដែរឬទេ?

**ឆ៖** ចំពោះ ណូយ គាត់ជាមេកងហ្នឹង គាត់ធ្លាប់បាននេះដែរ ព្រោះគាត់ ព្រោះខ្ញុំនិងគាត់ហ្នឹងវាមនុស្សជិតស្និទ្ធដែរ នៅភូមិជាមួយគ្នា។ គាត់ ប៉ុន្តែគាត់គ្រាន់បង្ហាញថា នេះឈ្មោះបងប្អូនចាម តែគាត់អត់បាននិយាយថា ពីរឿងចាមហ្នឹងគេយកទៅធ្វើម៉េចៗ គឺអត់ដែលបាននិយាយផង គ្រាន់ថាចាមហ្នឹងគេសម្រង់ឈ្មោះម្តុំហ្នឹងទៅ ខ្មែរហ្នឹងគេដាក់ដោយខ្លួនទៅ។ អាហ្នឹងមាន។

**ស៖** តើ ណូយ ធ្លាប់ប្រាប់លោកទេថា អ្នកណាជាបញ្ជាគាត់ឱ្យរៀបចំឱ្យស្រង់បញ្ជីហ្នឹងទេ?

**ឆ៖** ណូយ ហ្នឹងគាត់បញ្ជាពីគេហៅថៅ ប្រធានសង្កាត់ កាលនោះគេហៅប្រធានសង្កាត់ គេមិនមែនហៅថៅសង្កាត់ទេ គេហៅប្រធានសង្កាត់។ ដូច្នេះកាលណានេះទៅ គេអង្កាល់នោះ យើងវាគ្មានទំនាក់ទំនងអីតាមបណ្តាញទូរស័ព្ទតាមអីទេ គឺតាមនីរសារគេ។ ឧទាហរណ៍ថា បើសិនជាគេមានការអីចង់ទាក់ទងទៅប្រធានកងតាមមុខព្រួញហ្នឹងទៅ គេសរសេរសំបុត្រទៅ ហើយយើងធ្វើតាមទៅ វាអត់មានត្រូវទាក់ទងគ្នាដូចសព្វថ្ងៃទេបាទ គឺមាននីរសារគេ។

[១០:៤៤:០៣]

**ស៖** ឥឡូវនេះខ្ញុំនឹងនិយាយពីពេលវេលាដែលមុននេះលោកនិយាយបន្តិចនេះ គឺនៅពេលដែលគេឱ្យលោកតាមក្រុមដាវរែងនោះ។ ដូច្នេះទី១ ខ្ញុំចង់សួរលោកថា តើពេលនុំង នៅពេលនុំង គឺលោកនិយាយថា លោកបានឃើញបញ្ជីឈ្មោះមនុស្សដែលមេកងចល័តរបស់លោកបានស្រង់ ហើយបញ្ជីឈ្មោះនុំងស្រង់ឈ្មោះចាម។ ដូច្នេះខ្ញុំចង់ដឹងថា តើប៉ុន្មានថ្ងៃ ប៉ុន្មានខែក្រោយពេលដែលលោកឃើញលិខិតហ្នឹង គេចាត់តាំងលោកឱ្យតាមពួកក្រុមដាវរែង ទៅចាប់ខ្លួនជនជាតិចាមហ្នឹង? តើក្រោយគ្នាប្រហែលប៉ុន្មានថ្ងៃ

ប៉ុន្មានខែដែរ?

**ឆ៖** ការស្រង់ឈ្មោះនោះ គឺខ្ញុំនៅក្នុងការដ្ឋាននៅឡើយទេ ដែលគេនេះនុំង តែដល់ពេលមកចាប់បងប្អូនចាមហ្នឹង គឺវាមានរយៈពេលយូរហើយ ប្រហែលជាបីបួនខែ គេឲ្យខ្ញុំវិលត្រឡប់មកភូមិវិញ បានគេចាប់បងប្អូនចាមហ្នឹង។ តែគេស្រង់ហ្នឹង គេស្រង់តាំងពីនៅការដ្ឋានម្ល៉េះ។

**ស៖** តើលោកចាំទេ នៅថ្ងៃដែលគេចាត់តាំងឲ្យលោកទៅតាមកងដាវវែង ដើម្បីចាប់មនុស្សនោះ តើលោកចាំទេថាតើប្រហែលជានៅក្នុងខែអ្វី នៅក្នុងឆ្នាំអីដែរ លោកចាំទេ?

**ឆ៖** កាលដែលគេឲ្យខ្ញុំទៅតាមកងដាវវែងហ្នឹង ខ្ញុំអត់ដឹងខែទេ ដូចខ្ញុំបានជម្រាបអ៊ីចឹង ថាសម័យហ្នឹងគឺអត់ដឹងថាខែណាៗទេ ព្រោះយើងអត់មានធ្វើការអី ក៏ បើដូចសព្វថ្ងៃយើងធ្វើការយើងដឹងរដូវធ្វើការ។ ពេលហ្នឹងយើងការងារអី គឺស្រេចតែគេប្រើៗឲ្យធ្វើអីធ្វើហ្នឹង។ ប៉ុន្តែការចាប់ចាមហ្នឹង គឺនៅក្នុងឆ្នាំ១៩៧៧ ប៉ុន្តែនៅក្នុងខែណា ខ្ញុំមិនអាចកំណត់បានទេ។

**ស៖** តើលោកចាំទេថា ជារដូវប្រាំង ឬក៏រដូវវស្សា?

**ឆ៖** កាលនោះបើតាមខ្ញុំចាំ ព្រោះខ្ញុំនៅឡើងត្នោតនៅឡើយ វាប្រហែលជានៅក្នុងខែ៣ ខែ៤អីហ្នឹង ខែ៣ ខែ៤ហ្នឹង ព្រោះត្នោតតាមនេះវា តែខែ៥ខែអីហ្នឹង ឈប់ឡើងហើយ ពីខែ២ ខែ៣ ខែ៤ហ្នឹង ៣ខែហ្នឹង គឺយើងឡើយជាប់។ នេះតាមការចំណាំទេ មិនដឹងជាខែអីឲ្យប្រាកដទេ។

[១០:៤៧:២៤]

**ស៖** តើលោកអាចជម្រាបតុលាការបានទេថា មានអ្វីកើតឡើងនៅពេលដែលគេចាត់តាំងឲ្យលោកទៅតាមក្រុមដាវវែងនុំង តើមានអីកើតឡើង?

**ឆ៖** នៅក្នុងពេលដែលគេឲ្យខ្ញុំទៅហ្នឹង គេអត់បានប្រាប់ថាឲ្យយើងទៅធ្វើស្អីទេ។ គេគ្រាន់តែថា ពួកឡើងត្នោតទៅទាំងអស់គ្នា ប៉ុន្តែថាទៅហ្នឹង ខាងខ្ញុំហ្នឹងទៅម្នាក់ឯងអ៊ីចឹងទៅ ចេញក្រោយក្បែរខ្លោងធ្វើវត្តនៅផ្លូវជិតមាត់ទន្លេឯណោះ។ ហើយបីនាក់ទៀតហ្នឹង មិនដឹងគេឲ្យទៅណា ព្រោះការចាប់បងប្អូនចាមហ្នឹងគឺគេធ្វើមួយយប់ហ្នឹង គឺគេចាប់ទាំងអស់ហ្នឹងតែម្តង។ ដូច្នេះបែងចែកហ្នឹង ខុសៗគ្នា។ រួចដល់ខ្ញុំ គេនាំខ្ញុំទៅដល់ថ្នល់ ជិតថ្នល់ហ្នឹង ស្រាប់តែខ្ញុំឃើញគេចាប់បងប្អូនចាមហ្នឹង គាត់ខ្លះ បើពីនារីគាត់នៅចោមពុងចោមអី ងូតទឹកឲ្យកូនអីអ៊ីចឹងណា។ ស្រាប់តែគេចាប់ទាញប្រទង់ មកយកមកផ្លូវខ្លោងធ្វើវត្តហ្នឹង។ គេឲ្យខ្ញុំអ្នកមើល គេថាមិត្តឯងមើលបងប្អូនចាមហ្នឹង រួមគេអ្នកដើរចាប់ គេយកមកនឹងផ្លូវហ្នឹង គេឲ្យខ្ញុំអ្នកមើល។ ហើយគេប្រាប់ថា បើបងប្អូនចាមរត់រួច មិត្តឯងក៏មិនរស់ដែរ។ ហើយខ្ញុំទៅជា

វាថា ដូចថាមានការស្រឡាំងកាំងរន្ធត់ ដោយវាអត់បានដឹងពីព្រឹត្តិការណ៍យ៉ាងម៉េចៗ ស្រាប់ដល់រួចទៅគេចាប់ព្រួសៗមកអ៊ីចឹង ខ្លះទៅគាត់ អានេះខ្ញុំឃើញជាក់ស្ដែងនឹងភ្នែក ខ្លះទៅកំពុងតែសើចប្រឡែងលេងជាមួយកូនអីអ៊ីចឹងទៅ ស្រាប់តែទៅទាត់គ្នា ធាក់ពីលើផ្ទះអីមកអ៊ីចឹង អូសមក។ អូសមក មកដាក់មួយជួរតាមផ្លូវហ្នឹងទៅ ឲ្យតម្រង់ជួរគ្នាអ៊ីចឹងទៅ។ រួចគេចេះតែដើរចាប់បន្តៗមក ខ្ញុំហ្នឹងគេឲ្យនៅមើលៗ ប៉ុន្តែបងប្អូនចាមហ្នឹង គេដាក់ទៅខាងជើង ខ្ញុំហ្នឹងគេឲ្យនៅខាងត្បូង នៅខាងថ្នល់ហ្នឹង ឲ្យឈរៗមើលហ្នឹង ជាមួយពួក កាលហ្នឹងដូចជាមានពួកសន្តិសុខហ្នឹងនៅជាមួយដែរ ពួកសន្តិសុខដាវវែងហ្នឹង រួមទាំងខ្ញុំនៅជាមួយដែរ។

**ស៖** តើនៅថ្ងៃហ្នឹង តើគេចាប់ជនជាតិចាមហ្នឹងប្រហែលជាប៉ុន្មាននាក់? ហើយថាតើគេចាប់ពួកជនជាតិចាមហ្នឹង ចាមមកពីភូមិណាដែរ?

[១០:៥០:១១]

**ឆ៖** នៅក្នុងឃុំពាមជីកងហ្នឹង វាបងប្អូនចាមមាននៅខាងសំបួរមាសខខ្លះ សំបួរមាស “ក”ខ្លះ ហើយនៅសាច់សូខ្លះ។ ក្នុងយុទ្ធនាការដែលគេចាប់បងប្អូនអ៊ីស្លាមហ្នឹង គឺគេធ្វើតែមួយល្ងាចហ្នឹង គឺគេចាប់ទាំងអស់តែម្ដង គេចាប់គ្រប់ភូមិទាំងអស់តែម្ដង។ អាកងឈ្លបដាវវែងហ្នឹង គេចែកគ្នាជាក្រុមៗអ៊ីចឹងទៅ ប៉ុន្មាននាក់ទៅភូមិណាៗ គេចែកតាមមុខព្រួញអ៊ីចឹងទៅ គឺថាមួយៗល្ងាចហ្នឹង គឺគេចាប់ទាំងអស់តែម្ដង ពីម៉ោងប្រហែលជាប្រាំមួយទៅហ្នឹង ម៉ោងប្រាំពីរប្រាំបី គឺចាប់អស់តែម្ដងបាទ។

**ស៖** តើជនជាតិចាមដែលគេចាប់ខ្លួនហ្នឹង មានទាំងក្មេងៗចាម ជនជាតិចាមដែរឬទេ?

**ឆ៖** បាទ ការចាប់ហ្នឹងគឺចាប់ទាំងអស់តែម្ដង ក្មេងប៉ុនណាក៏ចាប់ដែរ ក៏ប៉ុន្តែដូចខ្ញុំបានជម្រាបថា គេស្រង់ឈ្មោះនៅការដ្ឋានហ្នឹង បងប្អូនៗចាមដែលទៅចល័តហ្នឹង អាហ្នឹងគេចាប់ពីកន្លែងគេហ្នឹងមកតែម្ដង។ បើបងប្អូនប្រជាពលរដ្ឋចាម ដែលរស់នៅតាមភូមិមួយៗហ្នឹង គឺពួកខាងដាវវែងហ្នឹងគេៗចាប់ៗមកទាំងអស់តែម្ដង។ តាមការដ្ឋាននោះ គេចាប់ផ្សេងមកទៀត អាហ្នឹងគេដឹករទេះសេះមក ក្នុងពេលតែមួយហ្នឹង ថ្ងៃតែមួយហ្នឹង ខែឆ្នាំតែមួយហ្នឹង។

**ស៖** លោកបាននិយាយថា ការចាប់ខ្លួនហ្នឹង គឺរួមបញ្ចូលទាំងការចាប់ក្មេងៗចាមផងដែរ។ ដូច្នេះ ខ្ញុំចង់ដឹងថាតើលោកឃើញថាក្មេងៗចាមដែលគេចាប់ហ្នឹង ក្មេងៗដែលក្មេងបំផុតហ្នឹង មានអាយុប្រហែលប៉ុន្មានដែរ លោកចាំទេ?

[១០:៥២:២១]

**ឆ៖** អាក្មេងហ្នឹង តាមនេះទៅ តាមខ្ញុំមើលទៅ ឧទាហរណ៍ថា មួយគ្រួសារហ្នឹងវាមានប្រាំនាក់ ដល់គេចាប់ឪពុកម្ដាយមកហើយ គឺក្មេងហ្នឹងដើរតាមឪពុកម្ដាយទាំងអស់ទៅ អត់មានទៅណា គេហៅទៅទាំងអស់មួយគ្រួសារៗហ្នឹងគឺទៅទាំងអស់ ទាំងតូចទាំងធំតែម្ដង។ ប៉ុន្តែគេសង្កត់ធ្ងន់ គេការពារតែឪពុក និងម្ដាយទេ ឲ្យតែគាត់ គេប្រិតប្រៀងខ្លាំងគឺឪពុក ព្រោះឪពុកវាប្រុស ដល់ម្ដាយគាត់មិនអាចមានថា កម្លាំងអីទៅតទល់ជាមួយគេទេ។ គេហៅទៅទាំងអស់ៗ ក្មេងហ្នឹងចេះតែដើរតាមឪពុកម្ដាយអ៊ីចឹងទៅ។

**ស៖** តើលោកអាចប្រាប់បានទេថា ជាសរុបទៅ តើគេប្រមូលផ្ដុំជនជាតិចាមប្រហែលជាប៉ុន្មាននាក់ដែរនៅពេលនោះ?

**ឆ៖** បងប្អូនជនជាតិចាមមួយពេលហ្នឹង បើតាមការ នេះជាការប៉ាន់ស្មានទេ ខ្ញុំអត់ដឹងតួលេខច្បាស់ទេ ប៉ុន្តែខ្ញុំគ្រាន់តែបូកសរុបតាមភូមិមួយៗទៅ បងប្អូនចាមប្រហែលជា៤០០ ទៅ៥០០នាក់។

**ស៖** នៅក្នុងកិច្ចសម្ភាសន៍ជាមួយ ក.ស.ច.ស លោកបានផ្ដល់តួលេខ ថាមានៗជនជាតិចាម ៣០០។ តើលោកច្បាស់ទេថា ជនជាតិចាមដែលគេចាប់ខ្លួន ដែលគេប្រមូលផ្ដុំហ្នឹងមានប្រហែលជាបួនប្រាំរយនាក់ ឬមួយក៏មានត្រឹមតែ៣០០នាក់ទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំចាំថា លោកសាក្សីគាត់បាននិយាយថា ប្រហែលជា២០០នោះទេ មិនមែន៣០០នោះទេ។

[១០:៥៤:៥០]

**លោក ឌេល លីសាក់៖**

ប្រហែលជាខ្ញុំសូមអាននូវសម្រង់ដែលសាក្សីបានឆ្លើយរួចមកហើយនោះ គឺឯកសារ E3/5252 ខ្មែរមានលេខ 00235021, អង់គ្លេសមានលេខ 00235517 និងបារាំងមានលេខ 00269892។ ខ្ញុំសូមដកស្រង់៖ “គេប្រមូលផ្ដុំចាម៣០០នាក់ ទាំងក្មេង ទាំងចាស់ ហើយឲ្យពួកគេនៅតាមផ្លូវនៅខាងមុខច្រកទ្វារវត្ត។ នៅពេលនោះ គេចាត់តាំងមនុស្សពីរនាក់ពីក្រុមខ្ញុំដែលមានគ្នាបួននាក់ ដើម្បីឲ្យយាមនៅចុងខាងត្បូង។”

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាត គឺថាឯកសារដែលនិយាយគឺ E3/5302 គឺអង់គ្លេសមានលេខ 00210488, បារាំងមានលេខ 00623191, ខ្មែរមានលេខ 00635176។ "គេឱ្យខ្ញុំដឹកនាំប្រជាជនចាមប្រហែលជា២០០ ទៅ៣០០នាក់ ដើម្បីយកទៅសម្លាប់"។ សូមបញ្ចប់ការដកស្រង់។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកមេធាវី។ ឥឡូវនេះ ខ្ញុំនឹងសួរទៅដល់សាក្សីវិញ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី នៅក្នុងចម្លើយរបស់លោកនាពេលកន្លងមក លោកនិយាយថា ប្រហែលជាមានជនជាតិចាម២០០ ទៅ៣០០នាក់ ប៉ុន្តែថ្ងៃនេះ លោកនិយាយថា មានប្រហែលជា៤០០ ទៅ៥០០នាក់។ ដោយសារតែយើងដឹងថា លោកគ្រាន់តែធ្វើការប៉ាន់ប្រមាណ ដូច្នេះតាមដែលលោកចាំច្បាស់នោះ តើលោកអាចបញ្ជាក់ឱ្យបានច្បាស់ទេ ថានៅយប់ហ្នឹង គេចាប់ជនជាតិចាមហ្នឹង ប្រហែលជាប៉ុន្មានរយនាក់ដែរ?

**លោក សេង ស៊្រុន៖**

**ឆ៖** បាទ ហ្នឹងដូចខ្ញុំបានបញ្ជាក់ហើយថា ពីរបីរយនាក់ហ្នឹង អាហ្នឹងវានៅតាមភូមិ ក៏ប៉ុន្តែវាបូករួមនឹងបងប្អូនចាមដែរនៅចល័តទៀត វាអាចដល់៤០០ ឬ៥០០នាក់ ព្រោះអង្កាល់នុំង វាធម្មតាឪពុកម្ដាយ គឺរស់នៅដោយខ្លួនជាមួយនឹងក្មេងកុមារតូចៗ តែមនុស្សដែលពេញវ័យ គឺល្មមធ្វើការ គឺគេបានបញ្ជូនទៅការដ្ឋាន។ ដូច្នេះ ខ្ញុំនិយាយ៤០០ ទៅ៥០០នេះ ខ្ញុំនិយាយពីប្រជាពលរដ្ឋចាមសរុបនៅក្នុងឃុំពាមជីកងហ្នឹង។

[១០:៥៧:៤៣]

**ស៖** បាទ សូមអរគុណ ដែលបានបញ្ជាក់អំពីចំណុចនេះ។ តើលោកបានដឹងថា មានគេចាប់ចាមខ្លះដែរទេ នៅយប់នោះ?

**ឆ៖** នៅៗយប់នុំង គេខ្ញុំបញ្ជាក់ហើយថា ថ្ងៃនុំង គេចាប់ទាំងអស់ ប៉ុន្តែកាលដែលគេចាប់ហ្នឹង គឺគេចាប់មួយថ្ងៃហ្នឹង គឺអស់តែម្ដង ពីម៉ោងប្រាំមួយ ទៅដល់ម៉ោងប្រាំបីហ្នឹង គឺចាប់ទាំងអស់តែម្ដងបងប្អូនចាម នៅក្នុងតាមសហករណ៍ឃុំពាមជីកង។ បើខាងអង្គរបាន អង្គរអី ខ្ញុំអត់ដឹងទេអានុំង រឿងគេផ្សេង ប៉ុន្តែថានៅក្នុងឃុំពាមជីកង ព្រឹត្តិការណ៍ដែលកើតឡើងគឺខ្ញុំដឹង គឺខ្ញុំជម្រាបតែនៅក្នុងឃុំ

ពាមជីកង។

**ស៖** ប្រហែលជាដោយសារមានបញ្ហាបកប្រែហើយមើលទៅ។ ខ្ញុំសូមសួរបញ្ជាក់ឡើងវិញ។ លោកបានរស់នៅក្នុងតំបន់នោះ សំណួរខ្ញុំ ថាតើលោកមាននៅចាំប្រជាជនចាមដែលត្រូវបានគេប្រមូល ដាក់ម៉ុំ និងចាប់ខ្លួននៅយប់នោះទេ? លោកៗនៅចាំចាម ដែលត្រូវបានគេចាប់ខ្លួន ក្នុងចំណោមចាមដែល គេចាប់ខ្លួន លោកមានស្គាល់ចាមណាខ្លះទេ?

**ឆ៖** បាទ បងប្អូនចាមដែលត្រូវចាប់ខ្លួនហ្នឹង ខ្ញុំស្គាល់ច្រើនដែរ ស្គាល់ច្រើន ព្រោះធ្វើការជាមួយ គ្នា។ អង្កាល់ដែលពីមុន គេមិនទាន់ឲ្យខ្ញុំឡើងត្នោត គឺគេឲ្យខ្ញុំនេសាទត្រីជាមួយបងប្អូនចាមហ្នឹង។ ក្នុងទូកមួយបងប្អូនចាមពីរនាក់ ខ្ញុំខ្មែរហ្នឹងម្នាក់។ ដូច្នេះខ្ញុំអាចស្គាល់គាត់ច្រើនដែរ បងប្អូនចាមនុ៎ង ព្រោះ យើងធ្វើការជាមួយគ្នា។

[១០:៥៩:៤២]

**ស៖** លោកបានឆ្លើយថា ចាមត្រូវបានគេចាប់ខ្លួនដោយរបៀបណា ប្រមូលដាក់ម៉ុំដោយរបៀប ណា នៅជិតវត្តអូរត្រកួន នៅពេលដែលគេឲ្យលោកយាម ចាំយាមផ្លូវ។ តើគេៗយកចាមទាំងអស់នេះ យកទៅណា ហើយធ្វើអ្វីដែរ នៅពេលដែលគេប្រមូលដាក់នៅលើផ្លូវមួយក្បែរវត្តអូរត្រកួននោះ?

**ឆ៖** ដល់គេប្រមូលបងប្អូនចាមមកហើយ គេឲ្យខ្ញុំដើរពីក្រោយ អ្នកខ្លះដើរពីមុខ ប៉ុន្តែខ្ញុំនៅខាង ក្រោយទេ។ ហើយគេឲ្យបងប្អូនចាមហ្នឹង ដើរទៅក្នុងវត្តឡើងទៅក្នុងវិហារ។ ព្រឹត្តិការណ៍ដែលខ្ញុំឃើញ នឹងភ្នែក គឺបងប្អូនចាមគាត់ជាបុរស មុននឹងឡើងទៅលើវិហារហ្នឹង គេវ៉ៃគាត់ គេវ៉ៃគាត់មួយដែកៗហ្នឹង ដែកហ្នឹងប្រហែលជាធំជាងមេដៃបន្តិច។ គេវ៉ៃគាត់អ៊ីចឹងទៅ ដូចថា គេដើម្បីបំបាក់ស្មារតីកុំឲ្យគាត់មាន ការបះបោរនៅក្នុងវិហារអ៊ីចឹង តែបងប្អូនចាមស្រីៗហ្នឹង គេអត់មានវ៉ៃតប់អីទេ ហើយក្មេងតូចៗដែល គ្នាឡើងលើជណ្តើរហ្នឹងមិនរួចទៅ វា ពួកអាសន្តិសុខនៅក្នុងវត្តអូរត្រកួនហ្នឹង វារុញ វាច្រានទៅណ៎ា អាខ្លះទៅដួលយំពេញតែវិហារនុ៎ង ក្មេងៗតូចៗនុ៎ង។ អាហ្នឹងព្រឹត្តិការណ៍ដែលទៅដល់វិហារហ្នឹង ខ្ញុំ ឃើញអ៊ីចឹង គឺអ៊ីចឹង។ តែបងប្អូនចាមប្រុសៗត្រូវបានគេវ៉ៃ ចូលទៅគេវ៉ៃហើយ។ មុននឹងចូលទៅក្នុង វិហារហ្នឹង គេវ៉ៃ គេវ៉ៃមួយឈើ -- មួយដែកហ្នឹងសិន។ គេឈរនៅចាំអាមាត់ទ្វារហ្នឹង វ៉ៃ។

**ស៖** តើលោកបានឃើញប្រជាជនចាមចូលទៅក្នុងវត្តអូរត្រកួនដែរឬទេ? តើលោកបានឃើញ ដោយផ្ទាល់ភ្នែកដែរទេ?

**ឆ៖** ខ្ញុំមិនត្រឹមតែបានមើលឃើញថា បងប្អូនចាមចូលទៅក្នុងវត្តទេ គឺខ្ញុំបានឡើងទៅដល់វិហារ

នៅលើវិហារដែលគេសម្រាប់ឃុំឃាំងបងប្អូនចាមហ្នឹង។ ឃើញផ្ទាល់នឹងភ្នែកតែម្តង។ ទៅដល់កន្លែងហ្នឹងតែម្តង មាត់ទ្វារហ្នឹង គឺខ្ញុំបានឡើងទៅដល់ជណ្តើរលើតែម្តង។

**ស៖** តើលោកបានឃើញអ្វីខ្លះនៅខាងក្នុងវត្ត?

[១១:០២:៣០]

**ឆ៖** នៅក្នុងព្រះវិហារនោះ វាមានដូចនៅក្នុងវិហារ គេសម្រាប់ឃុំឃាំងអ្នកទោស ក៏ប៉ុន្តែដល់ពេលដែលខ្ញុំនាំទៅហ្នឹង វាមិនជាសូវមើលច្បាស់ប៉ុន្មានទេ ខ្ញុំមើលបានតែកៀនៗហ្នឹង គឺសុទ្ធតែអ្នកទោសដែលត្រូវគេដាក់កងជើង ដោយមានដែកមួយគេស្វានសសរវិហារហ្នឹងទៅ គេស៊កបណ្តោយ អ៊ំ!ទទឹងវិហារហ្នឹងទៅ ហើយគេរៀបមនុស្សហ្នឹងដាក់អង្គុយជួរអ៊ីចឹងទៅ ដាក់កងជើង អាកងគេច្នៃប្រឌិតដែកយើងដំធ្វើដូចនេះអ៊ីចឹង គេមានប្រហោងគេពីរអ៊ីចឹងទៅ គេស៊កជើងរួច បានគេស៊កអាដែកហ្នឹងបន្តៗគ្នាទៅ។ នៅជាយៗហ្នឹងខ្ញុំអាចមើលឃើញ ដល់ទៅក្នុងនោះ ខ្ញុំមិនអាចមើលឃើញច្បាស់ទេ ប៉ុន្តែថ្ងៃដែលចាប់បងប្អូនចាមទៅហ្នឹង គឺអ្នកទោសហ្នឹង គឺពេញវិហារតែម្តង កោកកាកពេញតែវិហារហ្នឹងទាំងអស់តែម្តង។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតបង្ហាញជូនសាក្សីនូវរូបថតមួយចំនួន ចង់បញ្ជាក់ថា តើគាត់អាចស្គាល់មនុស្សក្នុងរូបថតនេះ ឬក៏អត់។ គឺឯកសារ E3/2569, E3/2568, E3/2573 ហើយរូបថតនេះ គឺមាននៅក្នុងឯកសារ E3/2654 ត្រង់ ERN 00211171។ ខ្ញុំសូមការអនុញ្ញាតពីអង្គជំនុំជម្រះបង្ហាញជូនសាក្សី ហើយក៏សូមការអនុញ្ញាត ដើម្បីបង្ហាញរូបថតនេះ នៅលើអេក្រង់ផង។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី ទី១ សូមឲ្យលោកមើលរូបថតនៅក្នុងឯកសារ E3/2569 សិន។ បាទ សូមការអនុញ្ញាតដើម្បីបង្ហាញរូបថតនៅត្រង់ឯកសារ E3/2569 នេះ។ តើលោកចាំរូបថតដែលចាក់បង្ហាញនេះទេ?

**លោក សេង ស៊្រុន៖**

**ឆ៖** រូបថតហ្នឹង ខ្ញុំមើលទៅដូចវាអត់ច្បាស់ គ្រាន់តែខ្ញុំឃើញរូបថត ខ្ញុំថានេះជាមុនីសារវន្ត

ដែលខ្លោងទ្វារវត្តអូរត្រកួនបាទ។ ប៉ុន្តែមនុស្សហ្នឹងមើលទៅវាអត់ច្បាស់សោះ វាតូចពេក។ អាចពង្រីកបានទេ? មិនដឹងនរណា ដូចមើលវាមិនច្បាស់សោះ។

**ស៖** ឈ្មោះវត្តដែលលោកទើបតែនិយាយអម្បាញ់មិញហ្នឹង តើក៏ជាឈ្មោះវត្តមួយ ក៏ជាឈ្មោះវត្តអូរត្រកួនដែរ គ្រាន់តែហៅឈ្មោះពីរ។ អ៊ីចឹង ឬមែនទេ ឈ្មោះដែលលោកឆ្លើយមុនអម្បាញ់មិញនេះ?

**ឆ៖** តាមពិតទៅវត្តហ្នឹងគេដាក់ឈ្មោះថា វត្តមុនីសារវន្ត ប៉ុន្តែប្រជាជននៅកន្លែងខ្ញុំហ្នឹងគេហៅតែវត្តអូរត្រកួនៗ តាំងពីដើមមក។ តាមពិតឈ្មោះវត្តមុនីសារវន្ត។ រូបភាពហ្នឹង ខ្ញុំមើលដូចមិនច្បាស់ដល់មើលទៅដូចរូបខ្ញុំម៉េចទេ មើលអត់សូវច្បាស់។

**ស៖** លោកចាំថាលោកបាននាំអ្នកស៊ើបអង្កេតពីការិយាល័យសហចៅក្រមស៊ើបអង្កេតទៅកាន់វត្តអូរត្រកួនទេ? ហើយលោកបានបង្ហាញនេះខ្លោងទ្វារវត្តនេះ?

[១១:០៧:៣៧]

**ឆ៖** បាទ ខ្ញុំបានជូនគាត់ទៅនុ៎ងមែន ប៉ុន្តែវាអ៊ីចេះ វាច្រើនមនុស្សពេកខ្ញុំវាដូចថា មិនសូវចាំច្បាស់លាស់ ប៉ុន្តែការស៊ើបអង្កេតហ្នឹងគឺវាមានច្រើនដង។ ហើយថតហ្នឹង ក៏មិនដឹងនៅលើកទីប៉ុន្មានដែរ ខ្ញុំវាដូចថាវាមិនសូវចាំច្បាស់។ ប៉ុន្តែថាចាំថារូបថតហ្នឹងមើលទៅដូចរូបខ្ញុំ មែនរូប--។

**ឆ៖** ឥឡូវ ខ្ញុំសូមលោកមើលរូបថតបន្ទាប់នៅក្បែរផ្លូវ គឺឯកសារ E3/2568។ តើលោកនៅចាំផ្លូវនេះទេ? រូបថតនេះវាហាក់មិនច្បាស់បន្តិច ប៉ុន្តែតើលោកចាំផ្លូវដែលបង្ហាញនៅក្នុងរូបថតនេះ ឬក៏អត់?

**ឆ៖** បាទ តាមរូបភាពនេះ បើតាមការខ្ញុំមើលទៅ ឃើញថានេះជាផ្លូវ ជាសាលាបឋមសិក្សាសំបួរមាស “ក” ស្ថិតនៅទីផ្លូវពីថ្នល់ទៅ ហើយចូលមកត្រង់ហ្នឹងមានខ្លោងទ្វារមួយនៅខាងត្បូងវត្តហ្នឹងកាច់ទៅកើតមានសាលាបឋមសិក្សាដែលសព្វថ្ងៃនៅមាននៅឡើយ គឺជាទីតាំងសាលារៀន។ ហើយទល់នឹងសាលារៀនហ្នឹង គឺផ្ទះខ្ញុំនៅទល់មុខសាលារៀនហ្នឹង។

**ស៖** ឥឡូវនេះ គឺថាទុករូបថតបន្ទាប់ចោលសិនចុះ ប៉ុន្តែសូមបង្ហាញរូបថតអំពីវត្តដែលមាននៅក្នុងឯកសារ E3/2654 គឺរូបថតមាននៅត្រង់ ERN 00211171 នេះគឺជាសំណៅថតចម្លងរូបថតដែលមានភាពច្បាស់គ្រាន់បើ។ ដូច្នេះសូមការអនុញ្ញាតបង្ហាញរូបថតមួយនេះជូនសាក្សីមើល។ លោកសាក្សីសូមមើលរូបថតនៅលើអេក្រង់កុំព្យូទ័រនេះ តើលោកស្គាល់វត្តនេះទេ ហើយតើវត្តនេះ ឈ្មោះអ្វីដែរ?

[១១:១១:០៤]

**ឆ៖** បាទ វត្តហ្នឹង គឺវត្តអូរត្រកួន ហៅវត្តមុនីសារវន្ត ហៅ អូរត្រកួន វត្តហ្នឹង។

**ស៖** តើអគារនេះ វិហារនេះ គឺជាព្រះវិហារមួយដែលគេប្រើតាំងពីឆ្នាំ១៩៧៦ ក្នុងរបបខ្មែរក្រហមហ្នឹងឬ?

**ឆ៖** វិហារនេះកាលពី១៩៧៦ វាមិនមែនជាវិហារដដែលហ្នឹងទេ ព្រោះគេក្រោយមកគឺគេផ្លាស់ប្តូរ គេផ្លាស់ដំបូល ផ្លាស់ក្បឿងផ្លាស់អីហ្នឹង ហើយគេលាបថ្នាំលាបអីអ៊ីចឹងទៅណា។ គេមានការបន្ថែមប្តូររូបភាព ពីមុនមកវិហា៧៦ហ្នឹងគឺវា មើលទៅវាចាស់ ហើយវា បើនិយាយនៅក្នុងវិហារ វាសុទ្ធតែឈាមជាប់នៅនេះនុ៎ង។ ដល់ក្រោយមក ក្រោយពីដាច់៧៩ហ្នឹងទៅ ចៅអធិការវត្ត និងគណៈកម្មការហ្នឹង គេក៏បានបោសសម្អាតវិហារហ្នឹង កសាងផ្លាស់ដំបូល ផ្លាស់អីចេញវិញ។

**ស៖** ក្រៅពីការជួសជុលដំបូល តើនិយាយពីរចនាសម្ព័ន្ធអគារនេះ វិហារនេះតែម្តងនេះ វានៅតែដូចគ្នាទៅនឹងពេលដែលគេប្រើប្រាស់វាក្នុងឆ្នាំ៧៦ និង៧៧ដែរទេ និយាយពីទំហំ និយាយអំពីលក្ខណៈរបស់វានោះ?

**ឆ៖** បាទ ខ្ញុំសូមជម្រាបថា ព្រះវិហារនេះ គឺទំហំផ្ទៃវិហារហ្នឹង គឺអត់មានការប្រែប្រួលទេ គឺមានតាំងពីដើមមកគឺអ៊ីចឹង។

**ស៖** លោកបានជម្រាបជូនតុលាការថា លោកបាននាំជនជាតិចាមទៅកាន់វត្តនោះ។ ក្រោយពីលោកនាំប្រជាជនទៅកាន់វត្តហ្នឹង តើលោកធ្វើអ្វីទៀត?

**ឆ៖** ពេលដែលខ្ញុំនាំទៅហើយ គេចាប់បញ្ចូលបងប្អូនអ៊ីស្លាមចូលទៅក្នុងវិហារហើយ ខ្ញុំក៏គេឲ្យត្រឡប់មកផ្ទះវិញមក។ មកកន្លែងរោងបាយវិញ រែកបំពង់ទឹកត្នោតមកផ្ទះវិញមក។ ប៉ុណ្ណឹង រឿងរ៉ាវអីទៀត គឺខ្ញុំអត់ដឹង។

[១១:១៥:០៥]

**ស៖** នៅពេលដែលលោកបានទៅដល់ផ្ទះនៅយប់នោះ តើលោកមានស្តាប់ឮសូរគេចាក់ភ្លេងចេញពីវត្តអូរត្រកួននោះ មកដែរទេ?

**ឆ៖** ពេលដែលខ្ញុំមកវិញហ្នឹងគឺសំឡេងឧគ្ឃោសនាសព្ទហ្នឹង គឺគេបានចាក់ ហើយខ្ញុំក៏អត់បានគិតថា គេសម្លាប់បងប្អូនចាមហ្នឹង យប់ហ្នឹងដែរ។ ក៏ប៉ុន្តែដល់ពេលភ្លឺឡើង ខ្ញុំបានទៅឡើងត្នោតហ្នឹង ខ្ញុំជួបឈ្មោះ មឿន ហ្នឹងខ្ញុំថា ម៉េច មឿន បងប្អូនពួកចាមគេចាប់យកមកល្ងាចមិញនោះ ម៉េចទៅហើយ? គាត់ថា អូ! វ៉ើចោលអស់យប់មិញទៅហើយ គ្មានសល់មួយទេ វ៉ើទាំងយប់ហ្នឹងតែម្តង។ វ៉ើទល់តែម៉ោង

ជិតពីរដណ្តប់ បានអស់។ រួចខ្ញុំថា ខ្ញុំនិយាយថា ចុះក្មេងតូចៗ ដែលគេចាប់ទៅនោះម៉េចដែរ? អាក្មេងតូចៗដែលតាមម្តាយនោះ? អ៊ូ! អាខ្លះវាចាប់ហែកជើង អាខ្លះវាបោកនឹងគល់ឈើ បោកបោះៗទៅក្នុងរណ្តៅជាមួយមនុស្សធំ មនុស្សតូច លាយគ្នាហ្នឹងទៅ។ វាគ្មានសម្លាប់ទេអាហ្នឹង វាចាប់បោកទៅ អាខ្លះហែកទៅ។ អាហ្នឹងវាបោះទៅក្នុងរណ្តៅហ្នឹងទៅជាមួយមនុស្សចាស់ហ្នឹងទៅ។ រួចខ្ញុំសួរបញ្ជាក់ថា អត់មានសល់ខ្លះទេ ថារឿងបងប្អូនចាមអត់មានសល់ទេ ព្រោះចាមយកមកច្រើន យកពីតាមភូមិហ្នឹងទៅ ដូចខ្ញុំបានបញ្ជាក់ថាពីរបីរយ ក៏ប៉ុន្តែយល់បន្តិចទៅ គេដឹកពីការដ្ឋានមក ពួកចល័តហ្នឹង ពួកចល័តនារីបុរសហ្នឹងដែលជាកងចល័តហ្នឹង ក៏គេយកមកសម្លាប់ក្នុងពេលយប់តែមួយហ្នឹងដែរ។

[១១:១៥:៤៨]

**ស៖** តើលោកស្តាប់ឮគេចាក់មីក្រូ ចាក់ភ្លេងតាមមីក្រូហ្នឹងរយៈពេលប៉ុន្មានដែរ?

**ឆ៖** វាចាក់មីក្រូយប់ហ្នឹង ដូចវាប្លែកពីធម្មតា។ រាល់ដង វាចាក់ត្រឹមម៉ោងប្រាំបួនម៉ោងដប់អីវាបិទហើយ។ អានេះបើតាមខ្ញុំប៉ាន់ស្មាន ម៉ាជំនាន់នុ៎ង ក៏យើងអត់មានម៉ោងមានអីណាមើលនឹងគេដែរ អានេះនិយាយតាមការប៉ាន់ស្មាន ប៉ុន្តែតាមយើងធ្លាប់ដេកអីអឺចឹងទៅ ម៉ោងប៉ុន្មានៗមាន់រងាវអីអឺចឹងទៅ ហើយមីក្រូហ្នឹងវាបិទៗមុនមាន់រងាវប្រហែលជា តាមស្មានប្រហែលជាកន្លះម៉ោងទេ។ ហើយអាមាន់រងាវទឹកជោរហ្នឹង បើតាមអាទម្លាប់វា វាច្រើនតែរងាវម៉ោងដបពីរ។ ម៉ោងដប់ពីរអីហ្នឹងវាចាប់រងាវហើយ។ រួចដល់ពេលគេបិទមីក្រូហ្នឹង មាន់អាមាន់ហ្នឹងបិទតែមួយសន្ទុះ ប្រហែលជាមិនបាន៣០នាទីអាមាន់ហ្នឹងក៏វារងាវទៅ។ ដូច្នេះក្នុងការប៉ាន់ស្មានហ្នឹង វាចាក់រហូតដល់ម៉ោងជិតដប់ពីរយប់។

**ស៖** តើលោកធ្លាប់ឃើញប្រជាជនចាមត្រូវបានគេនាំខ្លួនទៅវត្តអូរត្រកួន -- ប្រជាជនចាមដែលគេនាំខ្លួនទៅវត្តអូរត្រកួនកាលយប់នោះ ក្រោយមកលោកបានឃើញអ្នកណាខ្លះឡើងវិញទេ?

**ឆ៖** បងប្អូនចាមដែលត្រូវបានគេចាប់ខ្លួនហ្នឹង វាបើនិយាយរួមទៅ នៅក្នុងឃុំពាមជីកងមានតែពីរនាក់ទេ ដែលអាចគេចខ្លួនរួច គឺនៅសាច់សូហ្នឹង។ ដល់នេះទៅវានាំគ្នារត់ទៅ រត់ទៅនៅក្នុងបឹង។ រត់បានពីរនាក់ មួយឃុំហ្នឹងរត់បានពីរនាក់ រត់បានបីនាក់ដែរ មួយនោះរត់ទៅខាង មកខាងភូមិភាគបូព៌ា ប៉ុន្តែក្រោយមក គេត្រូវចាប់បានវិញ គេតាមចាប់បាន។ តែអាពីរនាក់ដែលវារត់រួច រត់ចុះទៅបឹងហ្នឹង គឺសព្វថ្ងៃគឺនៅរស់ទល់សព្វថ្ងៃហ្នឹង។

[១១:១៨:២៥]

**ស៖** ពេល មឿន ប្រាប់លោកអំពីការសម្លាប់នេះ តើ មឿន មានប្រាប់ថា ប្រជាជនចាមទាំង

នោះត្រូវបានគេសម្លាប់នៅឯណាទេ?

**ឆ៖** ប្រជាជនចាមដែលគេត្រូវសម្លាប់ហ្នឹង គេសម្លាប់នៅមុខវត្តតែម្តង។ ចម្ការ ត្រង់នុំងជាចម្ការគេពីសង្គមមក ចម្ការស្លា ចម្ការអីហ្នឹង ក្រូចឆ្មារ ចម្ការអីហ្នឹង ស្វាយអីហ្នឹង ក៏ប៉ុន្តែបងប្អូនចាមហ្នឹង ត្រូវគេបានគេជីករណ្តៅធំៗ រណ្តៅហ្នឹងប្រហែលជា១០ម៉ែត្របួនជ្រុងក្នុងរណ្តៅមួយ។ រណ្តៅមួយវាទំហំប្រហែល១០ម៉ែត្របួនជ្រុង ពេលគេវៃបងប្អូនចាម គឺគេជីករណ្តៅធំៗ ព្រោះមនុស្សច្រើន។ ហើយរណ្តៅមួយៗហ្នឹងអាចដាក់ដល់បានទៅ៧០ ឬក៏៨០នាក់។ ពេលអារណ្តៅធំៗហ្នឹង ខ្ញុំដើរៗទៅឡើងត្នោតហ្នឹង ឃើញរណ្តៅហ្នឹងវាមានរណ្តៅប្រាំ កៀកៗគ្នា គឺរណ្តៅសុទ្ធតែធំៗ។

**ស៖** ចម្ការនោះ ដែលគេជីករណ្តៅហ្នឹងគឺថាវាស្ថិតនៅទិសខាងណានៃវត្តនោះ វានៅខាងកើត ខាងលិច ខាងជើង ឬខាងត្បូង?

**ឆ៖** ចម្ការដែលគេជីករណ្តៅកប់បងប្អូនចាមនោះ គឺវាស្ថិតនៅខាងមុខៗព្រះវិហារហ្នឹងតែម្តង ប៉ុន្តែនៅឆៀងខាងជើង។ ចម្ការដែលគេធ្វើជាទីតាំងសម្រាប់កប់មនុស្សដែលគេសម្លាប់ហ្នឹង គឺវាមានពីរ ប៉ុន្តែពីរហ្នឹងវាស្ថិតនៅក្នុងភូមិសាស្ត្រជាប់គ្នាទេ គ្រាន់តែមានរបង។ របងហ្នឹង ក៏ជាមិនរបងអីសំខាន់ដែរ របងយើងធម្មតាហ្នឹង កូនឈើ ឫស្សីអីធម្មតាទេ ប៉ុន្តែនៅជាប់គ្នា។ ហើយបងប្អូនចាមហ្នឹង បានត្រូវគេយកទៅកប់ កាប់រណ្តៅនៅខាងមុខវិហារដែរ ប៉ុនចម្ការខាងជើងៗ។

**ស៖** លោកបានឆ្លើយថា លោកបានឃើញរណ្តៅនៅពេលលោកឡើងត្នោត។ តើលោកបានទៅពិនិត្យមើលវត្តអូរត្រកួនឡើងវិញទេក្រោយឆ្នាំ១៩៧៩? ហើយតើលោកឃើញរណ្តៅទាំងនោះនៅដដែលឬទេ?

[១១:២១:១៦]

**ឆ៖** បាទ ក្រោយពីឆ្នាំ១៩៧៩ ពេលនុំង បើនិយាយរួមទៅ អ្នកស្រុកហ្នឹងគាត់ដូចថា គាត់ទៅជីកខ្មោចដើម្បីយកមាស យកអីអីចឹងទៅណា។ វាមិនមែនថាអ្នកស្រុកទេ បើនិយាយទូទៅគឺពួកខាងយោធាស្រុកអីហ្នឹង។ គេទៅ គេនាំអ្នកស្រុកដែរគេចូលរួមដែលគាត់ស្គាល់ៗហ្នឹង ទៅជីករណ្តៅដើម្បីយកមាស យកអីហ្នឹង។ ហើយរណ្តៅបងប្អូនចាមហ្នឹង ខ្ញុំបានទៅឈរមើល។ អង្កាល់នុំងខ្ញុំក៏ជា គេចាត់តាំងឲ្យធ្វើប្រធានភូមិ ពីដាច់៧៩ហ្នឹង ឲ្យខ្ញុំធ្វើប្រធានភូមិនៅហ្នឹង ហើយខ្ញុំក៏បានដើរទៅមើលគេជីក។ ខ្ញុំអត់បានជីកទេ គេទេអ្នកជីក ប៉ុន្តែខ្ញុំគ្រាន់តែឈរមើល។ ហើយរណ្តៅមួយដែល ខ្ញុំថាសន្និដ្ឋានថារណ្តៅជាប់គ្នាបួនប្រាំ សុទ្ធតែរណ្តៅបងប្អូនចាមហ្នឹង គឺតាមការកត់សម្គាល់ខ្លះ វាមានខោអាវខ្លះ ដែលជា

ប្រពៃណីបងប្អូនចាមហ្នឹងគាត់ស្លៀកពាក់ណ៎ា វាមានខ្លះ ហើយអត់ខ្លះ។ ហើយវាមានទាំងក្បាលកូនក្មេង និងក្បាលមនុស្សធំលាយគ្នា។ បានខ្ញុំថា សន្និដ្ឋានថារណ្តៅដែលធំៗហ្នឹង គឺជារណ្តៅរបស់គេសម្រាប់កប់បងប្អូនចាម ហើយ មឿន ហ្នឹងក៏បានប្រាប់ខ្ញុំដែលថា គេអត់កប់ដូចអ្នកទោសដែលគេចាប់ពីរបីៗមក អាហ្នឹងគេកាប់រណ្តៅតូចៗទេ គេកប់នុ៎ង។ ហើយកាប់ហ្នឹង ក៏វាលុបមិនជិតដែរ គ្រាន់តែកាប់មួយតួៗខ្លួន លុបបន្តិចទៅ ធុំក្លិនស្អុយអីអ៊ីចឹងទៅ វាពាសពេញតែនុ៎ង។ ប៉ុន្តែបងប្អូនចាមហ្នឹង គេកាប់រណ្តៅហ្នឹងប្រហែលជា១០ម៉ែត្របួនជ្រុង ជម្រៅប្រហែលក។ ខ្ញុំឃើញគេកាយសព ដែលរកមាសរកអីហ្នឹង ប្រហែលជាត្រឹមក។ រួមមានតាំងពីក្បាលកូនក្មេង ក្បាលមនុស្សចាសអីអ៊ីចឹងទៅណ៎ា។ អាហ្នឹងក្រោយពី៧៩ ដែល ប៉ុល ពត បានរលំទៅហ្នឹង គឺខ្ញុំបានពិនិត្យមើលឃើញអ៊ីចឹងមែន ដូចពាក្យ មឿន ហ្នឹងប្រាប់ខ្ញុំមែន។

[១១:២៣:៣២]

**ស៖** លោកសាក្សី តំបន់ដែលលោកបានឃើញរណ្តៅសាកសពហ្នឹង តើនៅមុនខ្មែរក្រហមបង្កើតមន្ទីរសន្តិសុខនៅវត្តអូរត្រកួនហ្នឹង ធ្លាប់ដែលមានរណ្តៅបែបនេះទេ? តើធ្លាប់មានរណ្តៅបែបនេះនៅវត្តអូរត្រកួនទេ មុនពេលខ្មែរក្រហមបង្កើតមន្ទីរសន្តិសុខនៅទីនោះ?

**ផ៖** បាទ កាលពីសម័យមុនជំនាន់ដែលគេមិនទាន់បង្កើតមន្ទីរសន្តិសុខ គឺកន្លែងនោះ គឺអត់មានរណ្តៅទេ សូម្បីតែខ្មោចមួយក៏អត់មានដែរ គឺជាចម្ការរបស់ប្រជាពលរដ្ឋដែលគាត់ដាំដំណាំ។ ក្រោយមក មកសម័យ ប៉ុល ពត ដែលដាច់ពី៧៥មកហ្នឹងគឺគេ ដូចថាគេរំលាយកម្មសិទ្ធិ អត់មានដីហ្នឹងម្ចាស់ណាទៅកាន់កាប់បានទេ គេចង់យកធ្វើអី ស្រេចនឹងគេ សម័យខ្មែរក្រហមហ្នឹងគឺអស់កម្មសិទ្ធិហើយរៀងខ្លួន នៅតែផ្ទះទេ។ សូម្បីតែផ្ទះយើងនៅហ្នឹង ក៏គេត្រូវការរុះ គេរុះដោយអត់មានថា យើងឲ្យរុះ បានគេរុះ តែបើយើងមិនឲ្យរុះ ក៏គេរុះដែរ តែរុះ គេរុះចោលទាំងអស់ហ្នឹង។ អត់មានរណ្តៅអីទេកន្លែងនេះនោះ គឺជាចម្ការធម្មតាអ៊ីចឹងទៅ។

**ស៖** ខ្ញុំមានចំណុចមួយចំនួនតូចទៀតទេ ដែលត្រូវសួរទៅលោក។ ទី១ នៅម្តុំពេល ឬនៅក្នុងអំឡុងពេលដែលគេចាប់ប្រជាជនចាម នៅក្នុងឃុំរបស់លោក តើមានកម្មាភិបាលណាម្នាក់និយាយថាហេតុអ្វីបានជាប្រជាជនចាមទាំងនោះ ត្រូវបានគេចាប់ខ្លួនទេ?

[១១:២៥:៣៤]

**ផ៖** ក្រោយពីការដែលគេចាប់បងប្អូនចាមមកហ្នឹង ដូចជា បើនិយាយរួមទៅ ខ្ញុំអត់សូវបាន

ទទួលព័ត៌មាន ឬក៏ដឹងហេតុការណ៍ក្នុងសម័យ ប៉ុល ពត ហ្នឹងទេ ព្រោះខ្ញុំ គេមិនសូវឲ្យដឹងរឿងរ៉ាវទេ ព្រោះការដែលគេលាក់ការណ៍ហ្នឹង គឺគេសម្រាប់តែគ្នាគេនៅក្នុងអង្គភាពនុ៎ង។

**សៈ** ខ្ញុំមិនចង់ឲ្យលោកសន្មត ឬក៏ស្មានទេ លោកសាក្សី ខ្ញុំចង់អានឲ្យលោកស្តាប់នូវអ្វីដែលលោកបានឆ្លើយនៅក្នុងឆ្នាំ២០០៨ គឺឯកសារ E3/5302, ERN ជាភាសាខ្មែរ 00635176, អង់គ្លេស 00210488, បារាំង 00623191។ ខ្ញុំសូមដកស្រង់ នេះគឺជាអ្វីដែលលោកបានឆ្លើយ៖ "គេបានប្រាប់ខ្ញុំថា ជនជាតិចាមជាជនជាតិមួយផ្សេង ដូច្នេះត្រូវតែកម្ទេចចោល។ បើសិនណាជាទុកពួកគេទៅ ពួកគេនឹងងើបបះបោរប្រឆាំងជាមួយយើងនៅពេលណាមួយ។" បញ្ចប់ការដកស្រង់។ នៅក្នុងកិច្ចសម្ភាសន៍នេះលោកក៏បានបញ្ជាក់ពីបុគ្គលដែលបានឆ្លើយពីចំណុចនេះ បញ្ជាក់មូលហេតុនេះ ខ្ញុំមិននិយាយឈ្មោះទេ ប៉ុន្តែលោកប្រធាន គឺសាក្សី 2-TCW-873។ លោកសាក្សី លោកដឹងទេ គឺមានអ្នកណាម្នាក់មកពីក្រុមដាវវែង និយាយថា ចាមនេះជាជាតិសាសន៍មួយផ្សេងដែលត្រូវតែកម្ទេចចោលនោះ?

[១១:២៧:៥៣]

**ឆះ** ខ្ញុំដូចជា មានការភ្លេចភ្លាំងដែរ ក៏ប៉ុន្តែខ្ញុំ ចំពោះអ្នកដែលគេត្រូវកម្ទេចហ្នឹង មិនមែនតែបងប្អូនជាតិចាមទេ។ ទី១ បងប្អូនចាមហ្នឹង គឺគេកម្ទេចក្រោយគេបង្អស់។ ទី១ គឺគេកម្ទេចប្រជាពលរដ្ឋ គេហៅថា ប្រជាជនថ្មី ឬក៏ប្រជាជន៧៥ ហើយនិងអ្នកដែលជាប់និន្នាការជាមន្ត្រីរាជការពីសម័យសង្គមរាស្ត្រនិយម ក៏ដូចជាសម័យ លន់ នល់ ហ្នឹងដែរ។ ហើយចំពោះបងប្អូនចាមនេះ គឺជាជំហានចុងក្រោយដែលគេកម្ទេចក្រោយគេបង្អស់។ ហើយចំពោះតែការដែលគេថាចាមហ្នឹង ខ្លាចម៉េចៗហ្នឹង អាហ្នឹងខ្ញុំដូចជាមិនច្បាស់ដែរ ហើយខ្ញុំក៏មិនបានទទួលពីអ្នកណាមួយដែរ។ អានេះ គឺនិយាយតាមការដែល ការស្មោះត្រង់ គឺអ៊ីចឹង។ ខ្ញុំអត់បានទទួលព័ត៌មានទេ ព័ត៌មានខ្លះក៏វាគេមិនអាចប្រាប់យើងច្បាស់លាស់ដែរ គ្រាន់ថា ជាការនិយាយធម្មតាៗអ៊ីចឹង។ ប៉ុន្តែតែថាតាមការពិត ដូចខ្ញុំជម្រាបអ៊ីចឹងគោលដៅគេពួកខ្មែរក្រហមហ្នឹង សត្រូវគេទី១ គឺប្រជាជនថ្មីៗ ប្រជាជន៧៥ហ្នឹង ហើយនិងពួកមន្ត្រីរាជការដែលធ្លាប់បម្រើឲ្យសម័យសាធារណរដ្ឋ និងសម័យរាជានិយម។ អាហ្នឹងអ៊ីចឹង ហើយមិនមែនតែបងប្អូនចាមហ្នឹងទេ សូម្បីតែចល័ត គាត់ជាប់ជាកងចល័តហើយ គាត់ជាប្រជាពលរដ្ឋជម្លៀសពីឆ្នាំ៧៥ទៅ ក៏មានការគាបសង្កត់ការធ្វើបាប គ្រប់បែបគ្រប់យ៉ាងពីនេះហ្នឹងដែរ ហើយក៏ការចាប់ខ្លួនហ្នឹងក៏ច្រើន គឺភាគច្រើនតែប្រជាជនថ្មីហ្នឹងតែម្តង ចល័តក៏អ៊ីចឹងដែរ ទាំងចល័ត ទាំងអ្នកប្រជាពលរដ្ឋនៅតាមមូលដ្ឋានដែលគាត់មាននិន្នាការជាប្រជាជនថ្មី ហើយនិងជាមន្ត្រីរាជការអីហ្នឹងក្នុងសម័យរាជានិយម និងសម័យសាធារណរដ្ឋ។ ហើយ

អ្នកដែលមានពាក់ព័ន្ធជាមួយពួកសម័យខ្មែរក្រហមដូចគ្នាហ្នឹង ប៉ុន្តែគ្រាន់ថាពួកនិរតីចាស់ -- អ៎! ពួកកម្មាភិបាលចាស់ និងកម្មាភិបាលថ្មីហ្នឹង ក៏មានតាមដាន ចាប់តាមខ្សែ តាមបក្សពួកអីចឹងដែរ។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំមើលម៉ោងទៅ ឃើញថាម៉ោងដប់មួយ សាមសិបនាទីហើយ ខ្ញុំត្រូវការពេលវេលាប្រហែលជា១០នាទីទៀត ហើយខាងដើមបណ្តឹងរដ្ឋប្បវេណី គាត់ប្រាប់ថា គាត់ត្រូវការ១០នាទីដែរ។ បើអង្គជំនុំជម្រះ អនុញ្ញាតបន្ថែមម៉ោងឲ្យខ្ញុំ២០នាទីទៀត សាកសួរតទៅទៀត គឺថាខ្ញុំអាចសួរបន្តពីនេះតែម្តង ឬក៏ថាអាចចាប់បន្តក្រោយពេលសម្រាក?

[១១:៣០:៥៦]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៣១:២៨]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតទៅតាមសារៈសំខាន់នៃសក្ខីកម្មរបស់សាក្សី។ ផ្តល់ឲ្យសរុបទាំងពីរនាក់ហ្នឹង២០នាទី តាមសំណើនេះ។ ឥឡូវនេះ គឺសូមអញ្ជើញបាទ ខាងសហព្រះរាជអាជ្ញាឲ្យចប់ទៅ សហព្រះរាជអាជ្ញារង។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី ខ្ញុំចង់អានឲ្យលោកស្តាប់នូវបញ្ហាដែលខ្ញុំទើបតែសួរលោក ទាក់ទងទៅនឹងមូលហេតុនៃការចាប់ខ្លួនជនជាតិចាម គឺចម្លើយដែលលោកឆ្លើយគឺ E3/1692។ ខ្មែរមានលេខ 00218554 ដល់ 555, អង់គ្លេសមានលេខ 00242088 និងបារាំងមានលេខ 00337425 ដល់ 26។ នេះ គឺជាអ្វីដែលលោកបានផ្តល់សក្ខីកម្មជាមួយអ្នកស៊ើបអង្កេតនៃសហចៅក្រមស៊ើបអង្កេត៖ “សំណួរ៖ តើលោកបានដឹងពីមូលហេតុនៃការចាប់ខ្លួន និងការសម្លាប់ជនជាតិចាមដែរឬទេ? ឆ្លើយ៖ មិនមានអ្នកណាម្នាក់ប្រាប់ពីមូលហេតុនោះទេ ប៉ុន្តែខ្ញុំបានសង្កេតឃើញថា ពួកគេបានចាត់ការប្រឆាំងនឹងអ្នកណាដែលមិនមែនជាខ្មែរ ជាពិសេសជនជាតិចាម និងយួន។ ឪពុកម្តាយខ្ញុំបានរៀបការជាមួយស្ត្រីវៀតណាមម្នាក់ ហើយប្រពន្ធគាត់ និងកូនទាំងអស់ ដែលមានគ្នាប្រាំបួននាក់ ត្រូវបានគេចាប់យកទៅ

សម្លាប់ ដោយសារតែម្ដាយជាជនជាតិវៀតណាម។ ឪពុកមាខ្ញុំឈ្មោះ ញេច គុច មិនត្រូវបានគេចាប់យកទៅសម្លាប់ទេ ព្រោះគាត់ជាខ្មែរសុទ្ធ។" សូមបញ្ចប់ការដកស្រង់។ លោកសាក្សី តើលោកអាចជម្រាបអំពីឪពុកមារបស់លោក និងប្រពន្ធរបស់គាត់ជាជនជាតិវៀតណាមដែរឬទេ? ថាតើពួកគាត់រស់នៅទីណា ហើយថាតើពេលណាដែលប្រពន្ធ និងកូនរបស់គាត់ទាំងប្រាំបួននាក់ហ្នឹង ត្រូវបានគេចាប់ខ្លួននោះ?

[១១:៣៣:៥០]

**លោក សេង ស្រ៊ុន៖**

**ឆ៖** ឪពុកមាខ្ញុំហ្នឹង គឺគាត់បានយកប្រពន្ធជាជនជាតិវៀតណាម ក៏ប៉ុន្តែមិនមែនគាត់ទើបតែយកទេ គាត់យកតាំងពីសម័យសង្គមរាស្ត្រនិយមម្ល៉េះ។ ហើយពេលនុំង សម័យមក ប្រហែលជាសម័យលន់ នល់ គេត្រូវបានជម្លៀសបងប្អូនវៀតណាមហ្នឹង ចេញពីស្រុកខ្មែរ ក៏ប៉ុនដល់ពេលនុំង ដោយគាត់មានប្ដីជាខ្មែរ គេក៏បានអនុញ្ញាតឲ្យគាត់រស់នៅជាមួយប្ដីគាត់ហ្នឹង ជាឪពុកមាខ្ញុំហ្នឹង ព្រោះគាត់មានកូនចៅហើយ គេអត់បានបញ្ជូនគាត់ទៅទេ។ តែដល់មកសម័យខ្មែរក្រហមហ្នឹង គេស្រង់ឈ្មោះអីចឹងទៅមិនមែនតែបងប្អូនចាម បងប្អូនខាងវៀតណាមទេ សូម្បីតែចិន ក៏គេស្រាវជ្រាវដែរ គេហៅពួក បេ៥២, ៥៣អីគេហ្នឹង ខ្ញុំវាមិនសូវយល់ន័យគេដែរ ប៉ុន្តែចិនហ្នឹង គេហៅពួកអី បេ៥២។ ពួកហ្នឹងក៏ជាមុខសញ្ញាដែលគេត្រូវតែតាមដានដែរ។ ហើយនៅក្នុងឆ្នាំ៧៧ហ្នឹង ឪពុកមាខ្ញុំហ្នឹង គាត់មានកូនប្រាំបីនាក់ ប្រាំបួននាក់ កូនប្រាំបួននាក់ហ្នឹង។ ដូច្នេះគេចាប់ហ្នឹង គេចាប់ កូនវាប្រាំបួននាក់ គេចាប់កូនហ្នឹងប្រាំបីនាក់ នៅសល់កូនមួយ ដោយសារគេៗលាក់ គេថាគាត់មិនមែនកូនឈ្មោះនេះហ្នឹងទេ ឈ្មោះ អ៊ុក ហ្នឹងទេ។ អ្នកដែលគេចាប់ខ្លួនហ្នឹងឈ្មោះ អ៊ុក គាត់ជនជាតិវៀតណាមហ្នឹងឈ្មោះ អ៊ុក។ ដល់គេ ដូចថាគេនឹកឃើញគេអាណិតអាសូរអីចឹងទៅ ប្រធានកងក៏គេលាក់ឈ្មោះៗ ចាន់ ធូ ហ្នឹងវា អើគ្នាវាខ្មែរ វាមិនមែនទៅចេះនិយាយយួនអីមួយម៉ាត់ផង ប៉ុន្តែគ្រាន់តែម្ដាយជាជនជាតិវៀតណាម ហើយវៀតណាមហ្នឹងក៏មិនមែនកើតនៅស្រុកវៀតណាមដែរ គឺគាត់កំណើតគាត់ គឺនៅស្រុកខ្មែរហ្នឹងដែរហ្នឹង។ ហើយប្រធានកងគេក៏លាក់អីចឹង ទៅក៏បានរួចមួយហ្នឹង មករស់រហូតដល់សព្វថ្ងៃទៅ។ ដូច្នេះការគេចាប់ហ្នឹង គេចាប់ទៅកូនគាត់ហ្នឹងប្រាំបីនាក់ និងប្រពន្ធគាត់មួយ វាប្រាំបួននាក់។ អាហ្នឹងគេចាប់ទាំងថ្ងៃតែម្ដង គេគ្មានចាប់យប់ទេ។ ហើយការដែលចាប់មកហ្នឹង គឺយើងមើលទៅដូចជាវាមានការសង្វេគ គិតថា មនុស្សដូចគ្នា ដល់គេធ្វើយើងប្រហែលជាសត្វធាតុ យើងក៏មានការតូចចិត្តដែរ ក៏ប៉ុន្តែមួយពេលនោះ គឺអត់មានប៊ាន

នរណាមួយ សូម្បីតែខ្ញុំ ថាជាបងជីដូនមួយបង្កើតហ្នឹង ក៏អត់មានទៅប៉ោននិយាយអីដែរ កាលណាយើងនិយាយទៅគេចាប់ទាំងយើងទៀត។

ដូច្នេះមួយជំនាន់នុ៎ង គឺអត់មានពីណាជួយអ្នកណាបានទេ។ សូម្បីតែកូនខ្លួនឯងបង្កើត ក៏យើងអត់ជួយបានដែរ កូនខ្លួនឯងបង្កើត ក៏អត់មានជួយឪពុកបានដែរ គឺថា ដូចគេថា ក្បាលនរណាសក់ពីអ្នកនុ៎ង។ ចាប់អ្នកណាអ្នកនុ៎ងហើយ យើងអត់មានសិទ្ធិតវ៉ាអីទេ។ ហើយដូចគេចាប់ប្រាំបួននាក់ហ្នឹង មកហ្នឹង បើតាមគេចាប់គាត់ គាត់នៅភូមិដំណាក់ជ្រៃ ហើយគេដឹកចូលវត្តអូរត្រកួន ហើយចាប់មកហ្នឹង គឺថាកូនគាត់មួយហ្នឹង អាហ្នឹងកូនទី៤ ឬទី៣ទេ ខ្ញុំភ្លេចឈ្មោះវាអស់ហើយយូរហើយ ប្រហែលជា២០-៣០ឆ្នាំហើយ ខ្ញុំមិនអាចចាំឈ្មោះវាទេ វាមិនដែលឃើញមុខអីច្បាស់លាស់ផង។ ទុកតែរស់ដល់សព្វថ្ងៃ ក៏មិនអាចស្គាល់ដែរ ៣០ឆ្នាំជាងទៅហើយ ថាវាធ្លាក់ពីលើរទេះសេះ ដោយជាប់ចំណង គេអត់ឈប់រទេះសេះដាក់ផង គេអូសៗមកតែម្ដង អូសតាមរទេះសេះនុ៎ងរហូតដល់វត្តអូរត្រកួន។ អាហ្នឹងតាមសាក្សីខ្លះដែលគេឃើញហេតុការណ៍ដែលកើតឡើង ពីណាក៏គេមានការសង្វេគដែរ ក៏ប៉ុន្តែពេលនោះ ដូចខ្ញុំបានជម្រាបនុ៎ង អត់មានពីណាជួយពីណាបានទេ គឺប្រាសយកតែអាយុរៀងខ្លួន កុំឲ្យតែគេមកចាប់យើងហ្នឹងទៀត អរណាស់ហើយ។ រស់មួយថ្ងៃ គឺជីវិតយើងមួយថ្ងៃ គឺសម្រាប់តែមួយថ្ងៃ បើស្អែកទៀតមិនដឹងជាមានរឿងអីកើតឡើងទេ ចំពោះប្រជាជនគ្រប់រូប ទាំងគេ ទាំងខ្ញុំ។ អាហ្នឹងខ្ញុំសូមជម្រាបអ៊ីចឹង ហើយប្រាំបួននាក់ហ្នឹង គឺគេដឹកមកនៅមកចូលវត្តអូរត្រកួនហ្នឹង ប៉ុន្តែចាប់មកនេះ មុនចាប់បងប្អូនចាមមិនមែន ចាប់បងប្អូនចាមក្រោយទេ។ គេចាប់បងប្អូនណាជាប់ជាជនជាតិវៀតណាមហ្នឹង ចាប់មកមុន។ អាហ្នឹងខ្ញុំជម្រាបអ៊ីចឹង ហើយវា២០-៣០ឆ្នាំហើយ ការរៀបរាប់ក៏វាមិនមែនសុក្រឹតថា ត្រឹមត្រូវទាំងអស់ដែរ។ ប៉ុន្តែថា ការដែលខ្ញុំនិយាយ គឺខ្ញុំនិយាយការពិត និយាយរឿងអីដែលខ្ញុំបានឃើញនិយាយរឿងអីដែលខ្ញុំបានដឹង ហើយនិយាយព្រឹត្តិការណ៍អីដែលខ្ញុំបានឮ នឹងភ្នែក ហេតុការណ៍ដែលបានកើតឡើង។

[១១:៣៨:៣៨]

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំមានសំណួរមួយចុងក្រោយទៀត តើលោកដឹងទេថា តើសរុបជារួមមានមនុស្សប៉ុន្មាននាក់ត្រូវបានគេសម្លាប់នៅវត្តអូរត្រកួន? ហើយតើលោកអាចប្រាប់តុលាការបានទេថា តើលោកដឹងចំនួនសរុបហ្នឹងដោយរបៀបណា ឬក៏លោកអាចធ្វើការប៉ាន់ប្រមាណចំនួនសរុបហ្នឹងបានដោយរបៀបណាដែរ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំជំទាស់ទៅនឹងសំណួរនេះ សាក្សីគាត់បានផ្ដល់សក្ខីកម្មរួចមកហើយ ថាគាត់មិនបានឃើញការសម្លាប់នោះទេ ហើយគាត់គ្រាន់តែបានព័ត៌មានដែលគាត់ស្ដាប់ឮ តាមរយៈមូលដ្ឋាន -- ផ្អែកលើមូលដ្ឋានរបស់ មឿន។ ដូច្នេះហើយ គឺថាចំណុចទាំងអស់នេះ គឺវាមិនមានភាពពាក់ព័ន្ធអ្វីទៅនឹងសំណួរឡើយ។ ដូច្នេះ សំណួរនេះ គឺគ្រាន់តែស្នើសុំឲ្យមានការទាយស្មានប៉ុណ្ណោះ។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំមិនមែនស្នើឲ្យទាយស្មាននោះទេ។ ខ្ញុំលើកសំណួរនេះ ដោយសារតែយើងមានពេលវេលាខ្លី។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ខ្ញុំចង់សួរលោកថា ក្រោយពេលដែលបញ្ចប់របបខ្មែរក្រហម លោកសាក្សី ថាតើមានឯកសារ ឬក៏មានបញ្ជីឈ្មោះអ្នកទោសនៅវត្តអូរត្រកួនដែរឬទេ? ហើយថាតើលោកដឹងថាតើមនុស្សប៉ុន្មាននាក់ដែរ ដែលគេឃុំខ្លួននៅវត្តអូរត្រកួននោះ?

[១១:៤០:១៧]

**លោក សេង ស្រ៊ុន៖**

**ឆ៖** បាទ ជាចម្លើយ អានេះខ្ញុំនិយាយតាមការជាក់ស្ដែង ក្នុងភាពយើងជាមនុស្ស។ យើងជាមនុស្សយើងត្រូវនិយាយអីឲ្យមានការពិត។ ដល់យើងចេះតែនិយាយៗហួសពីការដែលព្រឹត្តិការណ៍ដែលកើតឡើង វាអត់កើត។ ដូចនៅក្នុងមន្ទីរសន្តិសុខវត្តអូរត្រកួន អ្នកខ្លះគេអះអាងថា ប្រជាពលរដ្ឋដែលត្រូវគេយកទៅសម្លាប់មានចំនួន៣៥.០០០នាក់ បាទ ៣៥.០០០នាក់ច្រើនណាស់។ ប៉ុន្តែបើខ្ញុំនៅកៀកនឹងវត្តហើយ ខ្ញុំចេញចូលៗស្ទើររាល់ថ្ងៃ ឲ្យខ្ញុំពិនិត្យទៅលើរណ្ដៅនោះ ប្រជាពលរដ្ឋដែលគេសម្លាប់ហ្នឹងវាមិនមែនអាចដល់៣៥.០០០នាក់ទេ។ អានេះនិយាយតាមការជាក់ស្ដែង។ ការតួលេខហ្នឹងគឺអត់មានអ្នកណាមួយថា យកតួលេខឲ្យច្បាស់ថា ប្រជាពលរដ្ឋត្រូវគេសម្លាប់ប៉ុន្មានទេ អត់ៗមានសោះ។ រួចខ្លះទៅ គេថាឃើញឯកសារកប់នៅក្នុងពាងអីណា ឈ្មោះគេយកទៅសម្លាប់អីណាអីណើ។ ខ្ញុំថាវាចេះតែតៗគ្នា

មក។ តែបើតាមខ្ញុំប៉ាន់ស្មានទៅក្នុងវត្តអូរត្រកួនហ្នឹង ប្រជាជនដែលគេត្រូវយកទៅសម្លាប់ហ្នឹងប្រហែល ជា បើថាយ៉ាងច្រើន វាអត់លើសពី១៥.០០០នាក់ទេ។ អាហ្នឹងតាមដែលខ្ញុំពិនិត្យទៅគឺប្រហែលជាល្បាក់ ៥៥.០០០ហ្នឹង ហើយក៏ ២០.០០០ចុះ ២០.០០០ឡើងគឺអត់មានទេ។ ហើយតាម រូចដល់តួលេខគេថា គេដាក់ក្នុងវិមានសាកសពនុំងឯណា ៣៥.០០០ណា ខ្ញុំវាអត់មានជំនឿជឿទេ ក៏ប៉ុន្តែខ្ញុំមិនជឿ ក៏ខ្ញុំមិន និយាយដែរ អាហ្នឹងសិទ្ធិគេ គេនិយាយថាម៉េចគឺរឿងគេ។ ប៉ុន្តែដល់ខ្ញុំៗអត់ជឿទេ ថា៣៥.០០០នាក់ ហ្នឹង បើសិនជា២០.០០០ចុះ អាហ្នឹងខ្ញុំអាចទទួលយក ខ្ញុំអាចឯកភាព។ អាហ្នឹងខ្ញុំសូមជម្រាបទៅដល់ អង្គតុលាការវិសាមញ្ញក្នុងរបបខ្មែរក្រហម។

[១១:៤២:១៩]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកសាក្សីដែលបានចំណាយពេលវេលា។ ហើយខ្ញុំមិនមានសំណួរបន្តទៀតទេ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ សូមគោរពអស់លោក លោកស្រីចៅក្រម ភាគី។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោក ពេជ អង្គ៖**

**ស៖** លោកសាក្សី ខ្ញុំមានសំណួរជូនលោកតែពីរចំណុចទេ ហើយមិនច្រើនទេសម្រាប់ពេលនេះ ដោយសារពេលវេលាខ្ញុំតិចណាស់។ ខ្ញុំសូមសួរបន្តពីខាងសហព្រះរាជអាជ្ញាបន្តិច។ លោកមានស្គាល់ ប្រធានកងចល័តម្នាក់ឈ្មោះ ណួយ ទេលោក អាចបញ្ជាក់បានទេ?

**លោក សេង ស្រ៊ុន៖**

**ឆ៖** បាទ ណួយ ហ្នឹងខ្ញុំស្គាល់គាត់ច្បាស់ណាស់ ប៉ុន្តែគាត់ប្រធានកងចល័តមែន គាត់មិនមែន ប្រធានកងចល័តទេ គាត់ បើនិយាយចំទៅគាត់ជាប្រធានមុខព្រួញ មុខព្រួញតាមកងមួយៗហ្នឹង។ តែ គាត់មិនជាអ្នកឃោរឃៅទេ គាត់ជាអ្នកស្លូតបូតធម្មតាទេ គាត់មិនមែនចរិតអីណាចាប់មនុស្សចាប់អី យកទៅសម្លាប់ គឺគាត់អត់ទេ ណួយ ហ្នឹង។

**ស៖** តើលោកអាចបញ្ជាក់បានទេ គាត់ប្រធានមុខព្រួញនៅទីកន្លែងណា? លោកអាចបញ្ជាក់បានទេ?

[១១:៤៣:៥៣]

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា គាត់ជាប្រធានមុខព្រួញតាមការគេចាត់តាំងទៅអ៊ីចឹង។ ឧបមាថា ឥឡូវមុខព្រួញហ្នឹង ដូចខ្ញុំទៅជាមួយគាត់ហ្នឹង មុខព្រួញទៅត្រពាំងពោន ទៅកន្លែងមួយកន្លែងអ៊ីចឹងទៅ។ ដល់ទៅមួយខែ ឬក៏កន្លះខែអ៊ីចឹងទៅ រួចមុខព្រួញហ្នឹងទៅ យើងចាប់ទៅខាងវាលឃ្លងណាអ៊ីចឹងទៅ។ ដូច្នេះមុខព្រួញហ្នឹងគឺវាមានច្រើន ហើយបន្ទាប់ពីហ្នឹងទៅ យើងមករាយប៉ាយមកទៅ មកទៅខាងវត្តថ្មី វត្តអីហ្នឹង អាហ្នឹងតាមតែកន្លែងណាដែលគេត្រូវធ្វើខ្លាំងហ្នឹង គឺកងចល័តពួកតំបន់ហ្នឹង គឺទៅកន្លែងនុំងសម្រុកធ្វើកន្លែងនុំង។ ឲ្យថាទីតាំងពិតប្រាកដ វាអត់ គ្រប់កន្លែងតែម្តង។

**ស៖** អ៊ីចឹងលោកអាចបញ្ជាក់ទេ ថាតើគាត់ជាប្រធានកងចល័ត មុខព្រួញហ្នឹងប្រចាំនៅឃុំ ឬក៏ស្រុក ឬក៏នៅតំបន់ណា លោកអាចបញ្ជាក់បានទេ?

**ឆ៖** គាត់មិនមែនជាប្រធានមុខព្រួញតំបន់ ឬក៏ប្រធានមុខព្រួញស្រុកអីទេ ក៏ប៉ុន្តែគាត់ជាប្រធានមុខព្រួញ ទទួលតាមកងមួយៗ តាមភូមិមួយៗ។ ដូចមួយក្នុងឃុំពាមជីកងខ្ញុំហ្នឹងទៅ កាលណាទៅការដ្ឋាននៅកន្លែងណាទៅ គាត់ហ្នឹងគឺជាអ្នកទទួលខុសត្រូវរួមក្នុងមួយឃុំពាមជីកងហ្នឹង គ្រប់រោងបាយហ្នឹង គឺគាត់ជាអ្នកទទួលខុសត្រូវ។

**ស៖** តើគាត់ចេះអានអក្សរទេ? លោកអាចបញ្ជាក់ ហើយលោកធ្លាប់អានអក្សរអ្វីឲ្យគាត់ស្តាប់ដែរឬទេ?

**ឆ៖** រឿងខ្លះគាត់ចេះដែរ ប៉ុន្តែចេះតិចតួច។ ជួនណាទៅអាឯកសារណាដែលត្រូវមិនចាំបាច់មិនត្រូវគេលាក់ការណ៍ហ្នឹងទៅ គេឲ្យខ្ញុំហ្នឹងជួសសរសេរជួយអីទៅណា។ អាហ្នឹងការងារដែលធម្មតាៗដូចជាចល័តប៉ុន្មាន ប្រុសប៉ុន្មាន ស្រីប៉ុន្មាន អាណាឈឺប៉ុន្មាន អីប៉ុន្មានហ្នឹង ជួនណាគេឲ្យខ្ញុំចម្លងឲ្យគេទៅ។ តែអាការងារសម្ងាត់គេ គេលាក់ការណ៍គេ គេមិនដែលឲ្យខ្ញុំដឹងទេ។ អាហ្នឹងខ្ញុំសូមបញ្ជាក់អ៊ីចឹង។

[១១:៤៦:០៨]

**ស៖** ចង់សួរបញ្ជាក់ឲ្យច្បាស់បន្តិច ថាតើលោកធ្លាប់អានលិខិតអ្វីមួយដែលពាក់ព័ន្ធទៅនឹងចាមដែរទេ ជូនលោក ណូយ ហ្នឹង ដើម្បីឲ្យគាត់ស្តាប់? លោកមានធ្លាប់អានលិខិតណាមួយជូនគាត់ស្តាប់ទេពាក់ព័ន្ធទៅនឹងចាម?

**ឆ៖** លិខិតដែលអានហ្នឹង ខ្ញុំអត់ដែលបានទេ។ ប៉ុន្តែគ្រាន់ថាដូចខ្ញុំជម្រាបអ៊ីចឹង វាក្នុងកងចល័តគឺយើងមានអ្នកជិតស្និទ្ធជាមួយគ្នាហ្នឹង ហើយអ្នកជិតស្និទ្ធហ្នឹង ក៏នៅជាមួយគាត់អ៊ីចឹងទៅ គេគ្រាន់តែបាននិយាយថា គេឱ្យធ្វើស្ថិតិប្រជាពលរដ្ឋចាមនៅក្នុងកងចល័តហ្នឹងប៉ុន្មាននាក់ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន។ អាហ្នឹងដែលឮ តែឃើញលិខិតតែម្តង ខ្ញុំអត់ដែលឃើញទេ។ គេមិនឱ្យយើងដឹងទេ អារឿងហ្នឹង ប៉ុន្តែគ្រាន់ថា ជាពាក្យសម្តី ឬគោលការណ៍ដែលគេផ្តល់ព័ត៌មានឱ្យយើងតគ្នាៗមក អាហ្នឹងមាន។

**ស៖** អ៊ីចឹងខ្ញុំសូមអនុញ្ញាតលោកប្រធាន ដើម្បីអានឃ្លាមួយដែលជាឯកសាររបស់លោក ដែលលោកផ្តល់ការសម្ភាសទៅដល់អ្នកស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេត ដែលមានលេខ E3/5527 ហើយជាខ្មែរគឺ ERN 00418575 ហើយជាផ្នែកខាងក្រោយនៃឯកសារនេះតែម្តង ខ្ញុំអត់មាន អត់បានផ្ទៀតផ្ទាត់ ERN ជាភាសាអង់គ្លេស និងជាភាសាបារាំងទេ ក៏ប៉ុន្តែវាជាផ្នែកខាងក្រោយនៃឯកសារនេះតែម្តង។ នៅក្នុងនោះ គេបានសួរលោកថា៖ “តើបញ្ហានោះ ត្រូវបានផ្សព្វផ្សាយដោយផ្ទាល់មាត់ ឬដោយលាយលក្ខណ៍អក្សរ? ឆ្លើយ លោកថា៖ ប្រធានកងចល័តនោះឈ្មោះ ណូយ មានសំបុត្រនោះ តែគាត់មិនសូវចេះអាន គាត់បានយកសំបុត្រមកឱ្យខ្ញុំអាន។ សំណួរបន្ត៖ តើសំបុត្រនោះនិយាយអំពីអ្វីខ្លះ? ចម្លើយ៖ សំបុត្រនោះសរសេរថា ឱ្យស្រង់បញ្ជីជនជាតិចាមភាគតិច ដើម្បីឱ្យដឹងថា ស្រីប៉ុន្មាន ប្រុសប៉ុន្មាន។ ក្នុងសំបុត្រនោះ មិនបាននិយាយថា តើត្រូវធ្វើអ្វីខ្លះមកលើជនជាតិចាមនោះទេ។ សំបុត្រនោះត្រូវចុះហត្ថលេខាដោយ ភាព ដែលជាអនុប្រធានស្រុកដែលទើបតែងតាំងថ្មី។ ភាព នេះជាប្រពន្ធរបស់កាន។”

អ៊ីចឹងខ្ញុំចង់សួរបញ្ជាក់លោក ថាតើបន្ទាប់ពីខ្ញុំអានអ្វីដែលលោកបានផ្តល់ការសម្ភាសទៅដល់សហព្រះរាជអាជ្ញា -- អ៎! អ្នកស៊ើបអង្កេតនោះ ថាតើលោកអាចនឹកឃើញឡើង វិញទេ ថាតើលោកមានធ្លាប់បានអានសំបុត្រណាមួយសម្រាប់ឱ្យ ណូយ ហ្នឹងស្តាប់ដែរឬទេ ពាក់ព័ន្ធទៅនឹងលិខិតចេញពី ភាព មក?

[១១:៤៩:១៥]

**ឆ៖** ពីបញ្ហារឿងសំបុត្រដែលបានអាន ពីរឿងករណី គេឱ្យស្រង់ស្ថិតិបងប្អូនចាមហ្នឹង អាហ្នឹងខ្ញុំដូចជាថា ខ្ញុំដឹង ក៏ប៉ុន្តែខ្ញុំអត់បានអានសំបុត្រហ្នឹងទេ ក៏ប៉ុន្តែ នៅក្នុងកងចល័តជាមួយគ្នា ដូចខ្ញុំជម្រាបអ៊ីចឹងវាមានអ្នកជិតស្និទ្ធជាមួយ ណូយ ហ្នឹង ហើយជិតស្និទ្ធជាមួយខ្ញុំហ្នឹង។ ហើយក្រោយ ព្រោះអង្គាល់ហ្នឹង ខ្ញុំអត់សូវចាប់អារម្មណ៍អារឿងសំបុត្រស្នាមអីទេ ក៏ប៉ុន្តែគ្រាន់តែខ្ញុំឃើញគេមើលសំបុត្រអីអ៊ីចឹង

ទៅ គេ ឈ្មោះដែលនៅជាមួយខ្ញុំហ្នឹង ដែលធ្វើការជាមួយគ្នានេះ បានប្រាប់ថា គេឲ្យស្រង់ស្ថិតិបងប្អូនចាមហ្នឹង ប្រុសដោយប្រុស ស្រីដោយស្រី បងប្អូនចល័តហ្នឹងណ៎ា។ តែករណីដែលគេយកទៅធ្វើអីៗ ខ្ញុំអត់បានដឹងទេ គ្រាន់តែនិយាយអ៊ីចឹង។ ហើយការដែលបានអានផ្ទាល់ហ្នឹង ខ្ញុំអត់បានអានផ្ទាល់ទេ ប៉ុន្តែថាមិនបានផ្ទាល់ ក៏ដូចផ្ទាល់ដែរ ព្រោះមនុស្សដែលអានសំបុត្រ និងខ្ញុំហ្នឹង គឺមនុស្សជំនិតជាមួយគ្នា រឿងអីក៏អត់អាចលាក់បាំងគ្នាបានដែរ។ ខ្ញុំសូមជម្រាបអ៊ីចឹង។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសួរចំណុចចុងក្រោយរបស់ខ្ញុំ ខ្ញុំនឹងមិនចំណាយពេលយូរទៀតទេ។ តើលោកធ្លាប់រៀបអាពាហ៍ពិពាហ៍នៅក្នុងសម័យខ្មែរក្រហមដែរទេ?

**ឆ៖** ខ្ញុំធ្លាប់បានរៀបអាពាហ៍ពិពាហ៍ជាមួយប្រពន្ធខ្ញុំហ្នឹងនៅក្នុងសម័យខ្មែរក្រហម។ ពីឆ្នាំ ១៩៧៦ គឺខ្ញុំបានរៀបអាពាហ៍ពិពាហ៍ដោយខ្មែរក្រហមហ្នឹងគេចាប់យើងឲ្យការណ៎ា។ ហើយក្នុងដែលការជាមួយខ្ញុំហ្នឹង គឺជាលើកទី១ហើយដែលនៅក្នុងឃុំពាមជីកងហ្នឹង ហើយចំនួនអ្នកដែលត្រូវរៀបការហ្នឹង វា២៨នាក់ ស្មើនឹង២៨គូ។ គេចាប់អ៊ីចឹងទៅ គេឲ្យយើងការជាមួយពីណា យើងការទៅ។ ហើយការៗហ្នឹង ក៏មិនមែនទៅការឯណានេះ គេគ្រាន់តែឲ្យអង្គុយកៅអីទន្ទឹមៗគ្នាអ៊ីចឹងទៅ គេនិយាយឲ្យយើងស្ដាប់ពីស្ទីឯណាឯណី ស្ទីទៅ ហើយគេមានធ្វើម្ហូបម្ហាទទួលយើងទៅ រួចទៅ ចប់ទៅ ទៅផ្ទះទៅ។ អាហ្នឹងប៉ុណ្ណឹង អត់មានរឿងអីផ្សេងពីហ្នឹងទៀតទេ។ ការការនេះ ក៏មិនមែនដោយសារ យើងព្រមព្រៀង ថាខ្ញុំស្រឡាញ់នារីហ្នឹង។ គេអត់សួរយើងផង គេចាប់មក ចាប់ដាក់ៗទៅ គ្រាន់តែហូបចុកអីរួចទៅ ទៅផ្ទះធម្មតាទៅ ប៉ុណ្ណឹង។

[១១:៥១:៤០]

**ស៖** តើលោកអាចបញ្ជាក់បានទេ ជាការរៀបការមួយដែលលោកស្ម័គ្រចិត្តដែរឬទេ?

**ប្រធានអង្គជំនុំ៖**

កុំទាន់ៗ!

**លោក សេង ស៊្រុន៖**

**ឆ៖** ចំពោះខ្ញុំអ៊ីចេះ ពីរឿងខ្ញុំវាដោយឡែក ក៏ប៉ុន្តែរឿងអ្នកដទៃទៀតគឺអត់បានស្ម័គ្រចិត្តទេ។ ដូចរឿងខ្ញុំ ខ្ញុំបាន បើនិយាយទៅ ខ្ញុំប្រពន្ធខ្ញុំដែល អាប៉ុល ពត ឲ្យរៀបការហ្នឹង គឺបានចាស់ទុំអីចូលស្ដីដណ្ដឹងអ៊ីចឹងទៅណា ក៏ប៉ុន្តែពេលនុ៎ងគេបិទ អត់ឲ្យមានយើង អត់មានការទេ។ ហើយចំពោះខ្ញុំហ្នឹង គេឲ្យការជាមួយប្រពន្ធខ្ញុំដែលដណ្ដឹងហ្នឹង តែចំពោះអ្នកដទៃទៀតគឺអត់ទេ។ គេអត់ទាំងប្រាប់ឈ្មោះផង គឺ

ច្រើនណាស់។ ក្នុង២៨គូហ្នឹង អ្នកដែលគេចាប់បង្ខំឲ្យការហ្នឹង វាប្រហែលជា២៥ ទៅ២៦នាក់ អ្នកដែលចំៗ អាគូវាដែលដណ្តឹងស្រាប់ហ្នឹង វាមានតែមួយពីរទេ។ បាទហ្នឹងខ្ញុំជម្រាបអ៊ីចឹង។ សុទ្ធតែការបង្ខិតបង្ខំ ខ្លះអត់ទាំងដឹងខ្លួនផង។

**លោក ពេជ អង្គ៖**

អ៊ីចឹងអរគុណហើយលោកដែលបានឆ្លើយចំពោះសំណួររបស់ខ្ញុំ។ លោកប្រធានខ្ញុំអរគុណចំពោះការផ្តល់ឱកាសនេះ។ សូមអរគុណ។

[១១:៥២:៥៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណៗលោកលោកសាក្សី។ ឥឡូវនេះដល់ពេលសម្រាក់ថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតទៅដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងមួយកន្លះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះ ឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៥៣ នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣២:០២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ តទៅនេះ ផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តី។ ដំបូងនេះ ផ្តល់វេទិកាទៅក្រុមសហមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម សហការីទាំងអស់។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជម្រាបសួរលោកសាក្សី។ ខ្ញុំមានសំណួរខ្លះៗ សួរទៅកាន់លោកនៅថ្ងៃនេះ។ ដំបូងខ្ញុំសូមសួរលោកអំពី មឿន។ ព្រឹកមិញនេះលោកបានឆ្លើយថា ខ្លួនលោកផ្ទាល់ មិនបានឃើញការសម្លាប់ប្រជាជនណាមួយដោយផ្ទាល់ នៅក្នុងវត្តនោះទេ ហើយលោកបានឮថា គេសម្លាប់នេះគឺតាមរយៈ មឿន។ តើវាត្រឹមត្រូវដែរឬក៏អត់ទេ បើសិនជាខ្ញុំនិយាយថា បើសិនណាជាលោកមិនបានដឹងពី មឿន ទេ លោកមិនដឹងថា មានគេសម្លាប់ចាមនៅក្នុងវត្តនេះទេ មែនឬក៏អត់ទេ?

[១៣:៣៣:៤៣]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

ខ្ញុំគិតថា ការសួរបែបឲ្យសាក្សីឆ្លើយដោយស្មានៗនេះ គឺមិនត្រឹមត្រូវទេ។ វាជាសំណួរឧបមានវិធី មិនត្រឹមត្រូវទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំខ្លាចតែខ្ញុំមិនយល់ថា មិនដឹងជាជំទាស់ដោយរបៀបណាទេ ប៉ុន្តែខ្ញុំព្យាយាមសួរអំពីការដឹងរបស់គាត់ ពាក់ព័ន្ធទៅនឹងការចោទប្រកាន់ទៅលើការសម្លាប់ជនជាតិចាមនៅវត្តអូរត្រកួន ព្រោះគាត់ដឹងនេះ គឺគាត់ឮសួរមកពីមនុស្សម្នាក់ឈ្មោះ មឿន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** បើសិនណាជា មឿន មិនប្រាប់គាត់ទេ គឺថាគាត់មិនដឹងទេ ថាចាមដែលគេចាប់ទៅហ្នឹង

គឺគេសម្លាប់នៅទីនោះទេ?

[១៣:៣៤:៥៣]

**លោក សេង ស៊្រុន៖**

**ឆ៖** ខ្ញុំសូមជម្រាបលោកមេធាវីការពារក្ដីថា បញ្ហាដែលខ្ញុំបានដឹងព័ត៌មាននេះ គឺវាមិនមែនជាព័ត៌មានគ្រាន់តែជាការស្រមើស្រមៃ ឬក៏ជាព័ត៌មានមិនពិតទេ។ ថ្វីត្បិតខ្ញុំមិនបានឃើញផ្ទាល់ភ្នែកមែន ក៏ប៉ុន្តែឈ្មោះ មឿន និងខ្ញុំហ្នឹង គឺជាមិត្តភក្តិជិតស្និទ្ធ និយាយទៅគឺថា យើងស្គាល់គ្នាយូរយារនៅកន្លែងវត្តអូរត្រកួនហ្នឹង។ ដូច្នេះ មឿន ហ្នឹងក៏គាត់មិនមែនជាអ្នកគ្រាន់ថា ឮតាមគេដែរ គឺគាត់បានចូលរួមទៅសម្លាប់បងប្អូនជាតិចាមហ្នឹងដោយផ្ទាល់ដែរ ព្រោះគាត់ជាសមាជិកសន្តិសុខនៅក្នុងវត្តហ្នឹង។ តែពេលថ្ងៃគាត់ឡើងត្នោត ដល់ពេលយប់ ពេលមានសម្លាប់ប្រជាពលរដ្ឋអ៊ីចឹងទៅ គាត់ក៏បានចូលរួមទៅដែរ។ ដូច្នេះការដែលគាត់មកប្រាប់ខ្ញុំនេះ មិនមែនបើកចំហជាសាធារណៈទេ។ ដូចលោកជ្រាបស្រាប់ហើយសម័យ ប៉ុល ពត គឺកាលណាបើយើងនិយាយអីឮដល់គេ គឺយើងក៏ត្រូវស្លាប់ដូច។ ដូច្នេះវាជាការសម្ងាត់ដោយសារតែគាត់មានការស្និទ្ធស្នាលជាមួយខ្ញុំហ្នឹងទៅណា៎ គាត់ប្រាប់ទៅ មិនមែនគាត់ដើរប្រាប់គេពេញតែភូមិទេ។ អាហ្នឹងខ្ញុំសូមជម្រាបបញ្ជាក់អ៊ីចឹង អាករណីហ្នឹង។ ហើយការដែលគាត់បានរ៉ាយរ៉ាប់ប្រាប់ខ្ញុំនេះ គឺវាច្រើនៗមែនទែន បើសិនជាខ្ញុំឆ្លើយពីរថ្ងៃក៏អត់អស់ដែរ រឿងបញ្ហាខ្មែរក្រហមដែលចាប់ពីខ្ញុំជួបនៅសម័យខ្មែរក្រហមមក ទាល់នឹងដាច់ឆ្នាំ៧៩ គឺច្រើនណាស់។ ក៏ប៉ុន្តែករណីរឿងខ្លះយើងអាចភ្លាត់ យើងអាចបាត់ការចងចាំ។ ឧទាហរណ៍ថា មនុស្សយើងវាមិនមែនចាំគ្រប់រឿងទេ សូម្បីតែនៅក្នុងគ្រួសារតូចមួយ ឧបមារថាសម្ល ១០ថ្ងៃមុនយើងហូបសម្លអីក៏យើងភ្លេចដែរ យើងអត់ដឹងទេ។ ដូច្នេះការហ្នឹងខ្ញុំក៏វាមិនអាចថា រៀបរាប់បានសព្វបែបដែរ ក៏ប៉ុន្តែករណីដែលខ្ញុំឮនេះ ក៏ដូចខ្ញុំបានឃើញផ្ទាល់ដែរ ព្រោះបញ្ហាដែលគេនិយាយហ្នឹង គឺមើលទៅវាឃើញការពិតទាំងអស់។ ព្រោះបានថាការពិត ព្រឹត្តិការណ៍ដែលខ្ញុំនាំបងប្អូនចាមចូលក្នុងវត្តហ្នឹង ខ្ញុំឃើញជាក់ស្តែងនឹងភ្នែកតើ! កូនចៅបងប្អូនចាមខ្លះដែលតូចៗគ្នាឡើងលើជណ្ដើរមិនរួចហ្នឹង វាចាប់គ្រវាត់ចាប់គ្រវែង បោះទៅទទឹងទទែង ដូចដុំថ្ម ដុំឥដ្ឋហ្នឹង ហើយកម្លាំងដល់ពេលសម្លាប់នុ៎ង វាមានអីគួរអស្ចារ្យ ដូចខ្ញុំជម្រាបហ្នឹង។ ខ្ញុំសូមបំភ្លឺប៉ុណ្ណឹងបាទ។

[១៣:៣៧:២៨]

**សៈ** ខ្ញុំយល់អ្វីដែលលោកកំពុងតែឆ្លើយលោកសាក្សី។ ឥឡូវនេះ យើងនៅចំពោះមុខតុលាការដែលកំពុងតែអនុវត្តតាមផ្លូវច្បាប់ អ៊ីចឹងឯងបានខ្ញុំស្វែងរកអំពីប្រភពនៃការដឹងរបស់លោក ពាក់ព័ន្ធទៅ

នឹងការចោទប្រកាន់ថា មានការសម្លាប់ជនជាតិចាម ពិតប្រាកដតែម្តង។ លោកបានឆ្លើយថា មឿន បានប្រាប់លោក តើមានប្រភពណាផ្សេងទៀត ដែលលោកអាចជម្រាបជូនតុលាការដើម្បីបញ្ជាក់ថា វាមានភាពស៊ីសង្វាក់គ្នាដែរឬទេ? តើមានប្រភពណាគួរឲ្យជឿជាក់បានក្រៅពី មឿន នេះទេ?

**ឆ៖** វាមានប្រភពផ្សេងៗទៀត វាមានច្រើន មិនមែនថាអត់ទេ។ មានអ្នកដែលជាចុងភៅនៅក្នុងកន្លែងសន្តិសុខហ្នឹង គឺអ្នកនុំងជាជំនិតជាមួយម្តាយក្មេកខ្ញុំហ្នឹង ក៏គាត់ជា អង្គាល់នុំងជាកូនធម៌ម្តាយក្មេងខ្ញុំហ្នឹង ហើយមានរឿងអីៗហ្នឹង គាត់យកមកនិយាយប្រាប់ម្តាយក្មេងខ្ញុំក៏ ក៏ប៉ុន្តែក្នុងបញ្ហាហ្នឹងគឺលាក់ការណ៍ទេ មិនបើកចំហជាសាធារណៈទេ ព្រោះគាត់នៅក្នុងនុំង កាលណាបែកធ្លាយរឿងអីសម្ងាត់ចេញមកក្រៅទៅ ដឹងដល់គេទៅ គាត់ហ្នឹងក៏អាចស្លាប់ដែរ។ ដូច្នេះ វាមិនមែនមានតែម្នាក់ហ្នឹងទេ គឺប្រភពនេះហ្នឹងវាច្រើន ក៏ប៉ុន្តែអ្នកខ្លះទៅប៊ាននិយាយទៅ អ្នកខ្លះក៏មិនប៊ាននិយាយទៅ។ ហើយដល់ពេលដែលដាច់៧៩ហ្នឹង អ្នកខ្លះដែលធ្លាប់នៅរស់នៅជាមួយពួកសន្តិសុខនៅក្នុងវត្តអូរត្រកួនហ្នឹង បាននិយាយជាចំហតែម្តង ពីហេតុការណ៍ដែលគាត់ឃើញគាត់អីហ្នឹង ក៏ប៉ុន្តែពីមុនមក គាត់អត់និយាយទេ ដល់ដាច់ទៅគាត់និយាយ។ ដល់គាត់និយាយមក ព្រឹត្តិការណ៍ដែលជាប់ពីរឿងដែលគាត់និយាយហ្នឹង កាលពីសម័យ ប៉ុល ពត នៅគ្រប់គ្រងមុនឆ្នាំ៧៩ហ្នឹង គឺវាអត់ខុសគ្នាពីឈ្មោះ មឿន ហ្នឹងបានបំភ្លឺប្រាប់ខ្ញុំហ្នឹង គឺដូចគ្នាទាំងអស់។

[១៣:៣៩:៤៦]

**ស៖** អ្វីដែលលោកកំពុងតែនិយាយនេះ ព័ត៌មាននោះ គឺថាព័ត៌មានក្រោយឆ្នាំ១៩៧៩។ ខ្ញុំចង់ដឹងប្រភពព័ត៌មានជាក់ស្តែង ដូចលោកបានឆ្លើយចំពោះឈ្មោះ មឿន នេះជាដើម។ល។ អ៊ីចឹងសំណួរខ្ញុំៗសួរពីចុងភៅវិញម្តង។ តើចុងភៅម្នាក់នេះឈ្មោះអ្វីដែរ? ហើយចុងភៅនេះបានឃើញអ្វីដែរ?

**ឆ៖** ចុងភៅស្ត្រីម្នាក់ហ្នឹងឈ្មោះៗ គេពិតប្រាកដខ្ញុំអត់ដឹងទេ ប៉ុន្តែគេហៅឈ្មោះ វីន គេហៅមិត្តវីនៗ ហ្នឹង គាត់ជាចុងភៅនៅកន្លែងសន្តិសុខហ្នឹង ហើយ វីន ហ្នឹងជាកូនធម៌ម្តាយក្មេកខ្ញុំហ្នឹង។ ហើយពេលដែលគាត់មិនទាន់ដល់ពេលស្លអីហ្នឹង គាត់ឧស្សាហ៍ចេញទៅក្រៅហ្នឹង ទៅលេងជាមួយម្តាយក្មេកខ្ញុំអ៊ីចឹងទៅណ៎ា។ ហើយគាត់បាននិយាយពីរឿងហ្នឹងខ្លះៗ ក៏ប៉ុន្តែគាត់បានហាមផ្តាច់ថា កុំឲ្យម្តាយក្មេកខ្ញុំហ្នឹងនិយាយរឿងហ្នឹងប្រាប់គេ។ កាលណាបើដឹងដល់ប្រធានសន្តិសុខទៅ គេនឹងអាចចាប់ខ្លួនគាត់ ឬក៏សម្លាប់គាត់ ដោយសារគាត់យកការសម្ងាត់ ដែលគេលាក់ការណ៍ហ្នឹងយកមកប្រាប់ដល់ប្រជាពលរដ្ឋដែលនៅៗខាងក្រៅហ្នឹង។

**ស៖** តើចុងភៅនេះ -- ចុងភៅដែលនិយាយនេះ និយាយក្នុងឆ្នាំ៧៧ ប្រាប់ម្ដាយក្មេកលោក ឬក៏និយាយក្រោយឆ្នាំ១៩៧៩ទេ?

[១៣:៤១:៣៩]

**ឆ៖** ស្ត្រីដែលនិយាយហ្នឹង កាលក្រោយពីឆ្នាំ៧៩ គាត់ក៏និយាយដែរ ក៏ប៉ុន្តែពីមុនក៏គាត់និយាយដែរ។ ហើយបើចង់ដឹងការពិត មានសាក្សីមួយ សព្វថ្ងៃគាត់នៅខាងព្រែកដំបូក ស្រុកស្រីសន្ធរ ឈ្មោះ យ៉ាត គាត់ក៏ជាចុងភៅដែរ ចុងភៅស្រីនៅហ្នឹងដែរ។ គាត់អាចដឹងហេតុការណ៍ច្រើននៅក្នុងវត្តអូរត្រកួននេះ។

**ស៖** តើចុងភៅទាំងពីរនាក់នេះ សព្វនេះនៅរស់ទាំងពីរឬ?

**ឆ៖** មួយឈ្មោះ វីន ហ្នឹង ខ្ញុំអត់ដឹងថាស្លាប់ ឬរស់ទេ ព្រោះគាត់អត់មានស្រុកកំណើតនៅហ្នឹងទេ។ ចែឈ្មោះ យ៉ាត ហ្នឹងគឺគាត់រស់នៅ សព្វថ្ងៃគឺគាត់នៅរស់ទេ នៅក្នុងឃុំព្រែកដំបូក ស្រុកស្រីសន្ធរ គាត់មានជីវិតរស់នៅទេសព្វថ្ងៃហ្នឹង។

**ស៖** នៅពេល មឿន ប្រាប់លោកនូវអ្វីដែលបានកើតឡើងចំពោះប្រជាជនចាម ដែលថាលោកនេះ ក៏បានចូលរួមក្នុងការចាប់ខ្លួនចាមទាំងនោះ។ តើលោកមានបានប្រាប់ទៅប្រពន្ធរបស់លោកអំពីអ្វីដែល មឿន ប្រាប់លោកទេក្នុង -- លោកប្រាប់ទៅប្រពន្ធលោកក្នុងថ្ងៃតែមួយ ឬថ្ងៃណាមកបន្ទាប់មកទៀតនោះ នូវអ្វីដែល មឿន ប្រាប់លោក?

[១៣:៤៣:១៩]

**ឆ៖** ការដែលឈ្មោះ មឿន ប្រាប់ខ្ញុំហ្នឹង គឺធម្មតាប្ដីប្រពន្ធយើងតែងមានមនោសញ្ចេតនា ពេលយើងសម្រាកអីអ៊ីចឹងទៅ ខ្ញុំក៏បាននិយាយប្រាប់ប្រពន្ធខ្ញុំហ្នឹងថា ចាមគេចាប់ទៅយប់មិញហ្នឹង គេសម្លាប់ចោលអស់ហើយ។ រួចដល់ តាមពិតទៅគេសម្លាប់មែន មិនមែនថាគេមិនសម្លាប់ទេ គឺគេសម្លាប់យប់ចាប់ហ្នឹងតែម្ដង។ ខ្ញុំប៉ានធានាអះអាងថា គេសម្លាប់ពេលគេចាប់ទៅហ្នឹងពេលម៉ោងប្រាំពីរហ្នឹង គេសម្លាប់ទាល់តែជិតម៉ោងដប់ពីរយប់។ ខ្ញុំប៉ានធានាខុសត្រូវ ខ្ញុំអត់ចេះនិយាយអីក្រៅពីការពិតទេ សូម្បីតែខ្ញុំមិនឃើញផ្ទាល់នឹងភ្នែក ខ្ញុំមិនទៅអ្នករៃ ក៏ប៉ុន្តែឈ្មោះ មឿន ហ្នឹង និងខ្ញុំហ្នឹងដូចមនុស្សតែមួយហ្នឹង គឺរឿងអី ក៏គាត់ប្រាប់ខ្ញុំដែរនៅក្នុងកន្លែងហ្នឹង។ តាំងពីរឿងចាប់រំលោភនារីៗ ប្រជាជនថ្មីដែលស្អាតៗហ្នឹង មុននឹងយកទៅវៃចោល វារំលោភស្រាតខោស្រាតអាវ រួចបានវាសម្លាប់ចោល ក៏និយាយ។ និយាយគ្រប់រឿងទាំងអស់ អ៊ីចឹងបានខ្ញុំថា បើសិនជារឿងរ៉ាវដែលខ្ញុំអង្គុយគិតទៅ ខ្ញុំបំភ្លឺនៅក្នុងតុលាការ

ពីរថ្ងៃក៏អត់អស់ដែរបាទ។ ខ្ញុំសូមជម្រាបប៉ុណ្ណឹង។

**ស៖** ប៉ុន្តែសំណួររបស់ខ្ញុំពេលដែល មឿន ប្រាប់មកលោក តើក្រោយមកលោកមានបានប្រាប់ទៅប្រពន្ធរបស់លោកនូវអ្វីដែល មឿន ប្រាប់លោកទេ? ដូចជាថា ប្រាប់ទៅប្រពន្ធថា នែ៎! មឿន នេះប្រាប់មកខ្ញុំថាអីចេះ ប្រាប់មកខ្ញុំថាអីចុះ។ លោកមានប្រាប់ប្រពន្ធលោកទេ?

[១៣:៤៥:00]

**ឆ៖** ដូចខ្ញុំបានជម្រាបព្រឹកមិញហើយ គឺថា ធម្មតាប្ដីប្រពន្ធ យើងការលាក់កំបាំងម៉េចក៏ដោយក៏យើងតែងតែនិយាយប្រាប់ដែរ ព្រោះថា ប្រពន្ធខ្ញុំហ្នឹង និងបងប្អូនចាមហ្នឹងធ្លាប់ទៅធ្វើការជាមួយគ្នាអីចឹងទៅ។ ដល់ពេលចាប់ទៅ តែងតែសួរដេញដោលគ្នាទៅវិញទៅមក ខ្ញុំក៏បានប្រាប់រឿងរ៉ាវ នេះទៅដែរ រឿងប្រពន្ធខ្ញុំអីថា ដូចយាយម៉ាស់ យាយអីហ្នឹងគាត់ធ្វើការជាមួយឯងហ្នឹង គេវៃចោលអស់ហើយ ខ្ញុំប្រាប់អីចឹងទៅណ៎ា។ រួចប្រពន្ធខ្ញុំក៏បានសួរខ្ញុំថា ឯងដឹងពីណាមក? ថា មិត្តមឿន ហ្នឹងប្រាប់ ព្រោះមឿន នោះក៏វាធ្លាប់មកលេងផ្ទះខ្ញុំអីអីចឹងដែរណ៎ា ដូចថាមិត្តភក្តិជិតស្និទ្ធ គេនៅសន្តិសុខមែន ប៉ុន្តែជួនណាគេហៅខ្ញុំទៅនឹងវត្តដែរ ប៉ុនខ្ញុំអត់ហ៊ានទៅទេ គេហៅចូលទៅកន្លែងវាហ្នឹងណា ខ្ញុំក៏អត់ហ៊ានទៅដែរ គ្រាន់ថា ក្រៅៗ ជួបគ្នាទៅ និយាយទៅ ទៅក្នុងវត្ត ខ្ញុំអត់ដែលហ៊ានទៅទេ។

**ស៖** បាទ ខ្ញុំនឹងសួរសំណួរងាយៗទៅលោក។ នៅពេល មឿន ប្រាប់លោកថា ប្រជាជនចាមត្រូវបានគេសម្លាប់ តើលោកប្រាប់ទៅប្រពន្ធរបស់លោកក្នុងថ្ងៃតែមួយ ឬក៏ថ្ងៃក្រោយៗមកទៀតទេ?

**ឆ៖** ពេលដែលខ្ញុំប្រាប់ប្រពន្ធខ្ញុំហ្នឹង ក្រោយពីព្រឹត្តិការណ៍គេសម្លាប់នោះ ឧបមាថា គេសម្លាប់យប់ហ្នឹង ខ្ញុំអត់ទាន់បានព័ត៌មានទេ ដល់ភ្លឺឡើងបានខ្ញុំដឹង។ ហើយពេលយប់ទី២ហ្នឹង បានខ្ញុំនិយាយប្រាប់ប្រពន្ធខ្ញុំហ្នឹង ពីរឿងគេសម្លាប់បងប្អូនចាមអស់ហ្នឹង។ រួចខ្ញុំបាននិយាយប្រាប់ប្រពន្ធខ្ញុំថា ក្នុងចំណោមបងប្អូនចាមនៅឃុំពាមជីកងហ្នឹង មានការរត់រួចតែពីរនាក់ទេ អាម៉ាន និងកូន តាហ៊ីម ព្រោះពីរនាក់ហ្នឹង វាជាគូប្ដីប្រពន្ធអីចឹងទៅណ៎ា ក៏ប៉ុន្តែពេលនោះ អត់ទាន់បានរៀបការអីទេ ពីរនាក់ហ្នឹងគ្រាន់តែជាគូដណ្ដឹងអីចឹងទៅ ដល់ពេលរត់ទៅ រត់ទៅទាំងពីរនាក់ហ្នឹងទៅ។ ហើយករណីដែលសម្លាប់បងប្អូនចាមហ្នឹង មិនមែនតែនៅក្នុងឃុំពាមជីកងទេ ខ្ញុំសូមជម្រាបលោកមេធាវី ដូចនៅក្នុងឃុំអង្គរបានដែលមានបងប្អូនចាម ក៏គេយកមកសម្លាប់នៅវត្តអូរត្រកួនហ្នឹងដែរ។ ក៏ប៉ុន្តែខ្ញុំអត់បានដឹងថា បងប្អូនចាមដែលនៅក្នុងឃុំអង្គរបានហ្នឹង វាមានចំនួនប៉ុន្មាន ខ្ញុំអត់ដឹងទេ ព្រោះខាងអង្គរបានហ្នឹង បងប្អូនចាមក៏ច្រើនដែរ។

**ស៖** លោកសាក្សី ប្រពន្ធរបស់លោកនៅរស់រានមានជីវិតទេ សព្វថ្ងៃ?

**ឆ៖** ប្រពន្ធរបស់ខ្ញុំស្លាប់តាំងពីឆ្នាំ១៩៨១។

[១៣:៤៨:០០]

**ស៖** លោកដឹងថា មឿន ប្រាប់តែលោកម្នាក់គត់ ឬក៏ មឿន ប្រាប់ទៅអ្នកដទៃទៀតដែរ នូវព្រឹត្តិការណ៍ហ្នឹង?

**ឆ៖** ខ្ញុំអត់បានដឹងថា គេប្រាប់ទៅពីណាទៀត ព្រោះជំនាន់នុំង សូម្បីតែគេប្រាប់ពីណា ក៏គេមិនដែលប្រាប់យើងដែរ។ ចំពោះខ្ញុំ និង មឿន ហ្នឹងគឺបាននិយាយទល់មុខគ្នា ឈរនៅក្បែរគ្នា ឈរទល់គ្នាហ្នឹង។ ប៉ុន្តែនិយាយហ្នឹង ក៏មិនមែននិយាយជាចំហដែរ និយាយមើលមុខមើលក្រោយដែរ។

**ស៖** ព្រឹកមិញនេះលោកសាក្សី សហព្រះរាជអាជ្ញាបានសួរលោកអំពីចំនួនមនុស្សដែលគេចោទប្រកាន់ថាត្រូវបានសម្លាប់ ហើយសួរលោកអំពីចំនួនតួលេខខ្មោចដែលរកឃើញនៅក្នុងរណ្ដៅនេះ លោកថា មានដល់រាប់ពាន់ឯណោះ។ សំណួរហ្នឹងសួរថា តើមានដល់រាប់ពាន់ទេ? បើសិនជាមិនច្រឡំទេ គឺលោកឆ្លើយថា មានមិនដល់៣០.០០០ទេ គឺត្រឹមតែ១៥.០០០ទេ ត្រឹមត្រូវដែរ ឬអត់ទេ?

**ឆ៖** ចំពោះប្រជាជនដែលគេយកទៅសម្លាប់នោះ តាមគេសរសេរជាឯកសារ សព្វថ្ងៃនៅវិមានសាកសពហ្នឹង គេដាក់ប្រជាជនដែលគេសម្លាប់ហ្នឹង៣៥.០០០នាក់។ តែខ្ញុំនៅកន្លែងនោះ គឺតាំងពីខ្ញុំ១ឆ្នាំរហូតដល់ខ្ញុំអាយុ អង្កាល់នុំងខ្ញុំអាយុនៅជាង៣០ឆ្នាំទេ។ វាមិនអាចដូចពាក្យគេថា អានេះ យើងនិយាយដូចខ្ញុំនិយាយថា ភាសាមនុស្សយើងនិយាយឲ្យត្រឹមត្រូវ។ កុំនិយាយ គេថា១០ គេថាងាប់តែ១០ យើងថា២០ ងាប់២០ យើងថា៥០ អាហ្នឹងវាខុសពីការពិត។ តែបើខ្ញុំនៅក្បែរនុំងហើយ ខ្ញុំអ្នកស្រាវជ្រាវដែររឿងបញ្ជី១០០អីហ្នឹង ខ្ញុំគាស់បានទាំងពាងឯកសារហ្នឹងទៀតនោះ។ ហើយខ្ញុំអ្នកគាស់ ខ្ញុំអត់ឃើញឯកសារនោះគេដាក់ថា៣៥.០០០ដែរ ចុះអ្នកដែលមិនបានឃើញសោះ ចេះតែថា ប្រឌិតទៅជា៣៥.០០០នាក់ក្នុងវត្តអូរត្រកួន។ ហ្នឹងខ្ញុំអត់ជឿទេ ព្រោះអាហ្នឹងខ្ញុំជឿជាសិទ្ធិខ្ញុំទេ ប៉ុន្តែគេអ្នកនិយាយជាសិទ្ធិគេទេ។ ក៏ប៉ុន្តែតាមការប៉ាន់ស្មានខ្ញុំ ដូចខ្ញុំនិយាយអ៊ីចឹង ខ្ញុំថាអត់មាន ខ្ញុំថាប្រហែលជា១៥.០០០ ឬក៏២០.០០០ចុះ។ បើឲ្យឡើងទៅលើទៀត គឺអត់មានទេ។

[១៣:៥០:៥៨]

**ស៖** ខ្ញុំនឹងត្រឡប់មកពីចំនួនតួលេខនេះក្រោយវិញ។ នៅក្នុងកិច្ចសម្ភាសន៍របស់លោកជាមួយការិយាល័យសហព្រះរាជអាជ្ញាគឺ E3/5302, ERN អង់គ្លេស 00210489, ខ្មែរ 00623188 ហើយ

បារាំង 00623189។ នៅត្រង់នេះលោកឆ្លើយថា សូមដកស្រង់៖ “មឿន បានប្រាប់ខ្ញុំក្នុងឆ្នាំ១៩៧៨ ថា ប្រជាជនប្រហែល៣០.០០០នាក់ត្រូវបានគេសម្លាប់នៅអូរត្រកួន។” ដូច្នេះហាក់បីដូចជាថា តួលេខ ៣០.០០០នាក់នេះ ក៏ជាតួលេខមួយដែល មឿន ប្រាប់ទៅលោក។ អ៊ីចឹងមែនទេ?

**ឆ៖** ចំពោះតួលេខដែលថាឈ្មោះ មឿន បានប្រាប់ខ្ញុំហ្នឹង មឿន ហ្នឹងខ្ញុំនិយាយទៅដូចថា អត់ដែលទាក់ទងរឿងបញ្ហាប្រាប់ថា ២០.០០០, ៣០.០០០នេះទេ គឺខ្ញុំដូចជាអត់ដែល មឿន និយាយប្រាប់ទេ គឺអត់ដែលដឹងតួលេខហ្នឹងផង។ តួលេខហ្នឹង ខ្ញុំដឹងៗដោយសារគេដាក់នៅលើជញ្ជាំងវិមានសាកសពនោះទេ។ ហើយចេះតែនិយាយតៗគ្នាមកថា ៣៥.០០០ៗ។ អ្នកខ្លះទៅអះអាងថា អីយកផ្អែកឯកសារ ក៏ប៉ុន្តែតាមការពិត វាអត់មានឯកសារអីទាំងអស់ គ្រាន់តែជាការប៉ាន់ស្មានតើ។

[១៣:៥៣:៥៨]

**ស៖** ខ្ញុំដកស្រង់សម្ដីលោកចេញពីឯកសារ គឺកំណត់ហេតុនៃការស្ដាប់ចម្លើយពីការិយាល័យសហព្រះរាជអាជ្ញា។ ខ្ញុំមិនដឹងពន្យល់ថាយ៉ាងដូចម្ដេចទេ ក៏ប៉ុន្តែនៅក្នុងឯកសារនិយាយថា មឿន ដែលជាអ្នកប្រាប់ទៅលោក ថាប្រជាជនប្រហែល៣០.០០០នាក់ ត្រូវបានគេសម្លាប់ចោលនៅវត្តអូរត្រកួន។ អ៊ីចឹងសំណួរខ្ញុំសួរថា នៅក្នុងឆ្នាំ៧៨ មឿន មិនដែលប្រាប់លោកអំពីតួលេខទេ អ៊ីចឹងឬក៏អត់ទេ?

**ឆ៖** បាទ នៅក្នុងឆ្នាំ១៩៧៨ មឿន និងខ្ញុំហ្នឹងអត់ដែលបាននិយាយអីពីរឿងតួលេខ តួអីណាអត់បាន ដូចខ្ញុំវា ដូចថា អត់ដែលបានទំនាក់ទំនងអីពីរឿងតួលេខ។ ដឹងតែពីរឿងដែលគេកាប់សម្លាប់ គេអីម៉េច គេវ៉ៃគេអី អាហ្នឹងមាននិយាយ។ តែពីរឿងតួលេខថា ប៉ុន្មាន ៣០.០០០, ២០.០០០ហ្នឹង ដូចខ្ញុំអត់ដែលបានទាក់ទងជាមួយ មឿន ហ្នឹង។

**ស៖** ឥឡូវខ្ញុំសួរលោកបន្តបន្តិចទៀតអំពីឈ្មោះ មឿន។ លោកបានឆ្លើយថា មឿន ផ្ទាល់នេះ គឺជាអ្នកដែលចូលរួមពាក់ព័ន្ធក្នុងការសម្លាប់មនុស្ស។ តើ មឿន នេះបានចូលរួមសម្លាប់ជនជាតិចាមទាំងនោះដែរទេ?

**ឆ៖** តាមការដែលគាត់និយាយជាមួយខ្ញុំហ្នឹង គឺក្នុងការសម្លាប់បងប្អូនចាមហ្នឹង គាត់មានចំណែកចូលរួមដែរ។ មិនមែនថាបងប្អូនចាមទេ សូម្បីតែសម្លាប់បងប្អូនប្រជាជនខ្មែរ ប្រជាជនថ្មី ប្រជាជន៧៥ហ្នឹង ក៏គាត់ចូលរួមគ្រប់ការដែលទៅសម្លាប់ហ្នឹង គឺគាត់មានការចូលរួមទាំងអស់។

**ស៖** ប៉ុន្តែតាមដែលខ្ញុំយល់ មឿន ក៏ជាអ្នកឡើងត្នោតដូចលោកដែរ ត្រឹមត្រូវទេ?

**ឆ៖** បាទ គាត់ជាអ្នកឡើងត្នោតដែរ ក៏ប៉ុន្តែគាត់ឡើងតែពេលថ្ងៃទេ ដល់ពេលយប់ គាត់មាន

ឡើងឯណា។

[១៣:៥៥:៣៧]

**ស៖** ដូច្នេះ តើលោកអាចឆ្លើយនឹងសំណួរខ្ញុំបានទេ ថាតើដោយសារអ៊ីចេះ គាត់គឺថាជាអ្នកឡើងដើមត្នោតធម្មតាទេ ក្លាយទៅជាឃាតករដ៏ចម្បងម្នាក់នៅក្នុងវត្តនុ៎ង តើលោកពន្យល់ឲ្យល្អិតបន្តិចបានទេ?

**ឆ៖** បាទ ករណីហ្នឹងអ៊ីចេះ។ ខ្ញុំសូមជម្រាបលោកជាមេធាវីថា កាលពីសម័យ ប៉ុល ពត ប្រជាពលរដ្ឋគ្រប់រូប ទាំងគេទាំងខ្ញុំ មិនមែនធ្វើការងារតែមួយមុខៗទេ ដូចខ្ញុំអ៊ីចឹង ខ្ញុំជួនណាគេឲ្យទៅរកត្រីទៅ ជួនណាគេឲ្យទៅដាំបន្លែទៅ ជួនណាគេឲ្យមកឡើងត្នោតមក តាមពេលតាមវេលា។ ហើយចំពោះមឿន ហ្នឹងពីដើមមកគាត់ជាសមាជិកកងសន្តិសុខនៅក្នុងវត្តហ្នឹង ក៏ប៉ុន្តែគាត់ ជំនាញគាត់ គាត់ចេះធ្វើត្នោត។ ដូច្នេះនៅក្នុងវត្តហ្នឹង គេក៏ឲ្យគាត់ឡើងត្នោតទៅ។ ពេលថ្ងៃគេអត់ឲ្យគាត់ធ្វើអីទេ គេឲ្យគាត់ឡើងត្នោត។ ដល់ពេលយប់ គាត់ធ្វើការគាត់ធម្មតាអ៊ីចឹងទៅ តាមវិជ្ជាជីវៈរបស់គាត់អ៊ីចឹងទៅ ក្នុងនាមជាសន្តិសុខហ្នឹង។ មិនមែនថាគាត់អ្នកឡើងត្នោតហើយ គេឲ្យទៅធ្វើសន្តិសុខទេ គាត់ជាកងសន្តិសុខនៅក្នុងវត្តអូរត្រកួនហ្នឹងដែរ ក៏ប៉ុន្តែដល់ពេលថាគាត់ចេះឡើងត្នោត គេឲ្យគាត់ឡើងត្នោតទៅពេលថ្ងៃហ្នឹង គេអត់ឲ្យគាត់ធ្វើអីទេ។ ហើយអ្នកដទៃទៀតដែលអត់មាន អត់ចេះឡើងត្នោតហ្នឹង គេប្រគល់នាទីអីឲ្យផ្សេងៗទៅ ដើរទៅតាមការដ្ឋានការអី នាំមនុស្សនាំអីមកអ៊ីចឹងទៅ។ ពេលដែលប្រធានកង ប្រធានអីគេចាប់មនុស្សអ៊ីចឹងទៅ គេឲ្យខាងសន្តិសុខហ្នឹង ជាមួយពួកដាវវែងហ្នឹង គេនាំមនុស្សមកទៅ។ ចំពោះ មឿន ហ្នឹងគេទុកឲ្យគាត់ឡើងត្នោតតែមួយមុខទេ នៅក្នុងវត្តហ្នឹង។ ហើយដល់ពេលយប់តួនាទីគាត់ ធម្មតាដូចគេ ដូចឯងអ៊ីចឹងដែរ។ ខ្ញុំសូមជម្រាបប៉ុណ្ណឹង។

[១៣:៥៧:៤៦]

**ស៖** ប៉ុន្តែអ្នកយាម គឺថាជាមនុស្សដែលខុសពីអ្នកសម្លាប់មនុស្ស។ អ៊ីចឹងលោកចង់ថា មឿន នេះមិនត្រឹមតែឡើងត្នោត ហើយមិនត្រឹមតែបំពេញនាទីជាអ្នកយាម គឺថា គឺជាឃាតករទៀតផង។ លោកចង់ថាអ៊ីចឹង?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាល់ទាន់ឆ្លើយតប!

អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ។

**លោក ឌេល លីសាក់៖**

ខ្ញុំយល់ឃើញថា មេធាវីការពារក្តី សំណួរនាំមុខហើយ។ អ្នកយាមនៅមន្ទីរសន្តិសុខមួយៗ មានមុខងារច្រើនៗ មិនមែនត្រឹមតែចាំយាម ឬឡើងប៉ុណ្ណោះទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំយល់ឃើញថា យើងមិនទាន់បានស្តាប់ភស្តុតាងពាក់ព័ន្ធទៅនឹងសំណួររបស់ខ្ញុំនៅឡើយទេ ពាក់ព័ន្ធទៅនឹងអូរត្រកួន។ អ៊ីចឹងហើយបានខ្ញុំសួរទៅគាត់ ថាតើអ្នកណានៅខាងក្នុង អ្នកណានៅខាងក្រៅ។ អ៊ីចឹងសំណួរខ្ញុំនេះ ខ្ញុំយល់ថា ត្រឹមត្រូវហើយ។ តែយ៉ាងណា ខ្ញុំរៀបចំឡើងវិញ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ត្រឹមត្រូវទេ ដែលថា មឿន មិនមែនបំពេញការងារជាអ្នកឡើងត្នោត ឬក៏ជាអ្នកយាមទេ ប៉ុន្តែក៏ជាអ្នកសម្លាប់មនុស្សដែរ អ៊ីចឹងមែនទេ?

[១៣:៥៩:១០]

**លោក សេង ស្រ៊ុន៖**

**ឆ៖** បាទ ខ្ញុំឆ្លើយអ៊ីចឹងមែន ព្រោះថា មឿន ហ្នឹងគាត់មិនមែនថាត្រឹមតែឡើងត្នោតទេ ពីដំបូងគាត់ជាកងសន្តិសុខនៅក្នុងវត្តអូរត្រកួនហ្នឹង ក៏ប៉ុន្តែដល់មួយជំនាន់នុ៎ង បើអ្នកណាចេះរកត្រី គេចាត់ទៅឲ្យរកត្រីទៅ ពេលថ្ងៃអ៊ីចឹង។ ដល់ពេលយប់ចូលមកក្នុងកន្លែងវិញ គឺធ្វើតាមតួនាទីសន្តិសុខហ្នឹង សម្លាប់មនុស្ស ចងមនុស្ស នាំមនុស្សទៅសម្លាប់ គឺធម្មតា។ ដូច មឿន អីហ្នឹង ថ្ងៃគាត់ឡើងត្នោតទៅ ដល់ពេលយប់ការងារគាត់ទៅជាមួយគេ ជាមួយឯងអ៊ីចឹងទៅ។ មិនតែប៉ុណ្ណឹងទេ បើសិននិយាយកងសន្តិសុខនៅក្នុងវត្តអូរត្រកួន ភ្នែកមួយណាក៏ក្រហមដែរ ព្រោះគេៗយកប្រមាត់មនុស្សហ្នឹង យកទៅត្រាំ ដើម្បីផឹក។ គេថាផឹកអាហ្នឹងទៅវា ដូចថាសាហាវដូចខ្លា វាអត់ចេះគិត អាណិតអាសូរអីទេ គឺត្រូវវាយៗ ត្រូវបោកៗអាហ្នឹងអ៊ីចឹង។ ហើយភ្នែកពួកសន្តិសុខហ្នឹង មួយណាដូចមួយណា មឿន ហ្នឹងបើខ្ញុំ បើកុំតែថាមនុស្សវាស្គាល់គ្នារាល់ថ្ងៃ បើឃើញភ្នែកគាត់ ខ្ញុំក៏គួរឲ្យខ្លាចដែរ។

**ស៖** តើភ្នែក មឿន ក្រហមដែរឬអត់ទេ?

**ឆ៖** បាទ ភ្នែក មឿន ហ្នឹងក្រហមដូចភ្នែកយើងអ្នកស្រវឹងស្រាហ្នឹង ក្រហមអ៊ីចឹងទៅ។ មើលទៅដូចខ្ញុំនិយាយអ៊ីចឹង បើកុំតែស្គាល់គ្នា បើសិនថាមិនធ្លាប់ទំនាក់ទំនងគ្នាហ្នឹង សូម្បីតែមុខគេយើងមិនហ៊ានមើលផង មើលទៅគួរឲ្យខ្លាច។

[១៤:០១:០៧]

**ស៖** តើលោកចាំទេថា មឿន នុំងគាត់ផឹកស្រវឹងគ្រប់ពេល ឬក៏គាត់ផឹកស្រវឹងតែពេលខ្លះទេ?

**ឆ៖** គាត់អត់មានស្រវឹងអីផង គាត់គ្រាន់តែភ្នែកគាត់ក្រហម គាត់អត់មានស្រវឹង គឺធម្មតាហ្នឹង មានស្រវឹងអីទ្រេតទ្រោតអី អត់មានទេ គ្រាន់តែភ្នែកគាត់ហ្នឹង វាខុសពីភ្នែកយើងធម្មតាបាទ។ ហើយ ដល់ខ្ញុំសួរទៅ គាត់ថា "បងឯងចង់ហូបដែរអ្វីស្រាគេត្រាំប្រមាត់មនុស្ស?" ខ្ញុំថា "អើ! ខ្ញុំអត់ចេះហូប ស្រាផង ខ្ញុំផឹកអីកើត ខ្ញុំអត់ផឹកទេ" និយាយអ៊ីចឹងទៅ។ មឿន ហ្នឹងឧស្សាហ៍និយាយជាមួយខ្ញុំដែរ រឿង ច្រើនណាស់ដែលគាត់និយាយ អើ! ជួបគ្នារាល់ថ្ងៃចេះតែនិយាយទៅ ប៉ុន្តែគាត់និយាយតែជាសម្ងាត់ដែរ ទេ មិនមែននិយាយជាចំហឲ្យគេឮគ្រប់គ្នាទេ។

**ស៖** ដើម្បីបញ្ជាក់ឲ្យច្បាស់ ថាតើភ្នែកក្រហមហ្នឹង តើភ្នែកក្រហមរបស់ មឿន ហ្នឹងដោយ សារតែគាត់ផឹកទឹកត្នោតជូរច្រើនពេក ឬមួយក៏ដោយសារអីផ្សេងទេ?

**ឆ៖** ខ្ញុំវាពិបាកពន្យល់ដែរ អារឿងភ្នែកក្រហមហ្នឹង ព្រោះខ្ញុំវាមិនចេះផឹក ខ្ញុំមិនដឹងនិយាយថា ម៉េច។ ក៏ប៉ុន្តែគាត់គ្រាន់តែប្រាប់ខ្ញុំថា អ្នកដែលចូលរួមសម្លាប់មនុស្សហ្នឹង គេឲ្យផឹកប្រមាត់មនុស្ស ដើម្បីដូចថា ឲ្យចិត្តហ្នឹងវាក្លាហានទៅណ៎ា គេឲ្យផឹកប្រមាត់មនុស្ស។ ចិត្តវាដាច់ ចិត្តវាគ្មានចេះអាណិត អាសូរអ៊ីចឹងទៅ។

**ស៖** ប្រសិនបើខ្ញុំយល់មិនខុសទេ គឺថាមានមនុស្សពីរនាក់ទៀត នៅក្នុងកង -- នៅក្នុងក្រុមអ្នក ឡើងត្នោតរបស់លោក តើអ៊ីចឹងមែនទេ?

**ឆ៖** ក្នុងចំណោមអ្នកឡើងត្នោតមួយក្រុមខ្ញុំហ្នឹងមានបួននាក់ ហើយសព្វថ្ងៃគាត់រស់នៅទាំង អស់ អត់ទាន់ពីណាស្លាប់ទេ។ មានគ្នាបួននាក់។

[១៤:០៣:២៨]

**ស៖** តើ មឿន ហ្នឹងគាត់ធ្លាប់និយាយប្រាប់តែលោកម្នាក់ឯងទេ ឬក៏គាត់និយាយប្រាប់អ្នកឡើង ត្នោតក្នុងក្រុមលោក ពីរនាក់ផ្សេងទៀតនោះ?

**ឆ៖** ខ្ញុំអត់បានដឹងទេ ពីរឿងគេប្រាប់អ្នកផ្សេងទៀត ក៏ប៉ុន្តែអ្នកផ្សេងទៀត គឺគេទៅឡើង ឆ្ងាយៗអ៊ីចឹងទៅណ៎ា អត់មាននៅជុំវិញហ្នឹងទេ មានតែខ្ញុំទេ ដែលឡើងត្នោតនៅជាប់ និងជុំវិញបរិវេណ វត្តហ្នឹង គឺមានតែត្នោតខ្ញុំទេ។ ខ្ញុំហ្នឹងគេឲ្យឡើង២៥ដើម គឺនៅជុំវិញវត្តហ្នឹងតែម្តង ហើយចំពោះអ្នក ដទៃទៀត គេឲ្យឡើងនៅតាមវាលស្រែ នៅតាមជិតៗភូមិ ខាងកើតឆ្ងាយពីវត្តហ្នឹងប្រហែលជា៥០ម៉ែត្រ

ឬក៏១០០ម៉ែត្រអីអ៊ីចឹងទៅ។ តែខ្ញុំទេនៅជិតវត្តប្រហែលជាៗ២០ម៉ែត្រជុំវិញវត្តហ្នឹង គឺខ្ញុំឡើងនៅម្ដុំតែម្ដង។ ហើយត្នោត មឿន និងត្នោតខ្ញុំហ្នឹងជួរនៅជាប់គ្នាហ្នឹង ត្នោតហ្នឹងត្នោតខាងខ្ញុំទេ ក៏ប៉ុន្តែដល់នេះទៅ ខាងវត្តហ្នឹងគេមកសុំត្នោតហ្នឹងបីដើម បីដើមហ្នឹង ខាងកើតជាប់នឹងវត្តហ្នឹង ហើយតមកគឺខ្ញុំ។ ខ្ញុំក៏ឲ្យគេបីដើមទៅត្នោតហ្នឹងនោះ គេសុំបីដើមធ្វើទឹកដើម្បីធ្វើស្ករសម្រាប់បម្រើក្នុងអង្គភាពសន្តិសុខគេនុ៎ង។ មិនមែនខ្ញុំអ្នកឲ្យទេ អាហ្នឹងប្រធានកងគេទេ អ្នកឲ្យនោះ គេគ្រាន់តែប្រាប់យើងថា ត្នោតនេះខាងសន្តិសុខគេសុំហើយ។

[១៤:០៥:០២]

**ស៖** ចាតើពីរនាក់ទៀតនៅក្នុងក្រុមអ្នកឡើងត្នោតជាមួយលោកហ្នឹង គាត់ពីរនាក់ទៀតហ្នឹងជាសន្តិសុខដែរ ឬមួយក៏មានតែ មឿន ទេដែលជាសន្តិសុខម្នាក់ឯង?

**ឆ៖** ចំពោះអ្នកឡើងត្នោតផ្សេងទៀតនោះក៏គាត់--

**ប្រធានអង្គជំនុំ៖**

កុំអាល១ទាន់ឆ្លើយ!

សូមអញ្ជើញលោកសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថា មេធាវីមិនមែនកំពុងតែសួរទេ គាត់កំពុងតែធ្វើការសន្និដ្ឋានដោយខ្លួនឯង។ ព្រោះថានៅក្នុងកំណត់ហេតុស្តាប់ចម្លើយ គឺបានបញ្ជាក់ច្បាស់អំពីបីនាក់ទៀត ដូច្នេះខ្ញុំគិតថា ប្រហែលជាមេធាវីការពារក្ដីគាត់គ្រាន់តែធ្វើការសន្និដ្ឋានតែប៉ុណ្ណោះ។ ដូច្នេះមេធាវីការពារក្ដីគួរតែត្រូវបញ្ជាក់ឲ្យបានច្បាស់ថា មឿន គឺជាផ្នែកនៃក្រុមអ្នកឡើងត្នោតហ្នឹងដែរ ឬមួយក៏យ៉ាងម៉េច?

**លោក វ៉ិចទ័រ កូប៉េ៖**

ប្រសិនបើខ្ញុំចាំមិនខុស ខ្ញុំបានកត់ត្រាទុករួចហើយ ប៉ុន្តែខ្ញុំនឹងកែសម្រួល។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី លោកបាននិយាយអំពីកងអ្នកឡើងត្នោតដែលមានបួននាក់ គឺលោក មនុស្សពីរនាក់ទៀត ហើយម្នាក់ទៀតគឺ មឿន។ តើអ៊ីចឹងមែនទេ?

[១៤:០៦:២៧]

**លោក សេង ស្រ៊ុន៖**

**ឆ៖** ខ្ញុំបានបញ្ជាក់ហើយថា ក្នុងកងសន្តិសុខហ្នឹងមានតែ មឿន ម្នាក់ទេ។ ចំពោះក្រុមខ្ញុំឡើងត្នោតជាប្រជាជនហ្នឹង គឺមានគ្នាបួននាក់។ ដូច្នេះបួននាក់ហ្នឹង គឺអត់មានទៅជាក្រុមសន្តិសុខអីទេ គឺជាប្រជាជនតាមសហករណ៍។ ហើយចំពោះអ្នកឡើងត្នោតម្នាក់ទៀត មឿន ហ្នឹងគឺគាត់អ្នកឡើងត្នោតក្នុងអង្គភាពសន្តិសុខហ្នឹង។ ខ្ញុំសូមជម្រាបអ៊ីចេះ ពួកខ្ញុំឡើងត្នោតហ្នឹងមានគ្នាបួននាក់ ហើយ មឿន ហ្នឹងគេមានតែម្នាក់គេទេនៅក្នុងកងសន្តិសុខហ្នឹង ព្រោះខ្ញុំវាមិនមែនកងសន្តិសុខណា ខ្ញុំជាប្រជាជនតើ។

**ស៖** ខ្ញុំយល់ហើយលោក។ ថាតើមានក្រុមអ្នកឡើងត្នោតផ្សេងទៀត ក្រៅពីក្រុមរបស់លោកដែលមានគ្នាបួននាក់ហ្នឹងដែរឬទេ?

**ឆ៖** បាទ ក្រុមឡើងត្នោតហ្នឹងវាមាន ក៏ប៉ុន្តែនៅក្នុងភូមិខ្ញុំហ្នឹង ភូមិសំបួរមាស "ក" ហើយអង្កាល់នុំងគេចែកជាពីរ គេមានសំបួរមាសលើ សំបួរមាសក្រោម។ ហើយខ្ញុំហ្នឹងគឺស្ថិតនៅ រស់នៅក្នុងសំបួរមាសក្រោម គេខាងសំបួរមាសលើនោះ គេឡើងមួយក្រុមគេដែរ ប៉ុន្តែខ្ញុំអត់ដឹងថាគ្នាប៉ុន្មាននាក់ទេ ប៉ុន្តែខ្ញុំអាចស្គាល់ ក៏ប៉ុន្តែដឹងរាប់អស់ មិនអស់ មិនដឹងទេ ខាងនុំងប្រហែលជាបីទៅបួននាក់ដែរឡើងត្នោតមួយកង។ ខាងខ្ញុំហ្នឹងមួយរោងបាយហ្នឹង បួននាក់ ខាងគេខាងកើតនុំងបួននាក់ដែរ។ ប៉ុន្តែនៅឆ្ងាយពីគ្នាប្រហែលជា៥០០ម៉ែត្រ។ រោងបាយលើ និងក្រោមហ្នឹងចម្ងាយប្រហែល៥០០ម៉ែត្រ។

[១៤:០៨:៣៣]

**ស៖** ថាតើ មឿន ហ្នឹងគាត់ធ្លាប់និយាយប្រាប់អ្នកដទៃនៅក្នុងកង ឬក៏នៅក្នុងក្រុមអ្នកឡើងត្នោតតើគាត់ធ្លាប់ប្រាប់អ្នកផ្សេងនៅក្នុងក្រុមអ្នកឡើងត្នោត អំពីហេតុការណ៍នៅវត្តអូរត្រកួនដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបទេ! សំណួរនេះគឺលោកសាក្សីឆ្លើយពីរដងហើយ ជាប្រភេទសំណួរច្រំដែល។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំកំពុងតែនិយាយអំពីកងផ្សេងទៀតលោកប្រធាន ប៉ុន្តែខ្ញុំនឹងបន្តទៅមុខ។

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបទេ!

យើងសម្រេចហើយ សំណួរច្រំដែល។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សំណួរចុងក្រោយសម្រាប់ប្រធានបទមួយនេះ។ លោកសាក្សី តើលោកអាចពន្យល់បានទេថា ហេតុអ្វីបានជាមានតែលោកម្នាក់ដែល មឿន និយាយប្រាប់អំពីហេតុការណ៍នានានុំង?

[១៤:០៩:៤៦]

**លោក សេង ស្រ៊ុន៖**

**ឆ៖** ខ្ញុំសូមបញ្ជាក់លោកមេធាវីថា ករណីដែលឈ្មោះ មឿន និយាយប្រាប់តែខ្ញុំម្នាក់ហ្នឹង គឺនៅកន្លែងនុំងតាមផ្លូវនុំង អត់មានប្រជាជនណាចេញចូលបានទេ មានតែខ្ញុំម្នាក់គត់ជាអ្នកឡើងត្នោតហ្នឹងអាចចេញ ហើយទាក់ទងនិយាយជាមួយ មឿន នេះបាន។ ចំពោះប្រជាជនធម្មតា គឺតាមផ្លូវនោះ គេបិទមិនឲ្យដើរ ហើយក៏ប្រជាជនខ្លះ គាត់មិនប៉ានដើរផងតាមនុំង គាត់អត់ប៉ានទេ។ ដូច្នេះការទំនាក់ទំនងរវាងខ្ញុំ និង មឿន ហ្នឹង គឺដោយសារ ដូចខ្ញុំបានជម្រាបពីមុនមកហ្នឹង ដោយសារដើមត្នោតវាជាប់គ្នាអ៊ីចឹងទៅ។ ដល់ពេលយើងឡើងទៅបីបួនប្រាំដើមទៅ ហត់ទៅ យើងឈប់សម្រាកអង្គុយទាំងអស់គ្នា យើងចេះតែនិយាយពីរឿងនេះ ពីរឿងនោះទៅ។ ហើយខ្ញុំហ្នឹងក៏មួយ ជំនាន់នោះ ខ្ញុំចង់ដឹងហេតុការណ៍ដែលកើតឡើងអី ខ្ញុំចេះតែលួចសួរទៅ ព្រោះមនុស្សវា ដូចថា បើសិនជាខ្ញុំសួរទៅ សូម្បីខុស សូម្បីត្រូវក៏គេអត់ចាប់ថ្នាក់ដែរ ព្រោះរាប់អានគ្នាដូចថា មិត្តភក្តិអ៊ីចឹងទៅណា។ ប៉ុន្តែខ្ញុំអត់ដែលបានចូលរួមទៅក្នុងមន្ទីរសន្តិសុខអីទេ គ្រាន់តែនៅខាងក្រៅៗ សូម្បីតែឈ្មោះ មឿន ហ្នឹងហៅខ្ញុំចូលទៅលេងអី ក៏ខ្ញុំអត់ប៉ានទៅដែរ ខ្ញុំថា ខ្ញុំអត់ទៅទេ ខ្ញុំនៅត្នោតច្រើនណាស់ ខ្ញុំចេះតែដោះសាអ៊ីចឹងទៅ។ ប៉ុន្តែតាមពិត គឺខ្ញុំមិនចង់ឃើញ មិនចង់អីទាំងអស់នៅក្នុងនុំង។

[១៤:១១:១៨]

**ស៖** តើ មឿន ហ្នឹងធ្លាប់ត្រូវបានគេចាប់ខ្លួន ឬក៏ឃុំខ្លួនអស់មួយរយៈពេលដែរឬទេ?

**ឆ៖** មឿន ហ្នឹងគាត់អត់ដែលបានគេចាប់ខ្លួនទេ ព្រោះគាត់ជាសមាជិកកងសន្តិសុខស្រុកហ្នឹងតាំងពីគាត់នៅខាងសន្ទើមដួច នៅខាងក្នុងឃុំខ្មៅ។ ហើយអ្នកដែលថាតូចតាចៗគ្រាន់តែជាកងសន្តិសុខអីកំប៉ិកកំប៉ុកអ៊ីចឹង គេអត់សម្លាប់ទេ គេសម្លាប់តែអ្នកណាដែលជាមេៗ ដូចជាប្រធាន ប្រធានសន្តិសុខអនុប្រធានអីអ៊ីចឹង អាហ្នឹងគេសម្លាប់។ ដល់កូនចៅតូចៗហ្នឹង គេអត់មានសម្លាប់ទេ វាអត់ខុសពីក្នុងឃុំទេ ក្នុងឃុំអ្នកដែលធ្វើជា គេហៅថា ប្រធានសង្កាត់ ប្រធានអី អនុប្រធានសង្កាត់ហ្នឹង បានត្រូវគេយកទៅសម្លាប់ចោល ហើយដូចជាអ្នកខ្លះ គ្រាន់តែជាកងឈ្លប ជាអីហ្នឹង គឺគេអត់យកទៅសម្លាប់ទេ គេទុក

ប្រើបន្តទៀត។

**ស៖** ឥឡូវនេះ ខ្ញុំនឹងត្រឡប់ទៅនិយាយអំពីហេតុការណ៍នៅពេលដែលគេចាប់ជនជាតិចាមជាច្រើន។ តើ មឿន ធ្លាប់ប្រាប់លោកទេថា អ្នកណាខ្លះដែលបានចូលរួមនៅក្នុងការចាប់ខ្លួនហ្នឹង ក្រៅពី មឿន ខ្លួនឯង? តើមឿន ហ្នឹងធ្លាប់ប្រាប់លោកអំពីឈ្មោះរបស់សន្តិសុខនានា ឬក៏សន្តិសុខផ្សេងទៀតដែលបានចូលរួមក្នុងការចាប់ខ្លួននោះដែរឬទេ?

**ឆ៖** បាទ ខ្ញុំដូចជាបាននិយាយហើយ ការចាប់ខ្លួននេះ គឺមិនមែនកងសន្តិសុខហ្នឹងចេញទៅចាប់ទេ ដូចខ្ញុំបានជម្រាបជូនអ៊ីចឹង គឺក្រុមដាវវែង។ ក្រុមដាវវែងហ្នឹងជាក្រុមដែលគេបង្កើតថ្មីពីឆ្នាំ៧៧ ហ្នឹង គឺពួកហ្នឹងគេអ្នកដើរចាប់។ ពួកសន្តិសុខខាងក្នុងហ្នឹង គេសម្រាប់តែទទួលអ្នកទោស ហើយនិងសម្លាប់។ តែអ្នកដើរចាប់ហ្នឹង គឺក្រុមដាវវែងហ្នឹងគេអ្នកដើរចាប់ ហើយ មឿន ហ្នឹងក៏គាត់អត់ដែលបានទៅដើរចាប់អីដែរ គាត់គ្រាន់តែទទួល អ្នកទទួល អ្នកយកទៅសម្លាប់ អ្នកមើលខុសត្រូវក្រោយពីបានគេចាប់ខ្លួនយកមកដាក់ក្នុងគុក ក្នុងវិហារហ្នឹង។

**ស៖** ប្រហែលជាមានបញ្ហាបកប្រែ។ សំណួររបស់ខ្ញុំមិនមែនចង់សួរថា ថាតើ មឿន ធ្លាប់ប្រាប់លោកអំពីឈ្មោះអ្នកដែលចូលរួមនោះទេ។ គឺមិនមែននិយាយអំពីការចាប់ខ្លួនទេ គឺការសម្លាប់។ លោកនិយាយថា មឿន បានចូលរួមក្នុងការសម្លាប់មនុស្សហ្នឹង សម្លាប់ជនជាតិចាមហ្នឹង ប៉ុន្តែខ្ញុំចង់ដឹងថា តើ មឿន មានប្រាប់លោកថា មានអ្នកណាផ្សេងទៀតចូលរួមក្នុងការសម្លាប់ជនជាតិចាមហ្នឹងដែរឬទេ?

[១៤:១៤:១៥]

**ឆ៖** ក្នុងសំណួរនេះ ខ្ញុំអាចឆ្លើយបានខ្លះ ឆ្លើយមិនបានខ្លះ ព្រោះបញ្ហាដែលយើងអត់ទៅឃើញយើងមិនដឹងថា ពីណាខ្លះទេចូលរួម។ ក៏ប៉ុន្តែអ្នកចូលរួមគឺច្រើន នៅក្នុងកងសន្តិសុខហ្នឹងមានតាំងពីកុមារអាយុ១៥ឆ្នាំ ២០ឆ្នាំ ហើយអ្នកសម្លាប់ហ្នឹង គឺសុទ្ធតែអ្នកជំនាញ ព្រោះគេមាន ដូចថាគេមានធ្វើការប្រលងអីអ៊ីចឹងទៅ អ្នកណាវៃមនុស្សបានច្រើន គេឲ្យធ្វើមេកងអីទៅណ៎ា។ ហើយនៅក្នុងភូមិខ្ញុំហ្នឹង វា អាមួយនោះ វាហាត់ៗទៅគេថា វាជាប់ចំណាត់ថ្នាក់ខាងវៃមនុស្ស។ ក្នុងមួយម៉ោង វាអាចវៃមនុស្សបាន៧០នាក់។ អាហ្នឹងក្មេងទេ ក្មេងអាយុ ប្រហែលជា២០ឆ្នាំទេ នៅក្នុងកងសន្តិសុខហ្នឹង។ ហើយកងសន្តិសុខអ្នកវៃនោះ វាមានអានៅក្នុងវត្តផង វាមានអានៅតាមថ្នល់ផង។ អានៅតាមថ្នល់ហ្នឹង ភាគច្រើនគឺកុមារ។ កុមារហ្នឹង បើនិយាយពីកាំភ្លើងវិញ ស្ពាយកាំភ្លើងអូសដី។ ហ្នឹងក៏វាយកទៅបង្ហាត់ក្នុងការសម្លាប់មនុស្សហ្នឹងដែរ មិនមែនតែពួកសន្តិសុខ។ ពួកសន្តិសុខដែលសម្លាប់មនុស្សហ្នឹង វានៅក្នុង

នោះវា គ្នាវាប្រហែលជា១០នាក់ដែរ នៅក្នុងកងសន្តិសុខហ្នឹង។ ហើយបើតាមខ្ញុំស្គាល់ វាខ្ញុំស្គាល់បាន បីបួននាក់ មឿន ហ្នឹងមួយ និងមួយរស់នៅឃុំព្រែកក្របៅហ្នឹង ខ្ញុំអត់ស្គាល់ទេ ខ្ញុំស្គាល់តែមុខ ហើយ ឈ្មោះ បុត្រ ហ្នឹងមួយ។ អាបុត្រ ហ្នឹងវាជាអនុប្រធាន អាហាន ហ្នឹង។ អនុប្រធាន អាហាន ហ្នឹងប៉ុន្តែ ក្រោយមក អាបុត្រ ហ្នឹងក៏ត្រូវ ហាន ហ្នឹងសម្លាប់ចោលដែរ អនុប្រធាន ព្រោះគេសម្លាប់ប្រធានអី ឃុន ហ្នឹងចោលទៅ គេទុក បុត្រ ហ្នឹងជាអនុប្រធានសន្តិសុខហ្នឹង។ ហើយក្រោយមក ដល់គេទុក បុត្រ ហ្នឹង ដើម្បីចង់ដឹងពីស្ថិតិ ចង់ដឹងពីចំនួនប្រជាពលរដ្ឋអី សភាពការណ៍នៅក្នុងហ្នឹងម៉េចៗ គេទុក បុត្រ ហ្នឹង ប្រើសិន។ ដល់ទុកបានប្រហែលជា អត់បានមួយឆ្នាំទេ ប្រហែលបីបួនប្រាំខែ ប្រាំមួយខែហ្នឹង បន្ទាប់ពី គេសម្លាប់ប្រធានសន្តិសុខឈ្មោះ ឃុន ហ្នឹងទៅ បុត្រ ហ្នឹងក៏គេសម្លាប់ដែរ។ ហើយខ្ញុំបានសួរ មឿន ហ្នឹងទៀតថា "ម៉េចបាន បុត្រ ហ្នឹងគេសម្លាប់?" ថា "សម្លាប់ហ្នឹងព្រោះ អាហាន ហ្នឹងវាស្រឡាញ់នារី ម្នាក់"។ ពីដើមគាត់ជាកូនរដ្ឋមន្ត្រីយើងហ្នឹង ស្អាតៗ គាត់ស្អាតៗណាស់ ខ្ញុំបានឃើញនឹងភ្នែកដែរ ព្រោះ គាត់បានទៅការដ្ឋានជាមួយខ្ញុំ។ បងប្អូនគាត់ឈ្មោះបីនាក់ឈ្មោះ ប្អូនប្រុសឈ្មោះ ដា រួចបងស្រីនោះ ឈ្មោះ ដេត រួចមួយទៀតនោះឈ្មោះអីទេ។ បងប្អូនបីនាក់នោះស្អាតៗមែន។ ហើយដល់ពេលនេះទៅ គេចាប់បីនាក់យកមកវត្តអូរត្រកួន។ បុត្រ ហ្នឹងវាស្រឡាញ់នារីហ្នឹង។ ដល់ស្រឡាញ់នារីហ្នឹងទៅ អាហាន ហ្នឹងវាដឹង អាហ្នឹងវាស្រឡាញ់នារីហ្នឹងដែរ វ៉ៃអានេះហ្នឹងចោលទៅ វ៉ៃ អាបុត្រ ហ្នឹងចោល ទៅ។ បើខ្ញុំចាំ មានតែ អាបុត្រ ហ្នឹងមួយទេ និង មឿន ហ្នឹងទេ ដែលខ្ញុំស្គាល់ បើក្រៅពីហ្នឹង ខ្ញុំអត់សូវ ស្គាល់ទេ ព្រោះគេសុទ្ធតែមកពីស្រុកក្រៅ។ បើសិនជាប្រជាពលរដ្ឋនៅកន្លែងខ្ញុំៗអាចស្គាល់។ ក៏ប៉ុន្តែ ក្មេងៗ ដែលខ្ញុំនិយាយថាវ៉ៃមនុស្សក្នុងមួយម៉ោង ៧០នាក់ហ្នឹង គឺនៅភូមិសំបួរមាស ខ្ញុំហ្នឹងដែរ។ ប៉ុន្តែ ឥឡូវងាប់បាត់ហើយ អានុ៎ង គេបាញ់ចោលបាត់ហើយ។

[១៤:១៧:៥៦]

**ស៖** ខ្ញុំយល់ លោកធ្លាប់បានប្រាប់រឿងនេះទៅអ្នកស៊ើបអង្កេតម្តងរួចមកហើយ។ ហើយតាម ដែលដឹង គឺប្រភពរបស់លោកគឺ មឿន ប៉ុន្តែខ្ញុំចង់ដឹងថាតើ មឿន មានប្រាប់ឈ្មោះសន្តិសុខផ្សេងៗក្រៅពី វុធ ដែលថាអ្នកសន្តិសុខផ្សេងៗទៀតដែលបានចូលរួម ហើយដែលនៅរស់រានមានជីវិតរហូតមកដល់ ពេលនេះ តើ មឿន មានធ្លាប់ប្រាប់លោកដែរឬទេ?

**ឆ៖** រឿងអ្នកសម្លាប់ហ្នឹង មឿង អត់ដែលបាននិយាយប្រាប់ខ្ញុំទេ។ អត់ដែលប្រាប់ថាឈ្មោះ ណាៗ សម្លាប់ គឺអត់ដែលបានប្រាប់ទេ។ អត់ដែលនិយាយ។

**ស៖** ឥឡូវនេះខ្ញុំសួរលោកឲ្យទូលាយបន្តិច។ តើ មឿន ធ្លាប់ប្រាប់ឈ្មោះអ្នកណាម្នាក់ដែលធ្វើការនៅក្នុងវត្តអូរត្រកួន ហើយបុគ្គលហ្នឹងនៅរស់រានមានជីវិតរហូតមកដល់ពេលឥឡូវហ្នឹង ហើយដែលបុគ្គលហ្នឹង គាត់អាចផ្តល់ចម្លើយទាក់ទងទៅនឹងអ្វីដែល មឿន បាននិយាយពីហេតុការណ៍ដែលបានកើតឡើងយប់នោះ? តើលោកអាចប្រាប់ឈ្មោះបានទេ?

**ឆ៖** បាទ ចំពោះសន្តិសុខដែលវាសម្លាប់មនុស្សនៅវត្តអូរត្រកួនហ្នឹង មកសព្វថ្ងៃវាអត់ដឹងថារស់ ឬងាប់ ព្រោះបានខ្ញុំនិយាយអី គ្រាន់តែឮថា ដាច់ភ្លាម គឺវារត់ទៅផ្ទះអស់គ្រប់គ្នាៗទៅ រត់។ អ្នកណានៅស្រុកណា គឺនៅស្រុកហ្នឹងទៅ។ ហើយឈ្មោះហ្នឹង ក៏ខ្ញុំស្គាល់មិនប្រាកដដែរ ព្រោះថា បើសិនជាឈ្មោះដូចសព្វថ្ងៃនេះ ឈ្មោះយើងពិតអ៊ីចឹងទៅ យើងអាចថាយើងស្គាល់បាន។ ក៏ប៉ុន្តែមួយជំនាន់ហ្នឹងគេមិនដាក់ឈ្មោះយើងពិតទេ គេដាក់ឈ្មោះស្អីៗអ៊ីចឹងទៅ។ ឧបមាថាដូច ឧបមាថា តាធុច អ៊ីចឹងតាធុច ឈ្មោះគាត់ដើម កុយ ធួន ដល់គ្មានពីណាស្គាល់ទេ កុយ ធួន គេស្គាល់តែ តាធុចៗ ហ្នឹង។ ហ្នឹងខ្ញុំសូមជម្រាបអ៊ីចឹង ខ្ញុំអត់ស្គាល់ឈ្មោះពិតគេទេ។ បើសិនជាយើងស្គាល់ឈ្មោះពិតគេ យើងអាចស្រាវជ្រាវមនុស្សហ្នឹងឃើញ។

[១៤:២០:១៨]

**ស៖** ខ្ញុំនឹងបន្តទៅប្រធានបទថ្មីមួយទៀត លោកសាក្សី។ លោកបាននិយាយថា លោកបានចូលរួមក្នុងការចាប់ខ្លួនជនជាតិចាមពីឃុំរបស់លោក។ ខ្ញុំមិនយល់ថា ហេតុអ្វីបានជាគេឲ្យលោកជួយក្នុងការចាប់ខ្លួនន៎ុង។ តើគេមានប្រាប់លោកថា ហេតុអ្វីដែរឬទេ ឬមួយក៏ថា អាចដោយសារតែខ្វះមនុស្ស? ដូច្នេះ ខ្ញុំចង់ដឹងថា ហេតុអ្វីបានជាកម្មាភិបាលគេសុំឲ្យលោកជួយក្នុងការចាប់ខ្លួនជនជាតិចាមហ្នឹងទៅវិញ?

**ឆ៖** ខ្ញុំសូមជម្រាបមេធាវីថា ក្នុងការចាប់ខ្លួនបងប្អូនចាមនេះ គឺខ្ញុំអត់បានទៅចាប់គាត់ទេ អត់បានទៅចូលរួមចាប់គាត់ទេ ខ្ញុំអត់ដឹងថា គេប្រើខ្ញុំទៅធ្វើអីផង ខ្ញុំអត់ដឹងទេ។ គ្រាន់តែគេថា ពួកឡើងត្នោតកុំអាលទៅផ្ទះ ទៅៗថ្នល់។ ទៅថ្នល់ ក៏អត់ដឹងថាទៅធ្វើស្អីដែរ។ ដែលពេលៗដែលគេចាប់បងប្អូនចាមចេញមករញ៉េរញ៉ៃហ្នឹង បានខ្ញុំដឹងថា គេចាប់ចាម។ ហើយខ្ញុំហ្នឹង ក៏អត់មានដើរទៅចាប់តាមផ្ទះដែរ គឺសុទ្ធតែពួកដាវវែងទេ ដែលគេចូលចាប់ហ្នឹង។ ខ្ញុំដូចខ្ញុំបានជម្រាបអ៊ីចឹង ខ្ញុំគ្រាន់តែគេឲ្យឈរនៅនឹងផ្លូវហ្នឹង នៅនឹងដើមផ្លូវខាងត្បូងហ្នឹង ដើម្បីកុំឲ្យប្រជាជនចាមហ្នឹងចេញទៅថ្នល់ ឧបមាថាអ៊ីចឹងណ៎ា ព្រោះមុខសញ្ញាគេ គេទៅខាងជើង គេយកប្រជាជនហ្នឹងទៅចូលវត្ត។ ខ្ញុំគេគ្រាន់តែឲ្យឈរអ៊ីចឹង

ហើយខ្ញុំឈរហ្នឹង ក៏ខ្ញុំគ្មានទៅធ្វើការគំរាមកំហែងអីណាដល់បងប្អូនចាមដែរ គឺខ្ញុំឈរចង់ស្រក់ទឹកភ្នែក ដោយសារតែឃើញកូនរង៉េករង៉ាកអីអឺចឹងទៅ។ ហើយគ្នាទើបបាយរួច មកដល់មិនទាន់នឹងបានផ្លាស់ខោអាវផង មកពីធ្វើការមក។ សម័យ ប៉ុល ពត ដូចដឹងស្រាប់ហើយ មិនមែនដូចយើងសម័យឥឡូវ យើងពេលហូបបាយ យើងទៅងូតទឹក សិតសក់អីទេ។ ពេលនុ៎ងឡើងតែពីស្រែមក ទាំងភក់ ទាំងអីហ្នឹង ហើយ ចូលទៅ ចូលកន្លែងតុទៅ។ ណាមកក្រោយ អត់ទៅ អាហ្នឹងអឺចឹង។ ឲ្យគ្នាហូបបាយរួចអឺចឹងទៅ ខ្លះមកដល់ផ្ទះទៅ ងូតទឹកទៅ ខ្លះមកដល់ផ្លាស់ខោអាវទៅ ពេលនុ៎ងក៏ពួកសន្តិសុខហ្នឹងវាទៅដល់ វាចាប់មក អាខ្លះមិនទាន់ទាំងផ្លាស់ខោអាវផង នៅទាំងភក់ ខ្លះចោមពុង រៀបនឹងងូតទឹក មកទាំងចោមពុង វាមិនទាំងឲ្យផ្លាស់ខោអាវផង។ បាទ អាហ្នឹងអឺចឹង។ ថាខ្ញុំចូលរួមចាប់ ខ្ញុំអត់បានដឹងអីទាំងអស់ រឿងចូលរួមចាប់ហ្នឹង។ គ្រាន់តែក្នុងនាមខ្ញុំជាប្រជាជន មួយជំនាន់នុ៎ង តែគេឲ្យទៅណាទៅហើយ ចេះតែទៅហើយ ប៉ុន្តែថាបើសិនជាទៅ ឲ្យសម្លាប់គេ ក៏ខ្ញុំមិនទៅដែរ។ ប៉ុនអានេះ គេគ្រាន់តែទៅឲ្យឈរ គេមានឲ្យធ្វើអី។ ចាប់ គេអ្នកសន្តិសុខ គេមិនមែនទុកចិត្តយើងទេ។ នេះខ្ញុំជម្រាបអឺចឹង ខ្ញុំអត់បានចូលរួមទៅចាប់បងប្អូនចាមទេ។

[១៤:២៣:១៤]

**ស៖** តើលោកមានកាំភ្លើងទេ នៅពេលនោះ?

**ឆ៖** អត់ទេ មានកាំភ្លើងអី ខ្ញុំខ្លួនទទេ។ សូម្បីតែកាំបិតភ្នោត ក៏គេមិនទាំងឲ្យយកទៅផង ទុកនៅកន្លែងរោងបាយ។ គេឲ្យដោះកាំបិតភ្នោតហ្នឹងទុកទៅ រួចទៅថ្នល់ជាមួយគេ។ ទៅនុ៎ងភ័យដែរ ម្នាក់ៗដឹងគេយកទៅម៉េច ខ្លាចគេឲ្យទៅតាមទឹកទន្លេ ក៏មិនដឹង។ គេឲ្យទៅ ចេះតែទៅហើយ ហ៊ានប្រកែកថាខ្ញុំមិនទៅ។ ហើយគេអត់មានប្រាប់យើងថា ទៅចាប់ចាមចាប់អី អត់ប្រាប់ ស្អីក៏អត់និយាយទាំងអស់ យើងអត់ដឹងហេតុការណ៍អីទាំងអស់។

**ស៖** ខ្ញុំសួរសំណួរហ្នឹងដដែលៗ ហើយខ្ញុំគ្រាន់តែឆ្ងល់ថា លោកអត់មានកាំភ្លើងទេ តើគេយកលោកទៅធ្វើអី? តើហេតុអីបានជាគេឲ្យលោកទៅជួយក្នុងការចាប់មនុស្សហ្នឹង?

**ឆ៖** បាទ ជំនាន់នុ៎ង បើនិយាយពីប្រជាពលរដ្ឋ គាត់បាក់ស្បាត។ ហើយពួកសន្តិសុខដែលទៅចាប់បងប្អូនចាមហ្នឹង ក៏អត់មានកាំភ្លើងដែរ គឺអត់មានកាំភ្លើងទេ មានតែដាវទេ អត់មានកាំភ្លើងសោះ គឺដៃទទេ និងដាវតែម្តង អត់មានប្រើកាំភ្លើងប្រើអីទេ ជំនាន់នុ៎ង អត់មាន។ បើសិនជាបងប្អូនចាមគាត់ស្រុះគ្នាគាត់ ធ្វើម៉េចៗ ប្រហែលជារត់រួចខ្លះ ប៉ុន្តែគាត់ដូចថាគាត់បាក់ស្បាតណ៎ា កុំសូម្បីតែគាត់ តែខ្ញុំក៏

បាក់ស្បាតដែរ តែគេលើក ឲ្យលើកដៃចង ឲ្យគេចង មួយជំនាន់នោះ គ្មានកាំភ្លើង គ្មានអីទេ ព្រោះពួកសន្តិសុខដាវវែងហ្នឹង វាអត់មានកាំភ្លើងទេ។ មានតែពួកសន្តិសុខនៅក្នុងវត្ត អាហ្នឹងបានមានកាំភ្លើងជំនាន់នុ៎ង មានតែដាវ។

[១៤:២៥:០០]

**ស៖** ប៉ុន្តែតើគេឲ្យលោកធ្វើអីដែរ? តើលោកធ្វើអ្វីនៅទីនោះ?

**ឆ៖** ខ្ញុំឈរធម្មតាអ៊ីចឹង គ្រាន់តែគេប្រាប់ថា មិត្តឯងនៅឈរត្រង់ហ្នឹង។ ខ្ញុំថាឈរធ្វើអី? នៅតែស្ងៀមទៅ ឈរឲ្យស្ងៀមទៅកុំឲ្យ ក្រែងលោបងប្អូនចាមហ្នឹងរត់ទៅចុះទន្លេចុះអីទៅណ៎ា។ ហើយខ្ញុំឈរហ្នឹង ហើយបងប្អូនចាមក៏គាត់គ្មានរត់ដែរ យកមកដាក់ត្រង់ណា គាត់នៅត្រង់នុ៎ង គាត់គ្មានទៅរត់ទៅអីឯណាគាត់។ ដល់ពេលគេឲ្យនាំទៅអ៊ីចឹង ដើរទៅដើរធម្មតាអ៊ីចឹង ទៅទាំងហ្វូងអ៊ីចឹងទៅ។ បើសិនជា ពេលនុ៎ងបើសិនជាថា បើសិនជាគាត់រត់គេចខ្លួនក៏រួចដែរ គ្មានពីណាដឹងទេ ព្រោះថាវាងងឹតៗ ទម្រាំនឹងទៅវាងងឹត មានពីណាទៅចាប់អារម្មណ៍ទេ ហើយខ្ញុំនៅក្រោយគេ ខ្ញុំដល់ពេលទៅ ខ្ញុំនៅក្រោយគេ ពួកសន្តិសុខគេទៅមុខ ហើយកណ្តាលៗហ្នឹង គឺអត់មានមនុស្សទេ។ តែដោយសារដូចខ្ញុំបាននិយាយអ៊ីចឹងថា មួយសម័យនុ៎ង គេបំបាក់ស្មារតីប្រជាជនយើងនឹងឲ្យខ្លាច តែពាក្យសម្តីហ្នឹង ក៏យើងខ្លាចដែរ។ បើសិនជាពេលនុ៎ង បើខ្ញុំថា បើគាត់រត់អាចរួច មិនមែនមិនរួចទេ។ ប៉ុន្តែគាត់អត់រត់ គាត់ចេះតែដើរតាមគេហៅទៅ គាត់ចេះតែដើរទៅ។

**ស៖** តើលោកធ្វើអ្វីដែរ ឬមួយក៏ ថាតើលោកគ្រាន់តែដើរតាមក្រុមហ្នឹង ឬមួយក៏លោកមានការងារអីផ្សេងទៀត?

[១៤:២៦:២៨]

**ឆ៖** បាទ ខ្ញុំបានជម្រាបច្រើនដងហើយថា ខ្ញុំអត់មានបានធ្វើស្អីទេ នៅក្នុងរបបខ្មែរក្រហមនោះ គឺខ្ញុំអត់មានជាប់សមាសភាពជាស្អីៗ គឺអត់ទេ។ គ្រាន់តែជាប់ជាអ្នកឡើងត្នោត រកត្រី ដាំបន្លែតែប៉ុណ្ណឹង អត់មានទៅជាប់ពាក់ព័ន្ធរឿងការងារអីក្នុងបនប្រល័យពូជសាសន៍នេះ គឺអត់មានទេ។ ពួកខ្ញុំហ្នឹង គេមិនឲ្យធ្វើទេ ព្រោះគេ បើនិយាយរួមទៅសម័យ ប៉ុល ពត សូម្បីតែអ្នកចេះអក្សរ ក៏គេអត់យកដែរ។ គេរកអ្នកណាដែលមិនចេះអក្សរ។ ដូចចេះដឹងដូចខ្ញុំថា ដូចខ្ញុំគេហៅថា ពួកខ្ញុំគេហៅអនុធនសិស្ស វាហៅអ៊ីចឹង។ ហើយម្ល៉ោះហើយ គេអត់មានប្រគល់ការងារឲ្យយើងទេ បានតែត្រឹមគេប្រើទេ តួនាទីគឺអត់មានអីទាំងអស់បាទ។

**ស៖** លោកបានបញ្ជាក់អម្បាញ់មិញនេះ ដូច្នេះ តើឪពុករបស់លោកមានតួនាទីអ្វីដែរ ត្រឹមឆ្នាំ ៧៩? ថាតើគាត់មានតួនាទី ឬក៏គាត់ធ្វើការនៅតាមចេតិយ ឬក៏នៅតាមកន្លែងតម្កល់បូជនីយស្ថាននុ៎ងដែរ ឬទេ?

**ឆ៖** ឪពុកខ្ញុំបាទ គាត់ពីឆ្នាំ៧៩មកហ្នឹង គាត់អត់មានតួនាទីស្អីទេ ក៏ប៉ុន្តែគាត់ចូលចិត្តដើរប្រមូលឆ្អឹង ប្រមូលអីអ៊ីចឹងដាក់ម៉ុអ៊ីចឹងទៅ។ ហើយគាត់គ្រាន់តែជួយខាងសាលារៀន សាលាអីហ្នឹង ការពារសាលារៀនអី ក្មេងរៀនក្មេងអីហ្នឹង ហើយនិងដើរប្រមូលឆ្អឹងប្រមូលអីហ្នឹង គាត់ធ្វើតែប៉ុណ្ណឹង គាត់អត់មានតួនាទីធ្វើអីផង។

[១៤:២៨:១៩]

**ស៖** បាទ ខ្ញុំនឹងត្រឡប់មកសួរចំណុចនេះ នៅពេលក្រោយ។ លោកបានឆ្លើយថា ប្រុសៗនៅក្នុងក្រុមមនុស្សហ្នឹង គឺថាត្រូវគេដាក់ខ្នោះដៃ។ តើអ្នកណាជាអ្នកដាក់ខ្នោះដៃទៅលើក្រុមមនុស្សដែលគេចាប់ខ្លួននុ៎ង?

**ឆ៖** បាទ ខ្ញុំដូចអត់បាននិយាយថា អ្នកដែលគេចាប់ទៅនុ៎ងដាក់ខ្នោះទេ។ ខ្ញុំគ្រាន់តែនិយាយថា អ្នកដែលជាប់ទោសនៅក្នុងវិហារគេដាក់ខ្នោះជើង។ តែចំពោះបងប្អូនខ្មែរអ៊ីស្លាមដែលគេចាប់ទៅហ្នឹង ដូចខ្ញុំបានជម្រាបពីមុនមក គ្រាន់តែថា ពេលដែលគាត់រៀបឡើងលើវិហារហ្នឹងគេវ៉ៃគាត់។ គេវ៉ៃគាត់មួយដែក អាដែកប្រវែងៗណោះ ដែកទ្រើសជាងមេដៃហ្នឹង បងប្អូនប្រុសៗហ្នឹងគេវ៉ៃ គេវ៉ៃមួយៗអ៊ីចឹងទៅ ឲ្យចូលទៅ។ តែចំពោះនារី បងប្អូនចាមហ្នឹង គេអត់មានវ៉ៃទេ។ ហើយដូចខ្ញុំបានឃើញអ៊ីចឹងថា កូនក្មេងដែលវាឡើងជណ្ដើរមិនរួចអ៊ីចឹងទៅ វាចាប់រុញ វាចាប់ច្រានអ៊ីចឹងទៅ យំរង៉េករង៉ាកពេញវិហារទៅ។ ហើយការដាក់ខ្នោះជើង គេដាក់ ដល់ពេលគេបញ្ចូលហើយ បានគេដាក់ខ្នោះជើង។ អាខ្នោះដៃអត់មានទេ បាទអត់មានខ្នោះដៃទេ មានតែចង សម័យនុ៎ងមានតែចង។ ចងហ្នឹងពួកចល័តពួកអីដែលគេចាប់មកពីការដ្ឋាន អាហ្នឹងគេចង អត់មានខ្នោះៗទេ។ ខ្នោះហ្នឹង គេសម្រាប់ដាក់ស៊កបង្គុតៗមួយខ្សែៗ ៣០-៤០នាក់ទៅមួយខ្សែហ្នឹង ៥០នាក់ទៅ។ ខ្ញុំអត់បាននិយាយថា ពីរឿងដាក់ខ្នោះដៃ ខ្នោះអី គឺអត់មានទេ។

[១៤:៣០:០១]

**ស៖** ដូច្នេះបើខ្ញុំយល់មិនច្រឡំទេ នៅពេលក្រុមទាំងមូលដែលគេបញ្ជូនទៅវត្តហ្នឹង គឺមុនទៅដល់វត្តហ្នឹង គឺមិនមានអ្នកណាម្នាក់ត្រូវបានគេដាក់ខ្នោះដៃ ឬចងអ្វីទេ អ៊ីចឹងមែនទេ?

**ឆ៖** ក្នុងចំណោមបងប្អូនអ៊ីស្លាមទាំងអស់ហ្នឹងដែលគេបញ្ជូនទៅវត្តហ្នឹង អត់មានបានអ្នកណា

មួយត្រូវចង ឬដាក់ខ្នោះអីទេ គឺទៅធម្មតា ទៅធម្មតាតែម្តង។

**ស៖** លោកឆ្លើយថា នៅពេលដែលប្រុសៗទៅចូលទៅក្នុងវិហារហ្នឹងគឺថា ប្រុសៗម្នាក់ៗគឺត្រូវបានគេវាយនឹងដែកវែងមួយ ត្រឹមត្រូវទេ?

**ឆ៖** បាទ អាហ្នឹងខ្ញុំឃើញជាក់ស្តែង គឺមុននឹងចូលឡើងទៅហ្នឹងគេវៃ គេវៃសួរតែភីងៗអ៊ីចឹងទៅមួយដែកៗហ្នឹង។ ឲ្យតែប្រុសៗគឺគេវៃ ក្មេងតូចៗអត់វៃទេ វៃតែមនុស្សចាស់ មនុស្សវ័យកណ្តាលហ្នឹង។

**ស៖** ហើយនៅពេលដែលបុរសទី១ ត្រូវបានគេវាយនឹងរបារដែកហ្នឹង តើប្រុសៗជនជាតិចាមដទៃទៀតឃើញ ដូចលោកឃើញដែរទេ?

**ឆ៖** និយាយទៅវា ពេលដែលចូលទៅក្នុងវត្តហ្នឹង គឺដល់ពេលយើងចូលអស់អ៊ីចឹងទៅ ពួកសន្តិសុខហ្នឹងគេព័ទ្ធជុំវិញអ៊ីចឹងទៅ ព័ទ្ធជុំវិញនៅពីក្រៅអ៊ីចឹង ហេតុដូច្នេះអ្នកទោសហ្នឹងគឺនៅកណ្តាលទាំងអស់ កងសន្តិសុខហ្នឹងគេព័ទ្ធយើងពីក្រៅអស់ហើយណ៎ា។ ដូច្នេះដល់វត្តហើយ គាត់មិនអាចរត់បានទេ។ ហើយអ្នកវៃហ្នឹង ឃើញតើ ឃើញវៃតើ ប៉ុន្តែមិនហ៊ានធ្វើម៉េច បើឃើញគេវៃអ៊ីចឹងហើយ ចេះតែចូលទៅទៀតទៅ។ ចូលទៅ គេវៃបន្តៗអ៊ីចឹងទៅ។ ដល់អ្នកណាស្រីៗទៅ គេអត់មានវៃទេ គេគ្រាន់តែច្រាន គ្រាន់តែរុញអ៊ីចឹងទៅ។ អ្នកខ្លះឃើតគាត់ គាត់ងងឹតអី ព្រោះពេលនុំងវាដូចជាអត់មានភ្លើងអំពូលភ្លើងអីណាផង អត់មានទេ មានតែភ្លើងយើងធម្មតា អុជចន្លុះ អុជខ្លាញ់ត្រី ខ្លាញ់អី។

[១៤:៣២:៣៤]

**ស៖** ឥឡូវខ្ញុំសូមចូលមកសួរអំពីដើមដំបូងនៃការចាប់ខ្លួន។ តើត្រឹមត្រូវទេ បើសិនណាជាខ្ញុំនិយាយថា ប្រសិនណាជាស្ត្រី ឬក៏ក្មេងៗមិនទៅតាមប្រុសៗទេ គឺថាមានន័យថា ស្រីៗនិងក្មេងៗហ្នឹងគឺថា មិនត្រូវបានគេចាប់ខ្លួនទេ? ន័យម្យ៉ាងទៀត ខ្ញុំចង់និយាយថាអ៊ីចេះថា ស្រី និងក្មេងៗដែលទៅជាមួយហ្នឹង គឺថាដោយសារតែទៅតាមបុរសៗទាំងនោះទេ អ៊ីចឹងមែន ឬក៏អត់ទេ?

**ឆ៖** បាទ កាលណាគេចាប់ខ្លួនមួយផ្ទះៗហ្នឹង គេចាប់ទាំងអស់ៗតែម្តង។ ហើយដូចថាស្ត្រីអីគាត់មិនអាចមានកម្លាំងណាទៅ និយាយរួមទៅទាំងប្រុសទាំងស្រី ព្រោះសម័យប៉ុល ពត វាអត់ដែលបានឲ្យយើងហូបចុកគ្រប់គ្រាន់ទេ។ ដូច្នេះទាំងគេទាំងខ្ញុំរាងកាយហ្នឹងក៏វាអត់មានមាំទាំដែរ គឺគ្រាន់ថាទៅធ្វើការហ្នឹង គឺទៅធ្វើដោយការខ្លាចគេសម្លាប់ គេអីអ៊ីចឹងណ៎ា។ ម្ល៉ោះហើយគាត់អត់មានកម្លាំងណាអីទៅតតាំងទៅអីទេ មនុស្សសុទ្ធតែស្គមៗ នៅតែក្បាល ជំនាន់ហ្នឹងវាមានឲ្យយើងហូបចុកឯណាគ្រប់

គ្រាន់ឯណា។ ត្រីមួយគីឡូទៅ ដាក់ត្រកួនមួយខ្ទះ រួចពីណាបានត្រីប៉ុនមេដៃអីហ្នឹង អរដូចឃើញឋានសួគ៌អ៊ីចឹង។

**ស៖** សំណួររបស់ខ្ញុំជាសំណួរមួយជាក់លាក់។ បុរសៗដែលចាប់ខ្លួននៅថ្ងៃ -- បុរសដែលគេចាប់ខ្លួននៅពេលនុ៎ងៗគឺថា ត្រូវតែមានស្ត្រី និងកុមារទៅតាមពួកគាត់ ឬក៏បើមិនមាន ក៏មិនបញ្ហាដែរ?

**ឆ៖** អត់បានទេ គឺការគេចុះយុទ្ធនាការចាប់បងប្អូនចាមហ្នឹង គឺមួយផ្ទះមានប៉ុន្មាននាក់គឺគេចាប់ទាំងអស់ អត់មានទុកទេ។ ចាស់ជរាម៉េចក៏យកទៅដែរ យកទៅទាំងអស់តែម្តង អត់មានទុកទេ។

[១៤:៣៥:០០]

**ស៖** សូមលោកផ្តល់ឈ្មោះបុរសជនជាតិចាមណាម្នាក់មើល ដែលលោកបានឃើញនៅពេលចាប់ខ្លួនហ្នឹង លោកស្គាល់ សូមលោកផ្តល់ឈ្មោះម្នាក់អីបានទេ?

**ឆ៖** ខ្ញុំអាចផ្តល់បានឈ្មោះ ក៏ប៉ុន្តែគាត់ស្លាប់អស់ទៅហើយ។ បើឈ្មោះខ្ញុំស្គាល់តើ ស្គាល់ច្រើនតើ មិនមែនស្គាល់តែម្នាក់ទេ ខ្ញុំស្គាល់ច្រើន។ ប៉ុន្តែដល់ពេលគាត់ស្លាប់អស់ទៅហើយ មានឈ្មោះក៏មិនដឹងយកឈ្មោះហ្នឹងមកធ្វើអី។ ខ្ញុំស្គាល់ច្រើន ឈ្មោះ រីន ហ្នឹងក៏គាត់រកត្រីជាមួយខ្ញុំ។ ឈ្មោះ តាជុ ហ្នឹងក៏គាត់រកត្រីជាមួយខ្ញុំ។ ឈ្មោះ តាម៉ាន ហ្នឹងក៏គាត់រកត្រីជាមួយខ្ញុំ តែមិនមែន ម៉ាន មួយដែលថារត់រួចហ្នឹងទេ ព្រោះបងប្អូនចាមភាគច្រើន សួរបងប្អូនខាងអ៊ីស្លាមទៅ បើ ម៉ានៗ ហ្នឹងចង់មួយកំណាត់ភូមិឈ្មោះវាច្រើនជាន់គ្នា។ ដូច្នេះមិនមែនថា ម៉ាន ហ្នឹងតែមួយទេ ម៉ាន ហ្នឹងវាមានច្រើន។ ឲ្យខ្ញុំទៅរកត្រីជាមួយខ្ញុំហ្នឹង ខ្ញុំស្គាល់ច្រើន ឈ្មោះ ហ៊ីម ក៏មាន, ឈ្មោះ ជុ ក៏មាន, ឈ្មោះ រីន ក៏មាន, ឈ្មោះ ម៉ានក៏មាន ទៅរកត្រីជាមួយគ្នាហ្នឹង ខ្ញុំស្គាល់តើ ស្គាលច្រើន មិនមែនស្គាល់តិចទេ ប៉ុន្តែ ២០, ៣០ឆ្នាំហើយយើងមិនអាចមានការចងចាំ ថាមនុស្សដែលបាត់បង់ទៅហើយ វាពិបាកដែរ។ សូម្បីតែមិត្តភក្តិនៅរស់នៅជាមួយគ្នា បែកគ្នាតែ២០ឆ្នាំ មកវិញមើលលែងស្គាល់ហើយ ទាល់តែនិយាយពីប្រវត្តិលិចកើតទៅទៅនេះទៅនោះទៅ បានអាចនឹកឃើញឡើងវិញ។

**ស៖** ឥឡូវខ្ញុំសូមសួរសំណួរផ្សេងវិញ តើលោកអាចផ្តល់ឈ្មោះបុរសចាមណាម្នាក់ដែលបានធ្វើដំណើរ ហើយជាមួយក្រុមចាមនុ៎ង គឺថា ឥឡូវរៀបរាប់ចាមមួយគ្រួសារមក បុរសចាមម្នាក់ និងប្រពន្ធកូនរបស់គាត់ដែលទៅជាមួយនឹងហ្វូងមនុស្សនេះ?

[១៤:៣៧:០១]

**ឆ៖** ខ្ញុំអាចប្រាប់បានពីឈ្មោះចាមដែលគេចាប់ទៅហ្នឹង ក៏ប៉ុន្តែប្រពន្ធកូន ខ្ញុំអត់សូវស្គាល់ទេ។

បើខ្ញុំស្គាល់កាលជំនាន់នោះ ស្គាល់តែមុខ ដល់ឈ្មោះ មិនដឹងឈ្មោះស្អី តែបើចាមប្រុសហ្នឹងមួយគ្រួសារហ្នឹង មេគ្រួសារហ្នឹងឈ្មោះគេហៅគាត់ថា រីនៗ ឈ្មោះ រីន។

**ស៖** ឥឡូវចាប់ផ្ដើមនិយាយអំពីឈ្មោះ រីន នេះតែម្ដង។ តើ រីន ហ្នឹងជាគ្រួសារតែមួយជាមួយនឹង ម៉ុក ឬក៏ពីរគ្រួសារផ្សេងគ្នា?

**ឆ៖** ខ្ញុំដូចអត់មានឈ្មោះ ម៉ុក ឯណា ខ្ញុំអត់មានថាឈ្មោះ ម៉ុក ផង។

**ស៖** បាទ ចាប់ផ្ដើមសួរអំពី រីន នេះចុះ។ តើលោកបានឃើញ រីន ដើរជាមួយនឹងក្រុមមនុស្សនេះទេ?

**ឆ៖** បាទ ពេលដែលចាប់មកហ្នឹង គឺឃើញគាត់ ផ្ទះគាត់ហ្នឹងនៅជាប់ជិតក្លោងទ្វារវត្ត។ ដូច្នេះគាត់ហ្នឹងគេត្រូវចាប់មុនគេ។ ដល់គេចាប់ៗមក វាច្របូកច្របល់គ្នារឹតតែច្រើនឡើងៗ មិនដឹងជាគាត់ទៅនៅត្រង់ណាទេ ប៉ុន្តែដំបូងគឺចាប់ផ្ទះគាត់ហ្នឹងហើយ គាត់នៅក្បែរផ្លូវ។ ផ្ទះគាត់ដំបូង ហើយផ្ទះសព្វថ្ងៃហ្នឹង ក៏នៅដែរផ្ទះហ្នឹង នៅទាល់សព្វថ្ងៃហ្នឹង ប៉ុន្តែឥឡូវបងប្អូនខ្មែរមកនៅហើយ ព្រោះត្រង់ហ្នឹងជាផ្ទះបងប្អូនខ្មែរ។

**ស៖** តើប្រពន្ធ និងកូនៗរបស់ រីន នេះ បានរួមដំណើរទៅជាមួយនឹង រីន នេះដែរទេ?

**ឆ៖** ខ្ញុំដូចជាបានប្រាប់ច្រើនដងហើយ ថាក្នុងមួយគ្រួសារៗដែលគេចាប់ហ្នឹងគឺគ្រួសារ ១០នាក់ គេចាប់ទាំង ១០នាក់, ប្រាំនាក់ គេចាប់ទាំងប្រាំនាក់ ប្ដីប្រពន្ធកូន និងចាស់ជរា គឺគេយកទៅទាំងអស់ អត់ទុកទេ តែម្នាក់ក៏អត់មានសល់ដែរ។ ក្នុងមួយយប់គឺចាប់ទាំងអស់ អត់មានសល់ទេ។

[១៤:៣៩:៣២]

**ស៖** ខ្ញុំមិនដឹងថា តើការចាប់ខ្លួននេះ ជាពាក្យមួយត្រឹមត្រូវប្រើក្នុងពេលហ្នឹងឬក៏អត់ទេ ប៉ុន្តែ តើលោកបានឃើញគេចាប់ រីន នេះដោយផ្ទាល់ទេ? លោកបានឃើញគេយកគាត់ចេញពីផ្ទះទេ?

**ឆ៖** ខ្ញុំឃើញផ្ទាល់នឹងភ្នែក។ បានថាខ្ញុំហ៊ានអះអាងថាខ្ញុំឃើញផ្ទាល់ ឈ្មោះ រីន នេះ គាត់ជាជនជាតិចាម ហើយគាត់រកត្រីទូកជាមួយខ្ញុំ។ ក្នុងខ្មែរពីរនាក់ គេឲ្យដាក់បងប្អូនចាមម្នាក់ ព្រោះគាត់មានជំនាញខាងនេសាទ។ ដូច្នេះគាត់និងខ្ញុំហ្នឹង គឺនៅទូកជាមួយគ្នា។ ហើយពេលដែលចាប់គាត់ហ្នឹង ខ្ញុំអត់បានទៅរកត្រីជាមួយគាត់ទេ ខ្ញុំគេឲ្យមកឡើងត្នោត។ ហើយពេលដែលគាត់ចេញមកហ្នឹង គាត់សួរខ្ញុំថា "គេហៅទៅណា ស្រ៊ុន?" គាត់ហៅខ្ញុំអ៊ីចឹងណ៎ា អើ!មនុស្សស្គាល់គ្នា ខ្ញុំថា "ខ្ញុំអត់ដឹងទេ រីន ខ្ញុំអត់ដឹងគេហៅរឿងអីៗទេ"។ ពីមុនដំបូង គាត់ស្មានតែគេហៅគាត់ហ្នឹងទៅប្រជុំនៅរោងបាយ រោងអីទេ។ ហើយ

ខ្ញុំហ្នឹងក៏អត់ដឹងថា គេចាប់យកទៅវត្តទៅអីទេ គឺខ្ញុំអត់ដឹងទេ។ ទើបដែលគេនាំទៅហួសរោងបាយទៅបានដឹងថា គេយកបងប្អូនចាមទៅចូលវត្តអូរត្រកួន។ អាហ្នឹងអីចឹង។ ហើយខ្ញុំស្គាល់ច្បាស់ណាស់រឿង រីន នេះខ្ញុំ បើសិនជាថា ខ្ញុំមិនដឹងថា បើសិនជានៅក្មេងដូចពីដើម ខ្ញុំអាចគូររូបគាត់ឲ្យមើលទៀតនោះ ខ្ញុំអាចគូររូបគាត់បានទៀតនោះ ព្រោះមិនមែននៅហូបបាយជាមួយគ្នារាប់ឆ្នាំរាប់ខែ មិនមែនថានេះ មិនមែនទើបនឹងស្គាល់គ្នាអី។ រីន នេះគឺគាត់នៅដើមផ្លូវគេ ផ្ទះគាត់នៅជាប់នឹងខ្លោងវត្តអូរត្រកួនហ្នឹងតែម្តង។ ហើយផ្ទះសព្វថ្ងៃ គឺនៅហ្នឹង នៅទាល់សព្វថ្ងៃ ផ្ទះហ្នឹងគេអត់ទាន់រុះទេ។ គាត់គេៗឲ្យមកនៅហ្នឹង ព្រោះខ្មែរម្នាក់ហ្នឹង ផ្ទះគាត់ហ្នឹង គាត់គេឲ្យទៅនៅសាច់សូ គេយកបងប្អូនចាមឲ្យមកនៅសំបួរមាស។ គេផ្លាស់ប្តូរគ្នាអីចឹង

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងបី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង១៤:៤១ នាទី ដល់ម៉ោង១៥:០២ នាទី)*

[១៥:០២:១៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរនីតិវិធីការសវនាការ ហើយតទៅនេះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តី ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សី។

សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ មុនពេលដែលខ្ញុំចាប់ផ្តើម ខ្ញុំគិតថា មេធាវីការពារក្តីប្រហែលជាមានពេលវេលាបន្ថែម២០នាទីទៀត តើមែនដែរឬទេ? តែខ្ញុំគិតថា ទោះជាយ៉ាងណាក៏ដោយ យើងគិតថា

នៅតែមិនគ្រប់គ្រាន់សម្រាប់ក្រុមមេធាវីការពារក្តី។ ដូច្នេះ ខ្ញុំសូមស្នើសុំបន្ថែម៣០ទៅ៤៥នាទីបន្ថែមពីលើពេល២០នាទីដែលយើងគួរទទួលបាន។ ដូច្នេះ ខ្ញុំស្នើសុំបន្តទៅដល់ម៉ោងដប់ព្រឹកនៅថ្ងៃស្អែកបន្តទៀត។ សូមអរគុណលោកប្រធាន។

[១៥:០៣:២០]

**ប្រធានអង្គជំនុំ៖**

វាទំនងជាច្រើនពេកទេដឹង។ ទី១ យើងបញ្ជាក់ជូនថា មេធាវី កាលពីក្រុមសហមេធាវី -- ក្រុមសហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ព្រឹកមិញនេះ យើងថែម២០នាទី បើធៀបជាមួយនឹងពេលវេលាដែលខាតបង់ដោយសារអង្គជំនុំជម្រះធ្វើនីតិវិធីផ្សេងៗនៅព្រឹកនុ៎ង គឺអស់១៥នាទីរួចហើយ។ ហើយបញ្ជាក់ថាម៉ោងឥឡូវនេះ គឺម៉ោងពេលព្រឹកនិងម៉ោងពេលរសៀលសវនាការគឺដូចគ្នា ២ម៉ោង១០នាទីដូចគ្នាប៉ុណ្ណោះ។

ចៀសវាងលម្អៀងគ្នាច្រើនពេក វានឹងអាចមានបញ្ហាប្រឈមនឹងបញ្ហានូវការតវ៉ាភាគីម្ខាងទៀតនៅពេលខាងមុខ វានឹងអាចមានវែង។ ឥឡូវលោកសមស្របប្រហែលណា ផ្តល់ពេលវេលាប្រហែលគ្នាបានទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំព្យាយាមប្រើប្រាស់ពេលវេលាខ្ញុំឱ្យមានប្រសិទ្ធភាព ប៉ុន្តែខ្ញុំគិតថា ខ្ញុំនៅតែត្រូវការពេលវេលានៅថ្ងៃស្អែកព្រឹកបន្ថែមទៀតលោកប្រធាន។ យ៉ាងណាក៏ដោយខ្ញុំគិតថា ពេលបន្ថែម២០នាទីហាក់ដូចជាមិនគ្រប់គ្រាន់ទេ សម្រាប់ក្រុមមេធាវីការពារក្តី។ ដូច្នេះ ខ្ញុំសូមឱ្យអនុញ្ញាតឱ្យអង្គជំនុំជម្រះផ្តល់ពេលវេលាបន្ថែមដល់ក្រុមមេធាវីការពារក្តី ដើម្បីពិភាក្សាអំពីបញ្ហាប្រល័យពូជសាសន៍។ ដូច្នេះ សូមលោកប្រធានមេត្តាអនុញ្ញាតផង។

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញ!

[១៥:០៥:០៥]

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំបានពិភាក្សាជាមួយនឹងសហភាតារបស់ខ្ញុំ គឺយើងពិបាកនឹងបញ្ចប់នៅថ្ងៃនេះណាស់។ ខ្ញុំសូមអរគុណដល់អង្គជំនុំជម្រះ ពាក់ព័ន្ធទៅនឹងគោលការណ៍ដែលថា ឱ្យ

យើងមានពេលបន្ថែម២០នាទីដូចសហព្រះរាជអាជ្ញា។ ក៏ប៉ុន្តែខ្ញុំមានបញ្ហាជាមួយនឹងសុខភាពរបស់កូនក្តីខ្ញុំ ព្រោះថា ព្រឹកមិញ២០នាទីហើយ បើសិនជាថែមដល់ល្ងាចហ្នឹងបន្ថែមទៀត ខ្ញុំគិតថាមានបញ្ហាសម្រាប់កូនក្តីខ្ញុំហើយ។ អ៊ីចឹងសូមឲ្យរៀបចំធ្វើយ៉ាងម៉េច ធ្វើឲ្យការបញ្ចប់សាកសួរហ្នឹងនៅថ្ងៃចន្ទព្រឹកវិញលោកប្រធាន ពីព្រោះថាគាត់ បើសិនជាបន្តពីរដង ព្រឹកម្តងហើយល្ងាចម្តងអ៊ីចឹងទៀត គាត់នឹងមានបញ្ហាប្រឈមផ្នែកសុខភាពហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ យើងមិនមានការជំទាស់អ្វីនោះទេ ប្រសិនបើតុលាការគិតថា ជាការសមស្របក្នុងការផ្តល់ពេលវេលាបន្ថែមបន្តិចបន្តួចនោះ។ ប៉ុន្តែអ្វីដែលខ្ញុំចង់ជំទាស់គឺថា ការដែលមេធាវីការពារក្តីបានកំណត់ប្រភេទសាក្សី ទាក់ទងទៅនឹងអ្វីដែលគាត់និយាយ។ ដូច្នេះ ប្រសិនបើគាត់ចង់ស្នើសុំពេលវេលាបន្ថែម គាត់គួរតែចៀសវាងការសួរសំណួរដដែលៗ ឬក៏សួរសំណួរច្រំដែលបែបនេះ។ ដូច្នេះប្រសិនបើគាត់ធ្វើដូច្នេះបាន គាត់ប្រហែលជាគាត់អាចប្រើប្រាស់ពេលវេលាអស់ទៅតាមអ្វីដូចដែលតុលាការបានផ្តល់មកខាងព្រះរាជអាជ្ញាដូចគ្នាដែរ។

[១៥:០៦:៤៧]

**ប្រធានអង្គជំនុំ៖**

បាទ ផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តី។ ហើយសូមបញ្ជាក់ថា ការកត់សម្គាល់របស់សហព្រះរាជអាជ្ញារងអន្តរជាតិលើបញ្ហារបៀប ប្រភេទនៃការតាំងសំណួរសមស្របណាស់ សូមលោកមានការប្រើប្រាស់ពេលវេលាឲ្យមានប្រសិទ្ធភាព ចៀសវាងការតាំងសំណួរច្រំដែល ឬក៏សំណួរដែលមិនមានការពាក់ព័ន្ធ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី លោកបាននិយាយអំពី រីន ហើយលោកនិយាយអំពីការចាប់ខ្លួន រីន។ ហើយ រីន ស្ថិតនៅក្នុងក្រុមជនជាតិចាមទាំង៣០០នាក់។ លោកនិយាយថា លោកនៅលើដើមត្នោត នៅចុងត្នោតនៅពេលដែលគេចាប់ខ្លួន រីន។ តើខ្ញុំនិយាយអ៊ីចឹងជាការត្រឹមត្រូវដែរឬទេ?

**លោក សេង ស្រ៊ុន៖**

**ឆ៖** បាទ ខ្ញុំសូមជំទាស់តិចថា ខ្ញុំអត់បានអាល័យនៅលើដើមត្នោតឯណាផង។ ហើយដល់សួរខ្ញុំអ៊ីចឹង ខ្ញុំអត់ដឹងឆ្លើយថាម៉េច។

**ស៖** អ៊ីចឹងប្រហែលជាខ្ញុំយល់ខុសហើយ។ ដូច្នេះតើលោកនៅកន្លែងណាដែរ នៅពេលដែលគេចាប់ខ្លួន រីន នោះ?

**ឆ៖** ពេលខ្ញុំ ចាប់ខ្លួន រីន ហ្នឹង ខ្ញុំដូចជាបានឆ្លើយច្រើនដងហើយ ប៉ុន្តែតែខាងមេធាវីការពារក្តីហាក់ដូចជាសួរសំណួរដដែលៗ។ ខ្ញុំថាពេលដែលគេចាប់ខ្លួន រីន ហ្នឹងគឺខ្ញុំនៅក្នុងហេតុការណ៍ ខ្ញុំនៅក្បែរផ្ទះ រីន ហ្នឹង។ ខ្ញុំបញ្ជាក់ពីរបីហើយតើ។ សូមអភ័យទោស។

[១៥:០៨:៥២]

**ស៖** តើឈ្មោះ រីន គាត់នៅក្នុងក្រុមដែលគេចាប់ខ្លួននោះ ឬក៏គាត់នៅមុនក្រុមដែលគេចាប់ខ្លួនពីររយបីរយនាក់នោះ?

**ឆ៖** បាទ ឈ្មោះ រីន ហ្នឹងគឺគេនៅក្នុងក្រុមទាំងអស់ជាមួយអ្នកចាប់ខ្លួនបងប្អូនអ៊ីស្លាមទាំងអស់ហ្នឹង គឺនៅជាមួយគ្នាទាំងអស់ ក្នុងពេលពីម៉ោងប្រាំមួយ ដល់ម៉ោងប្រាំបីយប់ហ្នឹង គឺនៅទាំងអស់បងប្អូនអ៊ីស្លាមដែលនៅក្នុងភូមិសំបួរមាស "ក" ហ្នឹងគឺនៅទាំងអស់។

**ស៖** ខ្ញុំមិនមែននិយាយពេលយប់នោះទេ ខ្ញុំនិយាយនៅពេលដែល រីន គឺថាមនុស្សដែលលោកស្គាល់ហ្នឹង ត្រូវបានគេចាប់ខ្លួន។ ដូច្នេះ ខ្ញុំចង់ដឹងថាតើគាត់ៗនៅក្នុងក្រុមមនុស្សពីរបីរយនាក់ហ្នឹង ឬក៏គាត់ស្ថិតនៅក្នុងក្រុមនៃការចាប់ខ្លួនជាទ្រង់ទ្រាយធំផ្សេងទៀតទេ?

**ឆ៖** ខ្ញុំដូចជាពិបាកឆ្លើយដែរ សំណួរហ្នឹង។ ខ្ញុំបានបញ្ជាក់ហើយថា ការចាប់ខ្លួនបងប្អូនចាមនេះគឺធ្វើនៅអំឡុងពេលតែមួយ ពេលវេលាតែមួយ គឺម៉ោងប្រាំមួយល្ងាចហ្នឹង គឺការចាប់ខ្លួនបងប្អូនចាមហ្នឹងគឺចាប់ទាំងអស់តែម្តង អត់មានចាប់ក្រុមណាផ្សេង ក្រុមណាមួយទៀតអត់ទេ គឺរួមគ្នាទាំងភូមិតែម្តង។

[១៥:១០:២៧]

**ស៖** ចាតើនៅពេលហ្នឹងគេប្រើប្រាស់មធ្យោបាយអ្វីដែរ? តើគេមានប្រើមីក្រូ ប្រើឧគ្ឃោសនា-សព្ទអីដែរឬទេ? ដូច្នេះខ្ញុំចង់ដឹងថាតើមានអ្វីកើតឡើងនៅពេលនោះ?

**ឆ៖** នៅពេលអំឡុងចាប់ខ្លួននោះ គឺគេអត់បានប្រើអីទាំងអស់។ សូម្បីតែប្រជាពលរដ្ឋដែលគាត់នៅតាមភូមិហ្នឹង ក៏គាត់អត់បានដឹងដែរ។ ដឹងតែអ្នកដែលនៅផ្ទះនៅជាប់ៗផ្លូវទេ តែផ្ទះគាត់ដែលមិននៅ

ក្បែរផ្លូវ គឺគាត់អត់បានដឹងអីទាំងអស់ ហើយអ្នកនៅក្បែរផ្លូវហ្នឹង ខ្លះក៏គាត់អត់បានដឹងដែរ ព្រោះគាត់អត់មានបានចាប់អារម្មណ៍ថា គេចាប់បងប្អូនចាមអី គឺគាត់អត់បានដឹងទេ ទាល់តែពេលព្រឹកឡើងបាន គាត់បានទទួលព័ត៌មានថា បងប្អូនចាមទាំងអស់ត្រូវគេចាប់ខ្លួនហើយ។

**ស៖** ឥឡូវនេះខ្ញុំសូមអាននូវអ្វីដែលលោកបានឆ្លើយជាមួយសហព្រះរាជអាជ្ញា គឺឯកសារ E3/5302, អង់គ្លេសមានលេខ 00210488, បារាំងមានលេខ 00623191 និងខ្មែរមានលេខ 00635176។ "ចំនួនប្រជាជនចាមដែលត្រូវចាប់ខ្លួនប្រហែលពីរបីរយនាក់។ ខ្ញុំត្រូវបានគេៗឲ្យបណ្ដើរទៅកាន់វិហារនៅអូរត្រកួន។ គេគ្រាន់តែបញ្ជាស្ត្រីជាជនជាតិចាមឲ្យដើរប៉ុណ្ណោះ ចំណែកបុរសវិញត្រូវដាក់ខ្នោះ និងវាយដំ។ ខ្ញុំជាមនុស្សម្នាក់ក្នុងចំណោមគ្នាពីរនាក់ ដែលបានដឹកនាំក្រុមនោះ។ ហើយមានមនុស្សពីរនាក់ផ្សេងទៀត ដើរយាមពីខាងក្រោយ។ ពួកយើងទាំងបួននាក់ជាអ្នកឡើងត្នោត។ នៅពេលដែលយើងទៅដល់វិហារក្នុងវត្ត ឆ្មាំគុកនិងពេជ្ឈឃាតបានមកយកប្រជាជនទាំងនោះ។" លោកសាក្សី គឺលោកបានចូលរួមនៅក្នុងការចាប់ខ្លួន ហើយនិងនាំខ្លួនជនជាតិចាម៣០០នាក់ ពីផ្ទះរបស់ពួកគេទៅមន្ទីរសន្តិសុខ។ តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវទេ?

[១៥:១៣:០៥]

**ឆ៖** ខ្ញុំអត់យល់ថា ពាក្យដែលខ្ញុំនិយាយថា គេដាក់ខ្នោះហ្នឹង គឺខ្ញុំអត់បាននិយាយទេ ព្រោះមួយសម័យនុ៎ង ខ្ញុំដូចបញ្ជាក់ហើយ វាអត់មានខ្នោះទេ ដាក់ខ្នោះដៃហ្នឹងវាអត់មានទេ។ ខ្ញុំគ្រាន់ថា គេដាក់ខ្នោះជើង នៅពេលដែលយើងចូលទៅក្នុងវិហារ។ ព្រោះវិហារនុ៎ង គេចោះប្រហោងវិហារហ្នឹង ហើយគេស៊កដែក អាដែកវែងៗនោះ ទទឹងៗវិហារហ្នឹង ហើយគេដាក់កង កងគេហ្នឹងម៉ាល្មមៗកជើងយើងហ្នឹង គេបញ្ចូលដែកហ្នឹងបន្តៗគ្នាទៅ អាណាៗចូលមុនទៅ គេដាក់មុនទៅ អាណានៅក្រោយ គេរុកៗតាមក្រោយទៅ ឲ្យដល់ពីត្បូងដល់ជើងទៅ គេចាក់សោទៅ។ រឿងខ្នោះដៃខ្នោះអីអត់មានទេ ព្រោះជំនាន់ហ្នឹងអត់មានខ្នោះដៃខ្នោះអីណាទេ។ ដល់យើងថាក់ដាក់ខ្នោះដៃអ៊ីចឹង ខ្ញុំដូចជាអត់បានថា ដាក់ខ្នោះដៃខ្នោះអីណាផង បើខ្នោះជើងខ្ញុំនិយាយ។ បាទ នេះខ្ញុំនិយាយតាមការដែលខ្ញុំឃើញ ដល់ខ្ញុំនិយាយខុសពីការដែលអីដែលខ្ញុំបានឃើញ ហាក់ដូចជាខ្ញុំហ្នឹងក្បត់ឆន្ទៈខ្លួនឯង ចេះតែកាឡៃពាក្យ ដើម្បីប្រឌិតរឿង។ ខ្ញុំអត់ចង់ប្រឌិតរឿងទៅលើបុគ្គលណាម្នាក់ទេ ខ្ញុំមកនេះក្នុងនាមជាសាក្សី ខ្ញុំបំភ្លឺដើម្បីជាភ័ស្តុតាងឲ្យខាងតុលាការហ្នឹងវែកមុខ រកមុខឃាតករដែលឲ្យសម្លាប់ប្រជាជនចាមហ្នឹង។ ខ្ញុំគ្រាន់តែប៉ុណ្ណឹង។

**ស៖** មិនបញ្ហាទេ គឺថាអត់ខ្នោះដៃក៏បានដែរ។ ដូច្នេះខ្ញុំចង់បញ្ជាក់ថា តើចម្លើយរបស់លោកត្រឹម

ត្រូវដែរឬទេ ដែលថាមានគ្នាបួននាក់ជាអ្នកឡើងត្នោត? គឺថាអ្នកឡើងត្នោតទាំងបួននាក់ហ្នឹងទទួលខុសត្រូវក្នុងការបណ្ដើរ ឬក៏ក្នុងការនាំជនជាតិចាមទៅមន្ទីរសន្តិសុខ។ បានន័យថាដើរខាងមុខ ហើយនិងដើរពីក្រោយហ្នឹង។ តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវទេ?

[១៥:១៥:០៣]

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា អ្នកឡើងត្នោតហ្នឹងវាមានគ្នាបួននាក់ ក៏ប៉ុន្តែគេចែកគ្នាតាមមុខសញ្ញា ព្រោះបងប្អូនខាងជនជាតិអ៊ីស្លាមហ្នឹង គាត់មិនមែននៅតែម្ដុំទេ។ គាត់ គេយកគាត់ទៅច្រឡូកជាមួយបងប្អូនខ្មែរ ឧបមាថា ទៅនេះបួនប្រាំគ្រួសារទៅ ទៅនោះបួនប្រាំគ្រួសារទៅ។ ដូច្នេះការបែងចែកពួកខ្ញុំអ្នកឡើងត្នោតហ្នឹង គេបែងចែកតាមមុខសញ្ញា។ តែកន្លែងខ្ញុំហ្នឹង អង្គាល់ខ្ញុំមកហ្នឹង ដូចមកតែខ្ញុំមិនដឹងក៏ពីរនាក់មិនដឹង ខ្ញុំវាដូចជាចាំមិនច្បាស់ ប៉ុន្តែរឿងខ្ញុំមក១ ខ្ញុំនិយាយត្រង់អ៊ីចឹង ខ្ញុំមកដឹងតែខ្ញុំមក។ ប៉ុន្តែវាច្របូកច្របល់ មិនដឹងថា មនុស្សវាច្រើន ដល់ច្រើនពេកទៅ មិនដឹងពីណាឡើងត្នោត ពីណាមិនឡើងត្នោតទេ ស្រែកកស្រែកាកពេញតែផ្លូវ ហើយមើលវា ហើយព្រលប់ៗ មួយជំនាន់នោះមានអំពូលម៉ែត្រអំពូលអីឯណា ងងឹតៗ ខែភ្លឺ មើលតាមពន្លឺខែហ្នឹង។ ដូច្នេះខ្ញុំអត់ដឹងថា អ្នកដែលទៅហ្នឹងគេទៅមុខសញ្ញាណាអត់ទេ ប៉ុន្តែបួននាក់ហ្នឹងគឺចេញទៅទាំងអស់គ្នា ប៉ុន្តែវាមានទៅខាងកើត មានទៅខាងលិចព្រោះមុខសញ្ញាបងប្អូនចាមហ្នឹង គេប្រមូលចាប់ហ្នឹង មិនមែនចាប់តែម្ដុំទេ គេចាប់ច្រើន ហើយគេយកមកបញ្ចូលត្រង់ខ្លោងទ្វារហ្នឹងទាំងអស់គ្នា បានចូលទៅក្នុង។

**ស៖** តើការបណ្ដើរប្រជាជនប្រហែលជា៣០០នាក់ហ្នឹង គឺគេចំណាយពេលប្រហែលប៉ុន្មាននាទីដែរ? តើចំណាយពេលប្រហែលជាកន្លះម៉ោង ឬក៏មួយម៉ោង តើលោកអាចប្រាប់បានទេ មុននឹងពេលទៅដល់កន្លែងប្រមូលផ្ដុំនោះ?

[១៥:១៦:៥១]

**ឆ៖** បាទ ការធ្វើដំណើរចាប់បងប្អូនអ៊ីស្លាមដែលទៅវត្តហ្នឹងវាមិនជាយូរប៉ុន្មានទេ។ ការធ្វើដំណើរហ្នឹងប្រហែលជា១០នាទីទេ ព្រោះថាវាជិតដែរ ចម្ងាយប្រហែលជា៣០០ម៉ែត្រទេ ៣០០ម៉ែត្រ ៣៤១ម៉ែត្រពីកន្លែងចាប់ហ្នឹងទៅក្នុងវត្តនោះ។ ប្រហែលចំណាយពេលប្រហែល១០នាទី។

**ស៖** តើចម្ងាយ៣៤១ម៉ែត្រពីវត្តហ្នឹង មានន័យថាម៉េចដែរអាហ្នឹង?

**ឆ៖** មានន័យថា ចម្ងាយដែលគេប្រមូលបងប្អូនចាមដាក់នៅម្ដុំហ្នឹង ហើយធ្វើដំណើរទៅក្នុងវត្តហ្នឹង វាមានចម្ងាយ៣៤១ម៉ែត្រ។ អង្គាល់ហ្នឹងខ្ញុំអត់ដឹងថាចម្ងាយប៉ុន្មានទេ ក៏ប៉ុន្តែដល់ពេលឥឡូវគេ ធ្វើ

ផ្លូវធ្វើអីហ្នឹង វាចម្ងាយវាស់ទៅបាន៣៤១ម៉ែត្រ។ ចម្ងាយពីកន្លែងចាប់ហ្នឹងទៅវត្តហ្នឹង៣៤១ម៉ែត្រ ហើយយើងប្រើពេលវេលា១០នាទី ប្រហែល១០នាទីចូលទៅដល់កន្លែងវិហារឃុំឃាំងនុ៎ង។

**សៈ** តើជនជាតិចាមគេធ្វើដំណើរតាមអ្វីដែរ ដើម្បីទៅដល់កន្លែងប្រមូលផ្ដុំហ្នឹង?

**ឆៈ** មធ្យោបាយធ្វើដំណើរគេគឺដើរ អត់មានធ្វើអីផង។ បើពួកបងប្អូនចាមដែលគេចាប់ពីការដ្ឋានមក អាហ្នឹងគេដាក់រទេះសេះ។ ដល់បងប្អូននៅតាមភូមិហ្នឹង គេអត់មានដាក់រទេះសេះទេ គឺគេបណ្ដើរដោយថ្មើរជើងតែម្ដង។

**សៈ** ហេតុអ្វីបានអ្នកឡើងត្នោតទាំងប្អូននាក់ហ្នឹងត្រូវបានគេឲ្យជួយបណ្ដើរ ឬក៏ជួយនាំជនជាតិចាមពីកន្លែងប្រមូលផ្ដុំហ្នឹងទៅវត្តទៅវិញ?

[១៥:១៩:២១]

**ឆៈ** ខ្ញុំបានឆ្លើយរួចហើយថា ពួកខ្ញុំហ្នឹងគឺអត់ដឹងអីទាំងអស់ ដែលគេប្រើទៅហ្នឹង គេមិនដឹងប្រើ អត់ប្រាប់យើងថាឲ្យទៅធ្វើអីផង។ ដល់កន្លែងកើតហេតុដែលគេចាប់បងប្អូនចាមមក បានយើងដឹងថាគេចាប់បងប្អូនចាម។ ពីដំបូងដែលយើងធ្វើដំណើរទៅហ្នឹង យើងអត់ដឹងទេ ព្រោះមូលហេតុអីបានគេអត់ឲ្យយើងដឹង? គេខ្លាចយើងទៅប្រាប់បងប្អូនចាមថាឲ្យរត់ឲ្យអីអឺចឹងណ៎ា ព្រោះយើងធ្វើការជាមួយគ្នា តែមានការចាប់ហ្នឹង យើងអាចទៅប្រាប់។ ដូច្នេះ គេអត់មានប្រាប់យើងរឿងពីមូលហេតុដែលគេឲ្យយើងទៅហ្នឹងទេ អត់ទេ។

**សៈ** ឥឡូវនេះ ខ្ញុំសូមអានចំពោះអ្វីដែលលោកបានឆ្លើយមុនពេលឈប់សម្រាក អំពីឈ្មោះ រីន។ លោកបាននិយាយថា រីន ជាជនជាតិចាម គាត់នៅក្នុងក្រុមអ្នកនេសាទ។ គេបញ្ចូលពួកចាម និងពួកខ្មែរនៅក្នុងកងនេសាទ ហើយលោកនៅជាមួយ រីន នៅលើទូក។ នៅពេលដែលគេចាប់ខ្លួន រីន គឺថាគេចាត់តាំងឲ្យលោកទៅធ្វើការជាអ្នកឡើងដើមត្នោត។ នេះ គឺជាអ្វីដែលយើងស្ដាប់ឮតាមរយៈការបកប្រែជាភាសាអង់គ្លេស។ តើអ្វីដែលខ្ញុំនិយាយហ្នឹង វាជាការត្រឹមត្រូវដែរឬទេ? តើលោកឃើញ រីន នៅពេលដែលគេចាប់ខ្លួន ឬក៏លោកឃើញ រីន ហ្នឹងនៅកន្លែងប្រមូលផ្ដុំទេ?

**ឆៈ** វាជាការពិតណាស់ ព្រោះខ្ញុំនិយាយ ខ្ញុំបាននិយាយហើយថា រីន ហ្នឹងគាត់ធ្លាប់នេសាទជាមួយខ្ញុំ ក្នុងបងប្អូនអ៊ីស្លាមម្នាក់ គេឲ្យដាក់ខ្មែរពីរនាក់ ព្រោះគាត់មានជំនាញខាងនេសាទ។ ក៏ប៉ុន្តែពេលដែលគេចាប់ខ្លួនគាត់ហ្នឹង គាត់នៅរកត្រីដដែល ហើយខ្ញុំនេះ បានត្រូវគេដកមកឲ្យឡើងត្នោត។ ក៏ប៉ុន្តែខ្ញុំ និងគាត់ គឺស្គាល់គ្នាច្បាស់ណាស់។ កាលណាគាត់បានត្រីអីចឹងទៅ គាត់យកទៅរោងបាយ

រួចខ្ញុំនៅឡើងត្នោតនុ៎ង។ ទៅជួបគ្នានុ៎ង រាល់ថ្ងៃហ្នឹង គឺគ្មានខានទេ ថ្ងៃណាក៏គាត់យកទៅដែរ។

[១៥:២១:៤០]

**ស៖** ខ្ញុំតាមលោកមិនទាន់ ប៉ុន្តែអ្វីទេ យើងបន្តទៅប្រធានបទថ្មីចុះ។ តើត្រឹមត្រូវដែរឬទេ ដែលថានៅក្នុងកិច្ចប្រជុំដែលលោកបានឮ អាន និយាយអំពីជនជាតិចាម តើលោកបានផ្តល់ចម្លើយទៅអ្នកស៊ើបអង្កេតថា លោកបានស្តាប់ឮ អាន និយាយអ៊ីចឹងមែនទេ?

**ឆ៖** បាទ រឿងបញ្ហា អាន ប្រធានតំបន់ដែលគេផ្លាស់មកថ្មីហ្នឹង ដូចខ្ញុំបានជម្រាបចៅក្រមស៊ើបអង្កេតហើយ ខ្ញុំថា អាន ហ្នឹងគេមកបើកមីទ្ទីងនៅក្នុងវត្តអូរត្រកួនហ្នឹង ហើយគេបំផុសពីប្រជាជនហ្នឹង គេឲ្យប្រជាជនយើងក្រោកតវ៉ាអីអ៊ីចឹងទៅ ពីមេកង មេអីណា ប្រធានរោងបាយអីណា ឲ្យយើងហូបរាវអី មិនគ្រប់គ្រាន់អ៊ីចឹង មិនឆ្អែតមិនអី ហើយមិនហាមឃាត់មិនឲ្យគាស់ដំឡូង កាប់ចេកអីតាមផ្ទះតាមអីហ្នឹង ឲ្យរាយការណ៍ប្រាប់គេ។ បើមេកងណាធ្វើអ៊ីចុង ប្រាប់គេ។ ហើយប្រជាពលរដ្ឋកន្លែងខ្ញុំឮគេនិយាយអ៊ីចុង អរណាស់ដំបូង។

**ស៖** សូមទោសដែលខ្ញុំកាត់លោក ប៉ុន្តែខ្ញុំចង់សួរថា តើ តាអាន ៗមាននិយាយអំពីជនជាតិចាម ឬក៏អត់នៅក្នុងសុន្ទរកថាដែលគាត់បានថ្លែងនោះ?

**ឆ៖** នៅក្នុង អាន គាត់និយាយហ្នឹង គាត់អត់បានបង្ហើបនិយាយពីរឿងបងប្អូនជនជាតិចាមទេ គាត់តែនិយាយតែពីរឿងការចាប់ខ្លួនកម្មាភិបាលចាស់ ថាជាពួកក្បត់ ក្បត់អង្គការ។ តែចំពោះបងប្អូនចាម គឺគាត់អត់មាននិយាយទេនៅក្នុងមីទ្ទីងនុ៎ង។ ហើយនៅក្នុងមីទ្ទីងនុ៎ង ក៏មានបងប្អូនចាមហ្នឹងទៅចូលរួមដែរ ពេលនុ៎ះ គឺមានបងប្អូនចាមចូលរួមដែរ។

[១៥:២៣:៤១]

**ស៖** តើគាត់និយាយយ៉ាងម៉េចដែរ អំពីជនក្បត់នៅភូមិភាគឧត្តរ? តើពួកទាំងអស់នោះ ក្បត់បែបណាដែរ? តើគេបានធ្វើអ្វី? តើគេបានបំពេញអ្វីដែរ? តើ តាអាន មានប្រាប់ថា តើកម្មាភិបាលនៅភូមិភាគឧត្តរហ្នឹង មានធ្វើអ្វីដែលៗថាជាជនក្បត់នុ៎ងដែរឬទេ?

**ឆ៖** បាទ ខ្ញុំសូមជម្រាបលោកមេធាវីថា ការដែលគេចាប់ជនក្បត់នោះ គេអត់ដែលប្រាប់យើងថា អ្នកនុ៎ងក្បត់រឿងអីៗទេ គេអត់ដែលបាននិយាយទេ ព្រោះយើងប្រជាជន គេមានអីណាមកប្រាប់យើងអារឿងអ៊ីចុងៗ ផ្ទៃក្នុងគេ។ គេគ្រាន់ថា គេគ្រាន់តែប្រកាសថា កម្មាភិបាលដែលត្រូវចាប់ខ្លួនពីមុនៗមក សុទ្ធតែជាជនក្បត់ ក្បត់អង្គការ ក្បត់បដិវត្តន៍។ គេនិយាយអ៊ីចឹង ប៉ុន្តែរឿងអីទៀត គេមិនអាចមក

ប្រាប់យើងទេ គេគ្រាន់តែថាក្បត់អង្គការមួយម៉ាត់ទៅ ចប់ហើយ។ ប្រជាជនមិនទៅប៊ាន ពីណាប៊ាន សួរដេញដោល។

**ស៖** តើលោកធ្លាប់ឮទេ ថាមានបុរស ឬក៏នារីដែលជាជនជាតិចាមត្រូវបានគេចោទប្រកាន់ថា ជាជនក្បត់ ឬក៏ជាអ្នកបះបោរប្រឆាំងអីដែរ តើលោកធ្លាប់ឮទេ?

**ឆ៖** អានេះបើនិយាយទៅ ការដែលគេប្រកាសថា ជនជាតិចាមជាជនក្បត់ជនអីហ្នឹង បើឮផ្ទាល់គេនិយាយ ខ្ញុំអត់ដែលបានទទួលព័ត៌មានទេ។ ប៉ុន្តែគ្រាន់តែថា តាមអ្នកនិយាយខ្លះៗ គេនិយាយថា គេចាប់ចាម ព្រោះគេខ្លាចបងប្អូនចាមហ្នឹងបះបោរអី។ តែចំពោះខ្ញុំឮផ្ទាល់នឹងត្រចៀក ដែលកម្មាភិបាល ប៉ុល ពត និយាយ គឺខ្ញុំអត់ដែលបានឮទេ។

[១៥:២៦:០៣]

**ស៖** តើការបះបោរដែលលោកនិយាយហ្នឹង គឺការបះបោរដូចដែលកម្មាភិបាលនៅភូមិភាគឧត្តរបានធ្វើ តើមែនដែរឬទេ? តើលោកធ្លាប់ឮថា ជនជាតិចាមមានការបះបោរ ឬក៏ញុះញង់ឲ្យមានការសមគំនិតក្នុងការក្បត់ដែរឬទេ?

**ឆ៖** ខ្ញុំសូមជម្រាបថា ប្រជាពលរដ្ឋ ប្រជាជនដែលរស់នៅ ជាបងប្អូនខាងខ្មែរអ៊ីស្លាមហ្នឹង ខ្ញុំអត់ដឹងថា គាត់បះបោរម៉េចទេ កុំសូម្បីតែប្រជាជន សូម្បីតែកម្មាភិបាលដែលគេចាប់ខ្លួនហ្នឹង ក៏ខ្ញុំអត់ដឹងថា គេក្បត់ គេបះបោរម៉េច គឺខ្ញុំអត់បានដឹង។ គ្រាន់តែគេប្រាប់យើងប៉ុណ្ណឹង។

**ស៖** អ៊ីចឹងមានន័យថា លោកមិនដឹងអំពីហេតុផលក្នុងការចាប់ខ្លួនជនជាតិចាមដែលលោកបានរៀបរាប់មួយថ្ងៃហ្នឹងហើយទេ តើអ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំដឹង ក៏ប៉ុន្តែខ្ញុំដឹងហ្នឹង ខ្ញុំមិនមែនដឹងថា តែបងប្អូនចាមម្នាក់ទេ គឺពាក្យ ប៉ុល ពត គេថា បនប្រល័យពូជសាសន៍ហ្នឹង ឲ្យតែជាតិសាសន៍ណាក្រៅពីជនជាតិខ្មែរ គឺជាសត្រូវនឹងគេទាំងអស់។ ជនជាតិចាម ជនជាតិវៀតណាម ហើយនិងជនជាតិចិន សុទ្ធតែជាសត្រូវគេទាំងអស់ រួមទាំងបងប្អូនប្រជាជន៧៥ គឺគេហៅប្រជាជនថ្មីនោះ។

**ស៖** នៅពេលនោះ តើលោកធ្លាប់ឮការបះបោររបស់ជនជាតិចាម នៅត្រើយម្ខាងទន្លេមេគង្គ គឺនៅក្នុងខែកញ្ញា ឬក៏តុលា ឆ្នាំ៧៥ ដែរឬទេ?

**ឆ៖** ខ្ញុំវា ដូចខ្ញុំបានជម្រាបហើយ ការទទួលព័ត៌មានមានកម្រិត។ សម័យ ប៉ុល ពត កុំសូម្បីតែត្រើយម្ខាង សូម្បីតែខ្ញុំនៅភូមិពាមជីកង ពីភូមិមួយទៅភូមិមួយចម្ងាយតែ៥០-៦០ម៉ែត្រហ្នឹងក៏យើងអត់

អាចទទួលព័ត៌មានថា យ៉ាងម៉េចដែរ។ សូម្បីតែយើងរស់នៅក្នុងភូមិជាមួយគ្នា រំលងគ្នាតែ១០ផ្ទះហ្នឹង ក៏យើងអត់អាចទទួលព័ត៌មានថា យ៉ាងម៉េចៗដែរ គឺគេហាមឃាត់មិនឲ្យយើងដើរ។ ដូច្នេះយើងអត់បានព័ត៌មាន ហើយខ្ញុំក៏អត់បានទទួលព័ត៌មានអីដែរ។

[១៥:២៩:០៦]

**ស៖** តើលោកដឹងដែរឬទេថា ជនជាតិចាមប្រហែលពីរបីរយនាក់ ដែលលោកនិយាយថា លោកបានឃើញហ្នឹង គឺថាកាលពីមុនគាត់នៅភូមិភាគបូព៌ា ដូចជាអំពិល ឬកោះផលជាដើមនោះ តើវាអាចដែរឬទេ?

**ឆ៖** តាមការពិនិត្យរបស់ខ្ញុំផ្ទាល់ គឺបងប្អូនខ្មែរអ៊ីស្លាមដែលនៅក្នុងពាមជីកងនេះ ពីមុនមកគាត់មានទីលំនៅហ្នឹងតែម្តង គឺអត់មានបងប្អូនចាមណាមកពីកោះផល កោះអីណាទេ គឺស្រុកកំណើតគាត់នៅដដែលៗ។ បើមានដែរ វាមានខ្លះ មានខ្លះទៅគាត់ទៅយកប្រពន្ធយកអី ដណ្តឹងប្រពន្ធដណ្តឹងអីអ៊ីចឹងទៅអាហ្នឹងអាចមានការផ្លាស់ប្តូរ។ តែអារឿងថា ពីត្រើយម្ខាងឆ្លងមកហ្នឹង ខ្ញុំអត់ដែលបានឮទេ។

**ស៖** តើពីកោះផលមក -- ពីកោះផល--

**អ្នកបកប្រែ៖**

លោកប្រធានសូមអធ្យាស្រ័យស្តាប់អត់ទាន់ទេ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

លោកមេធាវី តាំងសំណួរចុងក្រោយរបស់លោកសាជាថ្មីម្តងទៀត អ្នកបកប្រែបកប្រែមិនទាន់ទេ។

[១៥:៣០:៥២]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមទោសលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** តើមានចម្ងាយប៉ុន្មានពីកោះផលទៅវត្តអូរត្រកួន?

**លោក សេង ស៊្រុន៖**

**ឆ៖** ខ្ញុំដូចជាពិបាកក្នុងការឆ្លើយដែរ ព្រោះថាខ្ញុំនៅហ្នឹង ខ្ញុំអត់ទាំងស្គាល់កោះផលផងហ្នឹង។

**ស៖** បាទ ប្រធានបទចុងក្រោយ ខ្ញុំនឹងរូតសួរឲ្យបានលឿន។ លោកថា មឿន ក៏បានប្រាប់

លោកផងដែរ ថាគាត់ចូលរួមពាក់ព័ន្ធនៅក្នុងការសម្លាប់មនុស្សក្នុងខែកុម្ភៈ ឆ្នាំ១៩៧៥។ ត្រឹមត្រូវដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

មិនមែនជាការជំទាស់ តែគ្រាន់តែជាការកត់សម្គាល់។ ខ្ញុំមិនដែលបានឮអំពីការកាប់សម្លាប់នៅមុនខែកុម្ភៈ ១៩៧៥ទេ។ ខ្ញុំច្បាស់ហើយថា គាត់មានឆ្លើយនៅកន្លែងណាមួយនោះ។ គាត់និយាយថា ប្រជាជន១៧មេសា ឬក៏ប្រជាជនថ្មីនេះគឺថា ក៏ត្រូវបាន មឿន នេះបានប្រាប់គាត់ ហើយចូលរួមពាក់ព័ន្ធក្នុងការសម្លាប់មនុស្សមុនខែកុម្ភៈ ៧៥។

[១៥:៣២:៤៥]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ដើម្បីឲ្យបានលឿន ខ្ញុំសូមរៀបសំណួរឡើងវិញ។ លោកសាក្សី តើ មឿន មានបានប្រាប់លោកថា គាត់បានចូលរួមពាក់ព័ន្ធនៅក្នុងសម្លាប់មនុស្សនៅក្នុងខែកុម្ភៈ ១៩៧៥ មែនទេ?

**លោក ឌេល លីសាក់៖**

លោកមានថា លោកមេធាវីលោកថា ខែកុម្ភៈ ៧៧ ឬក៏ ៧៥?

**លោក វ៉ិចទ័រ កូប៉េ៖**

សូមទោស គឺខែកុម្ភៈ ៧៧ ទេ សូមអធ្យាស្រ័យ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី តើ មឿន មានប្រាប់លោកថា គាត់បានចូលរួមពាក់ព័ន្ធសម្លាប់មនុស្សនៅមុនខែកុម្ភៈ ១៩៧៧ ទេ?

**លោក សេង ស៊្រុន៖**

**ឆ៖** បាទ ដូចខ្ញុំបានរៀបរាប់ហ្នឹងគឺថា មឿន និងខ្ញុំហ្នឹងគឺមានការជិតស្និទ្ធនឹងគ្នាណាស់។ ធ្វើការអីនៅក្បែរអីចឹងទៅ រឿងអីៗក៏គេនិយាយប្រាប់ខ្ញុំដែរ គេមិនដែលលាក់ទេ។ ហើយដូចលោកមេធាវីថា ពី៧៥ ឯណានោះ អាន់ុងមិនមែនជាការពិតទេ ពីព្រោះ៧៥ វត្តអូរត្រកួនមិនទាន់សន្តិសុខផង

ហ្នឹង នៅខ្មៅ នៅនឹងសន្ទើមដូចទេនេះ។ ហើយនៅក្នុងឆ្នាំ១៩៧៦, ៧៧ហ្នឹងបានគេមកនៅជាប់នៅនឹងវត្តអូរត្រកួនហ្នឹងតែម្តង។ ហើយការដែល មឿន ដែលមានការជិតស្និទ្ធជាមួយខ្ញុំនឹង គឺគាត់ក្នុងឆ្នាំ១៩៧៧ហ្នឹង គឺស្គាល់គ្នាជិតដិតមែនទែន។ មកពីដំបូងៗ អត់សូវមានការទំនាក់ទំនងគ្នាទេ ព្រោះយើងអត់ស្គាល់គ្នា។ ដល់បានមកឡើងត្នោតក្បែរគ្នាអីចឹងទៅ ក៏មានការទំនាក់ទំនង។ ដូច្នេះការអី កិច្ចការអីក្នុងកន្លែងវត្តហ្នឹង គឺគាត់បាននិយាយប្រាប់ខ្ញុំថាស្ទើរតែគ្រប់រឿង។ ហើយមិនមែនជារឿងក្លែងក្លាយរឿងមិនពិតទេ ដូចករណីសម្លាប់បងប្អូនជនជាតិអ៊ីស្លាមហ្នឹង។ បើសិនជាថា បងប្អូនអ៊ីស្លាមនៅ ម្យប់ហ្នឹងចាប់មក ព្រលឹមឡើងទៅណាអស់ទៅ បញ្ជូនទៅណា? មិនយកទៅវ៉ៃចោល។ ដឹករទេះសេះទៅ ផ្ទះខ្ញុំត្រង់នុំង មិនឮរទេះសេះ។ រួចដល់គាត់និយាយមក គាត់ប្រាប់ខ្ញុំថាវ៉ៃចោល វាវ៉ៃចោលមែនហ្នឹង។ ហើយដល់តែពេលចប់ទៅ ៧៩ទៅ យើងទៅមើលឃើញជាក់ស្តែង គឺរណ្តៅប្រាំហ្នឹង គឺសុទ្ធតែបងប្អូនអ៊ីស្លាមមែន។

[១៥:៣៥:០៥]

**សៈ** ប៉ុន្តែសំណួរខ្ញុំអ៊ីចេះទេលោកសាក្សី តើ មឿន មានបានប្រាប់លោកថា មឿន នេះគាត់ចូលរួមសម្លាប់មនុស្សមុន អាន, ហាន, កាន អីមកដល់ទេ? តើគាត់មានតួនាទីអ្វីនៅវត្តអូរត្រកួនដែរទេ? សូមលោកបញ្ជាក់ចំណុចនេះបន្តិចមើល។

**ឆៈ** ការដែលគាត់មុននឹង អាន មុននឹង ហាន ហ្នឹងចូលមកដល់ហ្នឹង គាត់គ្រាន់តែជាសមាជិកនៅក្នុងកងសន្តិសុខហ្នឹង ហើយសន្តិសុខហ្នឹងគឺអត់នៅហ្នឹងទេ ជំនាន់គាត់ ជំនាន់ អាន អីមកហើយទេបាននេះ អង្កាល់ពីមុនមកនៅឯខ្មៅនោះទេ ប៉ុន្តែក្នុងស្រុកកងមាសដូចគ្នា។ ដូច្នេះការដែលពីនៅសន្តិសុខពីមុនដែលគាត់បានចូលរួមអីហ្នឹង ក៏គាត់បាននិយាយទេ គាត់និយាយតែក្នុងអំឡុងពេលដែលគាត់ជួបខ្ញុំគាត់ស្គាល់ខ្ញុំ នៅឆ្នាំ៧៧ ចុងឆ្នាំ៧៦ ដើមឆ្នាំ៧៧ហ្នឹង។

**លោក វ៉ិចទ័រ កូប៉េះ**

ដើម្បីជាប្រតិចារឹក ថាខ្ញុំនៅមានសំណួរច្រើនណាស់លោកប្រធាន ប៉ុន្តែដោយសារតែដល់ពេលទៅហើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញសហមេធាវីការពារក្តីលោក ខៀវ សំផន។

[១៥:៣៦:៣៩]

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម ជម្រាបសួរភាគីទាំងអស់។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរសាក្សី ខ្ញុំឈ្មោះ អត់តា ហ្គីសសេ ខ្ញុំជាសហមេធាវីអន្តរជាតិការពារលោក ខៀវ សំផន។ ខ្ញុំសូមសួរសំណួរបន្ថែមមួយចំនួនទៅកាន់លោក។ សំណួរទី១ នៅពេលដែលលោកឆ្លើយទៅនឹងសហព្រះរាជអាជ្ញា លោកបានបញ្ជាក់ថា លោកស្ថិតនៅក្នុងតំបន់៣០ក្នុងភូមិភាគឧត្តរ។ តើលោកមានចាំទេថា នៅក្នុងពេលណាមួយនោះ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ភូមិភាគឧត្តរមានផ្លាស់ប្តូរឈ្មោះទេ?

**លោក សេង ស្រ៊ុន៖**

**ឆ៖** នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ការផ្លាស់ប្តូរហ្នឹងដូចជាមិនមានទេ ដូចជាគ្រាន់តែថាពីមុនមកហ្នឹងវា ដល់មក៧៨ ចិតអីហ្នឹង ខ្ញុំមិនដឹងទេ ក៏ប៉ុន្តែពី៧៥, ៧៦, ៧៧ហ្នឹង គឺនៅជាភូមិភាគ៣០៤ ហើយខ្ញុំហ្នឹងរស់នៅតំបន់៣០ ហើយបន្ទាប់ទៀត មានតំបន់ ៣១, ៣២, ៤១ អីអ៊ីចឹងទៅ។

**ស៖** នៅពេលដែលលោកឆ្លើយទៅនឹងសហព្រះរាជអាជ្ញាដដែល លោកបានបញ្ជាក់ថា នៅពេលដែលលោកត្រឡប់មកភូមិវិញនៅឆ្នាំ៧៦ ក្រោយពីលោកចូលធ្វើយោធា គេចាប់ខ្លួនលោក។ លោកអាចបញ្ជាក់បានទេ អ្នកណាជាអ្នកចាប់ខ្លួនលោក?

**ឆ៖** ខ្ញុំមិនដឹងជាអ្នកណាទេ ដែលគេបញ្ជាឲ្យចាប់ខ្លួនហ្នឹង ប៉ុន្តែអ្នកដែលទៅចាប់ខ្ញុំផ្ទាល់គឺឈ្មោះ សំរិត មុយ។ គាត់ជាឈ្លបសង្កាត់ ឈ្លបឃុំ ហើយនិងបង គ្នាគាត់ប៉ុន្មាននាក់ទៀតទេ ដែលខ្ញុំមិនសូវជាចាំទេ ប៉ុន្តែខ្ញុំស្គាល់ច្បាស់គឺ សំរិត មុយ ហ្នឹងតែម្តងអ្នកដែលចាប់ខ្ញុំ ព្រោះគេខាងប្រធានឈ្លប។

[១៥:៣៩:០០]

**ស៖** លោកដឹងថានៅក្នុងកងឈ្លបហ្នឹង គាត់មានតួនាទីអ្វីឲ្យប្រាកដទេ?

**ឆ៖** តួនាទីគាត់ហ្នឹងវាពិបាកសន្មតថា គាត់ធ្វើអីប្រាកដណាស់ ក៏ប៉ុន្តែក្នុងឃុំពាមជីកងហ្នឹង គឺការដើរចាប់ដើរចងនេះ គឺនៅលើគាត់។ ហើយយើងមិនអាចដឹងថាគាត់ធ្វើអីឲ្យប្រាកដទេ ហើយព្រោះគាត់ធ្វើតាំងពីឆ្នាំ១៩៧៤, ៧៥ម្ល៉េះ ហើយគាត់បានចូលរួមសម្លាប់បងប្អូនប្រជាពលរដ្ឋដែលជម្លៀសពីទីក្រុងភ្នំពេញទៅ គេហៅថាប្រជាជនថ្មីហ្នឹង គាត់មានការយកទៅសម្លាប់ដែរ សម្លាប់ពួកទាហាន ពួក

ស្ទីខាងកណ្តាលខាងអីហ្នឹង យកទៅសម្លាប់ច្រើននៅ អង្កាល់ដំបូងនោះ អត់មានមន្ទីរសន្តិសុខអីទេ គឺនៅគេយកទៅវៃចោលនៅក្រោយសាលាលីសេពាមជីកង សព្វថ្ងៃជាវិទ្យាល័យ ហ៊ុន សែន ពាមជីកង។ មានអណ្តូងមួយ គេយកអ្នកដែលត្រូវសម្លាប់ គេសម្លាប់រួច គេយកបោះចោលក្នុងអណ្តូងនុ៎ង។

**សៈ** លោកបាននិយាយថាលោកបានត្រឡប់ទៅវិញ នៅឆ្នាំ១៩៧៦។ ខ្ញុំអត់និយាយអំពី៧៤, ៧៥ទេ ខ្ញុំនិយាយអំពីឆ្នាំ៧៦ និងឆ្នាំក្រោយៗមកទៀត។ តើលោកអាចបញ្ជាក់បានទេថា នៅឆ្នាំ១៩៧៦ ពេលលោកត្រឡប់មកភូមិសាច់សូរវិញហ្នឹងគឺ សំរិត មុយ ហ្នឹងមែនទេជាអ្នកចាប់ខ្លួនលោក?

**ឆៈ** បាន ខ្ញុំបញ្ជាក់ហើយថា សំរិត មុយ ហ្នឹងគេអ្នកទៅចាប់ខ្ញុំ តែគេទទួលបញ្ជាពីណា គឺខ្ញុំអត់ដឹងទេ។ ដល់ពេលគេមកចាប់យើង ចាប់យើងហើយ គេមិនមែនប្រាប់ថាពីណាមកឲ្យចាប់។ ប៉ុន្តែក្នុងចង្កោមសន្តិសុខហ្នឹង គឺខ្ញុំស្គាល់ច្រើន មានឈ្មោះ ស្រ៊ាង, ឈ្មោះ អ៊ុយ, ឈ្មោះ មុយ ហ្នឹង សុទ្ធតែកងសន្តិសុខដើរចាប់មនុស្សហើយឈ្លបហ្នឹង។

[១៥:៤១:១៩]

**សៈ** ខ្ញុំនឹងត្រឡប់មកនិយាយចំណុចនេះនៅពេលក្រោយ ក៏ប៉ុន្តែខ្ញុំចង់ដឹងថាតើនៅឆ្នាំ១៩៧៦ ហ្នឹងនៅក្នុងឃុំពាមជីកងហ្នឹង ឪពុកលោកមានតួនាទីអ្វីដែរ?

**ឆៈ** ឪពុកខ្ញុំ ដល់មកចូលឆ្នាំ៧៦ហ្នឹង គាត់អត់មានតួនាទីអីទេ ក៏ប៉ុន្តែគាត់មានតួនាទីកាលពីឆ្នាំ ៧១, ៧២ មកដល់៧៥ ដល់៧៦ហ្នឹងគាត់អស់តួនាទីហើយ គាត់អត់មានធ្វើអីទេ។ គេដាក់សុទ្ធតែអ្នកដែលសុទ្ធតែជាកម្មាភិបាលអី ដែលគេតស៊ូពីមុនៗមកហ្នឹង ហើយចំពោះឪពុកខ្ញុំគឺអត់មានការងារអីទេ។

**សៈ** ពី៧១ ដល់៧៥ហ្នឹង ឪពុកលោកមានមុខតំណែងអីដែរ?

**ឆៈ** ពី៧១ ដល់៧៥ហ្នឹង ឪពុកខ្ញុំមានតួនាទីគេហៅថា ប្រធានសង្កាត់ៗ។ គាត់គ្រប់គ្រងមួយសង្កាត់ហ្នឹង ប្រជាជនថ្មីអីហ្នឹងគាត់មើលខុសត្រូវទាំងអស់។ តែគាត់ជួយច្រើនណាស់ទៅដល់ប្រជាជនថ្មីដែលគេប្រុងធ្វើបាប គេប្រុងសម្លាប់អីហ្នឹង គឺគាត់បានបង្កេច បានពង្វាង បានជូនដំណឹង វាមាននេះច្រើន។ ដោយសារគេមើលឃើញអីចឹងហើយ ថាគាត់ហ្នឹងដូចថាមិនគោរពគេអីអ៊ីចឹងទៅ ចេះតែលួចប្រាប់ពួកហ្នឹងឲ្យរត់ ឲ្យគេចអ៊ីចឹងទៅ បានគេដកគាត់ចេញទៅ គាត់អស់តួនាទីនៅឆ្នាំ៧៥ហ្នឹង។

**សៈ** ខ្ញុំសួរសំណួរពាក់ព័ន្ធនឹងកាលបរិច្ឆេទនេះ ពីព្រោះថានៅក្នុងកំណត់ហេតុរបស់លោក គឺឯកសារ E3/1692, ERN ជាភាសាបារាំងគឺ 00337424, ERN ជាភាសាអង់គ្លេស 00242086 និង ERN ជាភាសាខ្មែរគឺ 00218552 ហើយនិងបន្តទៅដល់ 53។ លោកបាននិយាយអំពីការចាប់ខ្លួនរបស់

លោកនៅឆ្នាំ៧៦។ លោកបាននិយាយថា លោកមានសំណាងណាស់ គេបានដោះលែងលោក ហើយលោកគិតថាដោយសារតែឪពុករបស់ដែលធ្លាប់ធ្វើជាប្រធានសង្កាត់នៅឃុំពាមជីកង។ សូមបញ្ចប់ការដកស្រង់។ ដូច្នេះខ្ញុំចង់សួរលោកដូចតទៅ តើត្រឹមត្រូវទេដែលថា លោកគិតថាគេដោះលែងលោកនោះដោយសារតែតំណែងឪពុកលោកពីមុនមក តើអ៊ីចឹងមែនទេ?

[១៥:៤៤:៣៥]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប!

សូមអញ្ជើញ!

**លោក ខេល លីសាក់៖**

ខ្ញុំមិនដឹងថាបញ្ហានេះដោយសារការបកប្រែឬយ៉ាងណាទេ ប៉ុន្តែអត្ថបទភាសាអង់គ្លេសនិយាយថាឪពុករបស់គាត់ -- តួនាទីមុនរបស់ឪពុកគាត់ -- ប៉ុន្តែមិនដឹងថាវាបាត់ជាភាសាបារាំង ឬម៉េចទេ។ គឺនេះនិយាយអំពីតួនាទីរបស់ឪពុកគាត់កាលពីមុន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ប្រហែលជាបញ្ហាបកប្រែហើយ ខ្ញុំអានតាមកំណត់ហេតុជាភាសាបារាំង អ៊ីចឹងឲ្យសាក្សីគាត់ឆ្លើយទៅ។ គឺមានន័យថា ដោយសារតែមុខតំណែងរបស់ឪពុកលោកពីមុនមែនទេ បានជាលោកមានសំណាងត្រូវបានគេដោះលែងនោះ?

[១៥:៤៥:៣០]

**លោក សេង ស៊្រុន៖**

**ឆ៖** នេះប្រហែលជាការពិតហើយ ព្រោះអ៊ីចេះ បញ្ហានេះអ៊ីចេះ។ កម្មាភិបាលដែលគេទើបនឹងផ្លាស់មកថ្មីហ្នឹង គាត់នៅក្បែរផ្ទះខ្ញុំ ហើយការទំនាក់ទំនងជាមួយឪពុកខ្ញុំ និងកម្មាភិបាលដែលគេមកថ្មីហ្នឹង ដូចថាវារាប់អានគ្នាអីអ៊ីចឹងទៅ។ ដល់អ៊ីចុងទៅ ការចាប់ខ្លួនខ្ញុំហ្នឹង ក៏ត្រូវបានដោះលែង ហើយការដោះលែងហ្នឹង មិនមែនដោះលែងតែខ្ញុំទេ ពីរនាក់ដែលត្រូវចាប់ខ្លួនហ្នឹង គឺលែងទាំងពីរនាក់។ ប្រហែលជាគេគិតឃើញថា ឪពុកខ្ញុំហ្នឹង គាត់មានគុណសម្បត្តិអីក្នុងការជួយបម្រើសម័យរណសិរ្សហ្នឹង បានជាគេនេះអ៊ីចុងបាទ លែងខ្ញុំវិញមក។

**ស៖** តើលោកអាចបញ្ជាក់បានទេ អ្នកណាជាអ្នកជំនួសឪពុកលោក ឡើងជាប្រធានសង្កាត់

ជំនួសឪពុកលោកនៅឆ្នាំ៧៦ហ្នឹង?

**ឆ៖** អ្នកដែលឡើងជួសឪពុកខ្ញុំហ្នឹង គឺគាត់ឈ្មោះ រុន ប៉ុន្តែឥឡូវគាត់ស្លាប់ហើយ ហើយកម្មាភិបាលគេមកផ្លាស់ថ្មីឈ្មោះ ហេង គាត់ជាកម្មាភិបាល។ កម្មាភិបាលនេះ គឺសិទ្ធិគាត់ធំជាងសង្កាត់ហ្នឹងទៀត។ សង្កាត់ ចៅសង្កាត់ផ្សេង កម្មាភិបាលផ្សេង បាទសម័យនុំងគេបែងចែកអ៊ីចឹង។ ហើយជំនួសឪពុកខ្ញុំនេះ គឺឈ្មោះ តារុនៗ គេគាត់ដាក់ឈ្មោះក្នុងឈ្មោះបដិវត្តន៍គាត់ ឈ្មោះ សំរិត។

**ស៖** ខ្ញុំនិយាយឆ្នាំ៧៦ដដែល ខ្ញុំចង់ដឹងថា អ្នកណាជាប្រធានសន្តិសុខឃុំពាមជីកង?

[១៥:៤៧:៣០]

**ឆ៖** ប្រធានសន្តិសុខឃុំពាមជីកងហ្នឹង វាដូចជាវាច្របូកច្របល់គ្នា វាមាន មុយ ហ្នឹងផង អ៊ូ ប៉ុន្តែពី៧៦ហ្នឹងឈ្មោះ ណាំ នេះជាប្រធានសន្តិសុខ។ ក្រោយមកបាន ណាំ ហ្នឹងគេបញ្ជូនទៅឲ្យធ្វើសន្តិសុខតំបន់នៅ៧គរ នៅភូមិគរ។ ផ្លាស់ពីពាមជីកងទៅ ឡើងបានប្រធានមួយហ្នឹងឈ្មោះ អោក ហ្នឹងប្រធានឈ្លប ប្រធានខាងសន្តិសុខហ្នឹង ហើយជាមួយ មុយ ហ្នឹងពីរនាក់ហ្នឹងមិនដឹងជាពីណាមេ ពីណាកូនទេ វាច្របូកច្របល់។ ហើយយើងក៏គ្មានបានត្រូវដេញដោលអីច្បាស់លាស់ ថាពីណាប្រធាន ពីណាមិនប្រធាន ឃើញតែគេថាឈ្លបឃុំ អំណាចគេធំ ឈ្លបឃុំហ្នឹងទៅ ប៉ុន្តែប្រធានមិនប្រធានច្បាស់លាស់ហ្នឹង ខ្ញុំវាដូចថា វាស្រពេចស្រពិលដែរ ដឹងតែប្រធានចាស់មួយពីមុន ឈ្មោះ ណាំ ហ្នឹងគេបានដកគាត់ទៅនៅធ្វើប្រធានសន្តិសុខនៅគរ។

**ស៖** ខ្ញុំចង់ឲ្យលោកបញ្ជាក់បន្តិច ពាក់ព័ន្ធទៅនឹងបញ្ហាឈ្លបនេះ ហើយខ្ញុំយល់ថា នៅក្នុងឆ្នាំ៧៦ នៅពេលដែលគេចាប់ខ្លួនលោកនោះ សំរិត មុយ គឺជាកងឈ្លប ហើយខ្ញុំដឹងថា លោកមិនដឹងថា អ្នកណាជាប្រធាន អ្នកណាជាអនុប្រធានរវាង ណាំ និង មុយ ហ្នឹង មិនដឹងអ្នកណាមេ អ្នកណាកូនចៅទេ។ អ៊ីចឹងខ្ញុំចង់ដឹងឲ្យច្បាស់ថា លោកនិយាយហ្នឹង លោកនិយាយឆ្នាំ៧៦, ៧៧, ៧៨, ៧៩ លោកសំដៅទៅពេលណា នៅពេលដែលលោកនិយាយថា លោកមិនដឹងថា មុយ ហើយនិង ណាំ ហ្នឹងអ្នកណាជាមេ អ្នកណាជាអីហ្នឹង លោកសំដៅទៅលើឆ្នាំណា?

**ឆ៖** ខ្ញុំនិយាយនេះ គឺសំដៅទៅលើឆ្នាំ១៩៧៦។ ៧៦ហ្នឹងនៅដើមឆ្នាំហ្នឹង គឺពួកហ្នឹងនៅឡើយទេ ហើយ មុយ ហ្នឹងអង្គាល់នុំងគេប្តូរប្រធានសង្កាត់ចាស់ៗហ្នឹង ដូចគេចាប់អស់ហើយ ហើយឡើងប្រធានសង្កាត់ស្រីមួយទៀត ឈ្មោះ មិត្តតេង ។ មិត្តតេង ហ្នឹងគេដូចថាអ្នកគេត្រួតពីលើ មុយ ហ្នឹងទៀត។

**ស៖** លោកបាននិយាយជាមួយសហព្រះរាជអាជ្ញាអំពីក្រុមពីរ ខ្ញុំចង់ឲ្យលោកបំភ្លឺពាក់ព័ន្ធនឹង

ចំណុចនេះ។ លោកនិយាយអំពីឈ្លបឃុំ និងក្រុមដាវវែង តើលោកអាចបញ្ជាក់បានទេថា ណាំ និង មុយ នេះ នៅក្នុងក្រុមណា ក្រុមដាវវែងហ្នឹង ឬក៏យ៉ាងម៉េច?

[១៥:៥០:៤៦]

**ឆ៖** ខ្ញុំសូមជម្រាបថាក្រុម មុយ ដែលក្រុមដាវវែងហ្នឹង គឺគេមានតួនាទីដោយឡែកពីគ្នា។ ដោយឡែកយ៉ាងម៉េច ក្រុមដាវវែង ដូចខ្ញុំបានជម្រាបហើយ គឺថាគេសម្រាប់ទៅនាំអ្នកដែលគេត្រូវចាប់ខ្លួន។ ឧបមានៅតាមការដ្ឋានអីអ៊ីចឹងទៅ គេចាប់ប្រជាពលរដ្ឋ បើភាគច្រើនគឺប្រជាជនថ្មី គេហៅប្រជាជន៧៥ហ្នឹង។ កាលណាគេចាប់ប្រាំនាក់ ប្រាំមួយនាក់អីអ៊ីចឹងទៅ គេត្រូវហៅពួកដាវវែងហ្នឹងដើម្បីនាំយកមកចូលវត្តអូរត្រកួន។ ហើយអាពួកឈ្លបនេះ វាសម្រាប់ដើរចាប់អ្នកស្រុកនៅក្នុងភូមិ នៅក្នុងឃុំអីហ្នឹង។ វាមានតួនាទីខុសគ្នា។ តែក្រុមហ្នឹងវាដូចធ្វើការតែមួយទេ គ្រាន់តែបែងចែកអ៊ីចឹង។

**ស៖** ដូច្នេះ បើខ្ញុំស្ដាប់មិនច្រឡំទេគឺថា សំរិត មុយ ហ្នឹងគឺជាសមាជិកក្រុមដាវវែងមែនទេ?

**ឆ៖** សំរិត មុយ ហ្នឹងគាត់មិនមែនជាក្រុមសមាជិកដាវវែងទេ គាត់ជាសមាជិកក្រុមឈ្លបឃុំ។

**ស៖** តើលោកដឹងពីឆ្នាំណាដល់ឆ្នាំណាទេ ដែលគាត់នៅក្នុងឈ្លបឃុំហ្នឹង?

**ឆ៖** បើតាមការខ្ញុំដឹង គឺគាត់ធ្វើតាំងពីឆ្នាំ១៩៧៣ រហូតដល់ឆ្នាំ៧៩ បានគាត់ឈប់។ ដល់ពេលឈប់ទៅគាត់អត់ប៊ាននៅស្រុកទេ គាត់រត់ទៅនៅស្រុកគេនោះ រត់មកត្រើយត្បូង ហើយបានរត់ទៅនៅចំការលើ។ កន្លែងគាត់ធ្លាប់រស់នៅហ្នឹង គាត់អត់ប៊ានរស់នៅទេ។

**ស៖** លោកថា គាត់កាន់តំណែងហ្នឹងពី៧៣ដល់៧៩ លោកឃើញផ្ទាល់ភ្នែកទេ? លោកឃើញគាត់ធ្វើជាឈ្លបឃុំនុ៎ង លោកឃើញផ្ទាល់ភ្នែកទេពីឆ្នាំ៧៣ដល់ ឥឡូវខ្ញុំនិយាយថាទៅដល់៧៩ចុះ លោកឃើញផ្ទាល់ភ្នែកថា គាត់នៅធ្វើជាឈ្លបហ្នឹងដល់ឆ្នាំហ្នឹងទេ?

[១៥:៥៣:២១]

**ឆ៖** ខ្ញុំសូមជម្រាបថា ការដែលខ្ញុំនិយាយនេះ ខ្ញុំមិនចេះតែនិយាយដើម្បីបង្អាប់កេរ្តិ៍ឈ្មោះកិត្តិយសគេទេ។ ហើយខ្ញុំក្នុងនាមជាខ្ញុំសាក្សី គឺខ្ញុំនិយាយអីតែការពិត ដែលខ្ញុំឃើញ ដែលខ្ញុំបានដឹង ពីមុនមក។ ហើយមួយទៀត គឺថាខ្ញុំរស់នៅក្នុងភូមិសំបួរមាសនេះ គឺតាំងពីខ្ញុំអាយុ១ឆ្នាំម្ល៉េះ ដល់ពេលជំនាន់សម័យ ប៉ុល ពត ហ្នឹងខ្ញុំអាយុជាង៣០ឆ្នាំហើយ។ ហើយមករហូតដល់ឥឡូវ ខ្ញុំអាយុ៦៥ឆ្នាំហើយ ដូច្នេះការដែលខ្ញុំនិយាយគឺជាការពិត មិនមែនថា អ្ហ៎! តាមគេប្រាប់ទេ។ ព្រោះខ្ញុំឃើញ មុយ ហ្នឹងសម័យអាប៉ុល ពត កម្មាភិបាលមុនក៏នៅ គេចាប់អាមេកម្មាភិបាលចាស់ៗអស់ហ្នឹង មកអាថ្មី ក៏ មុយ ហ្នឹង

នៅ។ ទាល់តែដាច់ឆ្នាំ៧៩ហ្នឹង បានគាត់រត់តែម្តង។ ហ្នឹងបញ្ចាក់ខ្លីអ៊ីចឹង។

**ស៖** លោកសាក្សី ខ្ញុំសូមទោស ខ្ញុំមានពេលខ្លីណាស់ អ៊ីចឹងសូមឲ្យលោកឆ្លើយខ្លីៗបានហើយ។ ដូច្នេះខ្ញុំយល់ថា លោកឃើញ សំរិត មុយ ហ្នឹងធ្វើការជាឈ្លបហ្នឹងដល់៧៩ អ៊ីចឹងមែនទេលោក គ្រាន់តែឆ្លើយថា “បាទ” ឬក៏ “មិនមែន” ឬក៏ “ទេ” អ៊ីចឹងទៅបានហើយ សូមកុំឆ្លើយវែងពេក?

**ឆ៖** បាទ មែន។

**ស៖** ដូច្នេះលោកបែងចែកដាច់ពីគ្នារវាងក្រុមឈ្លបឃុំ ហើយនិងក្រុមដាវវែង។ តើលោកអាចរៀបរាប់បានទេថា អ្នកណាខ្លះដែលជាអ្នកស្ថិតនៅក្នុងក្រុមដាវវែងនោះ?

[១៥:៥៥:២៣]

**ឆ៖** វាខ្ញុំស្គាល់ ប៉ុន្តែខ្ញុំមកទល់ពេលឥឡូវខ្ញុំអាចរាប់រៀបបានអស់ទេ ប៉ុន្តែខ្ញុំនៅស្គាល់ច្រើនដែរ។ ១)គឺ ឡាវ ខួយ ហ្នឹងគាត់សព្វថ្ងៃជា ត្រូវជាបងថ្លៃខ្ញុំ។ មួយទៀត តាយ គឹមប៊ាន់ សព្វថ្ងៃគាត់ជាគណៈកម្មការវត្ត។ ហើយមួយទៀតឈ្មោះ ម៉េង លី។ មួយទៀតឈ្មោះ ហេង ប៉ា។ មួយទៀតឈ្មោះ យឿន ខ្ញុំអត់ដឹងនាមត្រកូលអីទេ។ ហើយមួយទៀតនៅខាងកោះតូច។ ពីរនាក់ទៀត ប៉ុន្តែសព្វថ្ងៃគាត់ស្លាប់អស់ហើយ ខ្ញុំដូចជាភ្លេចឈ្មោះគាត់អស់ហើយ។ ក្រុមដាវវែងហ្នឹងមានសមាជិកវាទាំងអស់ប្រាំបួននាក់។

**ស៖** ខ្ញុំនឹងត្រឡប់មកនិយាយអំពីបញ្ហាហ្នឹងនៅពេលក្រោយ ក៏ប៉ុន្តែខ្ញុំចង់ដឹងថា នៅថ្ងៃដែលគេចាប់ខ្លួនជនជាតិចាម ហើយដែលលោកនាំទៅវត្តហ្នឹង ខ្ញុំចង់ដឹងថា ក្រុមដាវវែងហ្នឹងមានវត្តមាននៅពេលចាប់ជនជាតិចាមទាំងអស់ហ្នឹងបញ្ជូនទៅវត្តអូរត្រកួនហ្នឹងទេ?

**ឆ៖** បាទ នៅពេលគេចុះចាប់បងប្អូនអ៊ីស្លាមហ្នឹង គឺក្រុមដាវវែងហ្នឹងហើយគេអ្នកដើរចាប់។

**ស៖** តើមនុស្សដែលលោករៀបរាប់ក្នុងចំណោមអ្នកទាំងប្រាំបួននាក់ នៅក្នុងក្រុមដាវវែងហ្នឹងមានវត្តមានទាំងអស់មែនទេ ទាំង ខួយ, តាយ គឹមប៊ាន់, ម៉េង លី, ហេង ប៉ា, យឿន អីដែលលោករៀបរាប់អម្បាញ់មិញហ្នឹង ប្រាំបួននាក់ហ្នឹងគឺមានវត្តមានព្រមគ្នាតែម្តងក្នុងពេលចាប់ខ្លួនហ្នឹងមែនទេ?

**ឆ៖** បាទ ក្នុងការចុះចាប់បងប្អូនចាមហ្នឹង គឺវត្តមានអ្នកដាវវែងប៉ុន្មាន គឺទៅទាំងអស់។ ក៏ប៉ុន្តែគេចែកគ្នាជាពីរក្រុម មួយក្រុមហ្នឹងគេចាប់នៅខាងភូមិសំបួរមាស“ក” ហើយមួយក្រុមទៀតហ្នឹងគេចាប់នៅខាងសំបួរមាស “ខ” និងភូមិសាច់ស្វ។ វាបីភូមិ បងប្អូនចាមនៅហ្នឹងគឺបីភូមិ។

**ស៖** ដូច្នេះខ្ញុំអាចនិយាយបានទេថា ក្រុមដាវវែងហ្នឹងគឺដើរចាប់ខ្លួនមនុស្សគ្រប់ភូមិទាំងអស់នៅ

ក្នុងឃុំពាមជីកងមែនទេ?

[១៥:៥៨:២៨]

**ឆ៖** ក្រុមដាវវែងហ្នឹង គេដើរចាប់ខ្លួនអ្នកទោសមែន ក៏ប៉ុន្តែទាល់តែមានផែនការអី ដូចខ្ញុំបានជម្រាបហើយថា គេចាប់ច្រើនអីអ៊ីចឹង ទៅការដ្ឋានអីដូចថានៅកន្លែងការដ្ឋានហ្នឹង គេឲ្យពួកដាវវែងហ្នឹងអ្នកទៅនាំខ្លួនជនដែលគេត្រូវចាប់ហ្នឹងមក។ បើនៅតាមឃុំ តាមអី មិនសូវមានទេ មានដែរម្ដងម្កាល។

**ស៖** ប្រសិនខ្ញុំមិនច្រឡំទេ កាលពីព្រឹកមិញនេះលោកនិយាយថា ក្រុមដាវវែងនេះត្រូវបានបង្កើតឡើងនៅក្នុងចុងឆ្នាំ៧៦ ដើមឆ្នាំ៧៧។ អ៊ីចឹងខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** អ្នកទាំងប្រាំបួនដែលជាសមាជិកកងដាវវែងហ្នឹង គាត់មកពីភូមិភាគបូព៌ាទាំងអស់ ហើយមកពីឃុំពាមជីកងទាំងអស់ ឬក៏យ៉ាងម៉េច?

**ឆ៖** ក្រុមដាវវែងដែលគេរៀបចំឡើងហ្នឹង គឺអត់មានមកពីណាទេ គឺស្ថិតនៅក្នុងឃុំពាមជីកងទាំងអស់។ គាត់ជាប្រជាជននៅក្នុងឃុំទាំងអស់ហ្នឹង។

**ស៖** លោកដឹងទេថា អ្នកណាជាអ្នកបង្កើតក្រុមដាវវែងនេះ?

**ឆ៖** តាមពិតទៅ រឿងអ្នកបង្កើតក្រុមដាវវែងហ្នឹង អង្កាល់ពីពួកនិរតីអត់ទាន់ទៅ គឺអត់មានទេ ទើបពួកនិរតីវាមកកាន់កាប់ហ្នឹង គឺគេបង្កើតក្រុមដាវវែងហ្នឹង គឺមានឈ្មោះ ភាព។ ភាព ហ្នឹងជាប្រពន្ធឈ្មោះ កាន។ កាន ហ្នឹងជាគណៈស្រុក។ ហើយ ភាព គាត់អនុស្រុកផង ហើយគាត់ក៏ជាតំណាងឃុំពាមជីកងដែរ តែប្រធានសង្កាត់ហ្នឹងគេឲ្យទៅ ខេន។ គាត់ហ្នឹងគ្រាន់តែជាកម្មាភិបាលគ្រប់គ្រងមួយឃុំព្រោះអង្កាល់នុ៎ង កម្មាភិបាលហ្នឹងផ្សេង ប្រធានសង្កាត់ហ្នឹងផ្សេង។ គេនិយាយពីរឿងពេញសិទ្ធិ មិនពេញសិទ្ធិអីនោះ ខ្ញុំវាមិនសូវយល់ទេ បញ្ហាខ្មែរក្រហម។

[១៦:០១:១៨]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំមើលម៉ោងទៅ គឺថាម៉ោងបួនហើយ។ ខ្ញុំអាចជម្រាបបានថា ខ្ញុំមិនអាចបញ្ចប់ការសួរសំណួររបស់ខ្ញុំជាមួយនឹងពេលវេលាបន្ថែមបន្តិចបន្តួចហ្នឹងទេ។ ខ្ញុំគិតថា សំណួររបស់ខ្ញុំគឺមានភាពពាក់ព័ន្ធច្រើន។ អ៊ីចឹងខ្ញុំសូមអនុញ្ញាតដើម្បីបញ្ចប់នៅថ្ងៃស្អែកព្រឹក លោកប្រធាន ហើយនិងគិតគូរទៅលើបញ្ហាសុខភាពរបស់កូនក្តីរបស់ខ្ញុំផង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះនឹងបន្ថែមពិនិត្យបន្ថែម២០នាទីនៅព្រឹកថ្ងៃស្អែក។

សវនាការនៅថ្ងៃនេះ ដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃអង្គារ ទី១៥ ខែកញ្ញា ឆ្នាំ ២០១៥ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ សវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងបន្តធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី សេង ស្រ៊ុន បញ្ចប់ ដែលនឹងសួរដោយក្រុមសហមេធាវីការពារក្តីលោក ខៀវ សំផន ហើយនិងចាប់ផ្តើមស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-883 សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

[១៦:០២:៣២]

អង្គជំនុំជម្រះអរគុណលោក សេង ស្រ៊ុន ដំណើរការសវនាការស្តាប់សក្ខីកម្មរបស់លោក ក្នុងឋានៈជាសាក្សី នៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញឲ្យលោកមកផ្តល់សក្ខីកម្មនៅព្រឹកថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញជូនលោក សេង ស្រ៊ុន រួមទាំងសាក្សីបម្រុង 2-TCW-883 ត្រឡប់ទៅកាន់កន្លែងដែលគាត់ស្នាក់នៅ ហើយនិងសូមឲ្យអញ្ជើញពួកគាត់មកចូលរួមសវនាការវិញ នៅថ្ងៃស្អែក នៅវេលាម៉ោងប្រាំបួនព្រឹក។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ទាំងពីររូបត្រឡប់ចូលរួមសវនាការនៅថ្ងៃស្អែក ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

បាទ សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៣ នាទី)*